# ខ្មែរ 高棉 KHMER



## អបអរសាទរខួបលើកទី ១០០ ឆ្នាំនៃការបង្កើតបក្សកុម្មុយនិស្តចិន

## 庆祝中国共产党成立100周年

ISSN 2095-249X

NO. 117

07/2021




07/2021　NO.117

主管：中华人民共和国国务院新闻办公室
主办：云南省人民政府新闻办公室
承办：云南日报报业集团
编辑出版：《高棉》杂志社

编辑指导委员会成员
主任：彭　斌　何祖坤
副主任：王廷尧

总编辑：王廷尧
法人代表、常务副总编辑：熊　燕
执行主编：张若谷
编辑部主任：陈创业
编辑部副主任：曹云波
中文编辑：段建鑫
柬语编辑：沈　燕　李　吒
译审：陆禹初　Svay Narin
外籍审稿：KONG CHANTARA
翻译：北京外国语大学亚非学院　李轩志
第一读者：莫源源
视觉设计：孙勇刚
发行：张俊宏

地址：中国云南省昆明市西山区日新中路 516 号云报传媒广场 A 座 9 楼
邮编：650034
编辑部电话：86-871-64181611（传真）
办公室电话：86-871-64101644
E-mail：magazinekh@163.com
http：//www.yunnangateway.com
金边记者站：柬埔寨金边市森速区新金边分区 1966 路
BoreiPengHuoth 小区
电话：00855-012982065　023884028（传真）

发行部电话：86-871-64101727
发行范围：国内外公开发行
邮发代号：64-37
出版日期：每月1日
中国标准连续出版物号
ISSN 2095-249X
CN 53-1219/C
广告经营许可证号：5300004000094
印刷：云南日报印务中心
定价：10 元（人民币）/6000 瑞尔（柬币）

**អ្នកគ្រប់គ្រងទូទៅ :** ការិយាល័យព័ត៌មាននៃក្រុមប្រឹក្សាកិច្ចការរដ្ឋ
សាធារណរដ្ឋប្រជាមានិតចិន
**អ្នករៀបចំ :** ការិយាល័យព័ត៌មានសាលាខេត្តយូណាន
**អ្នកទទួលរៀបចំ:** ក្រុមហ៊ុនកាសែតយូណានដេលីគ្រុប
**អ្នករៀបរៀងនិងបោះពុម្ពផ្សាយ :** ទីភ្នាក់ងារទស្សនាវដ្ដី "ខ្មែរ"
**សមាជិកនៃគណៈកម្មការនិពន្ធ**
**នាយក :** PENG BIN　HE ZUKUN
**នាយករង :** WANG TINGYAO

**អគ្គនិពន្ធនាយក :** WANG TINGYAO
**នីតិបុគ្គល　និងជាអគ្គនិពន្ធនាយករងអចិន្ត្រៃយ៍ :** XIONG YAN
**និពន្ធនាយកប្រតិបត្តិ :** ZHANG RUOGU
**ប្រធានផ្នែកនិពន្ធ :** CHEN CHUANGYE
**អនុប្រធានផ្នែកនិពន្ធ :** CAO YUNBO
**អ្នកនិពន្ធភាសាចិន :** DUAN JIANXIN
**អ្នកនិពន្ធភាសាខ្មែរ :** SHEN YAN　LI ZHA
**អ្នកពិនិត្យការបកប្រែ :** LU YUCHU　ស្វាយ　ណារិន
**អ្នកពិនិត្យនិងសម្រួលការបកប្រែ(ជនជាតិខ្មែរ) :** គង់ ចាន់តារា
**បកប្រែ :** វិទ្យាស្ថានភាសាអាស៊ីអាហ្វ្រិកនៃសាកលវិទ្យាល័យភាសាបរទេសប៉េកាំង　LI XUANZHI
**មិត្តអ្នកអានទីមួយ :** ប្រភព
**រចនារូបភាព :** SUN YONGGANG
**បោះពុម្ពផ្សាយ :** ZHANG JUNHONG
**អាស័យដ្ឋាន :** ជាន់ទី ៩ នៃអគារ អា ទីធ្លាកាសែតយូណាន ផ្ទះលេខ ៥១៦ ផ្លូវយីស៊ីនជុង
ខណ្ឌស៊ីសាន ក្រុងគុនមីង ខេត្តយូណាន ប្រទេសចិន
**លេខកូដប្រៃសណីយ៍ :** ៦៥០០៣៤
**លេខទូរស័ព្ទនិងទូរសារផ្នែកនិពន្ធ :** ៨៦-៨៧១-៦៤១៨១៦១១
**លេខទូរស័ព្ទការិយាល័យ :** ៨៦-៨៧១-៦៤១០១៦៤៤
**អ៊ីម៉ែល :** magazinekh@163.com
**គេហទំព័រ :** http://www.yunnangateway.com
**អាសយដ្ឋាននៃទីស្នាក់ការអ្នកយកព័ត៌មានប្រចាំនៅរាជធានីភ្នំពេញរបស់ទស្សនាវដ្ដី"ខ្មែរ" :**
ផ្លូវលេខ ១៩៦៦ បុរីប៉េងហួតដីស្ដាឡែ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
**ទូរស័ព្ទលេខ :** ០០៨៥៥-០១២៩៨២០៦៥
**ទូរសារលេខ :** ០០៨៥៥-០២៣៨៨៤០២៨
**លេខទូរស័ព្ទផ្នែកបោះពុម្ពផ្សាយ :** ៨៦-៨៧១-៦៤១០១៧២៧
**ក្របខ័ណ្ឌនៃការចែកចាយ :** បោះពុម្ពផ្សាយនិងចែកចាយជាសាធារណៈនៅក្នុង
និងក្រៅប្រទេសចិន
**លេខកូដបោះពុម្ពផ្សាយតាមប្រៃសណីយ៍ :** ៦៤-៣៧
**ថ្ងៃ-ខែ-ឆ្នាំបោះពុម្ពផ្សាយ :** ថ្ងៃទីមួយប្រចាំខែ
**លេខបោះពុម្ពផ្សាយតាមស្តង់ដារចិន :**
ISSN 2095-249X
CN 53-1219/C
**លេខអជ្ញាប័ណ្ណផ្សាយពាណិជ្ជកម្ម :** ៥៣០០០០៤០០០០៩៤
**បោះពុម្ពដោយ :** Yunnan Daily Printing Center
**តម្លៃកំណត់ :** ១០យ៉ាន់(ប្រាក់ចិន)/៦០០០ រៀល(ប្រាក់រៀល)


人民视觉 图

庆祝中国共产党成立100周年
The 100th Anniversary of the Founding of The Communist Party of China

# មាតិកា 目录

## ខួបលើកទី ១០០ ឆ្នាំ 百年华诞


04 យកបទពិសោធន៍ និងមេរៀនពីប្រវត្តិសាស្ត្រ បង្កើតអនាគតភ្លឺស្វាង
以史为鉴 开创未来


## ចិត្តដើមដំបូងមានភាពរឹងមាំដូចថ្មរឹង 初心如磐


08 ចិត្តដើមដំបូងមានភាពរឹងមាំដូចថ្មរឹង
初心如磐


## ប្រវត្តិមួយសតវត្សរ៍ 百年波澜


10 ផ្លូវអភិវឌ្ឍន៍រយឆ្នាំរបស់ប្រទេសចិន
百年波澜中国路

34 ព្រឹត្តិការណ៍សំខាន់ក្នុងរយៈពេល ១០០ ឆ្នាំកន្លងទៅ
100 年大事记


## ប្រទេសចិនបច្ចុប្បន្ន 今日中国


36 ប្រទេសចិនបច្ចុប្បន្ន
今日中国


## មានភាពយុវវ័យជាដរាប 永远年轻


40 អ្នកបដិវត្តន៍មានភាពយុវវ័យជាដរាប
革命人永远是年轻

56 "គ្រឿងឥស្សរិយយស ១ កក្កដា"
"七一勋章"


## ទំនាក់ទំនងរាប់អានគ្នា 友好往来


60 រឿងនិទានរបស់មិត្តបរទេស និងបក្សកុម្មុយនិស្តចិន
国际友人与中国共产党的故事

66 អបអរសាទរការទទួលបានសមិទ្ធផលដ៏អស្ចារ្យរបស់បក្សកុម្មុយនិស្តចិន
为中国共产党的伟大成就喝彩

68 ប្រទេសចិនជាមិត្តពិតរបស់កម្ពុជា
中国是柬埔寨的真朋友

70 ប្រទេសចិនទទួលសមិទ្ធផលមហិមា
中国取得了伟大成就

72 គារវកិច្ចចំពោះគណបក្សកុម្មុយនិស្តចិនដ៏អស្ចារ្យ
致敬伟大的中国共产党

# យកបទពិសោធន៍ និងមេរៀនពីប្រវត្តិសាស្ត្របង្កើតអនាគតភ្លឺស្វាង

## ឯកឧត្តម ស៊ី ជីនភីង អគ្គលេខាធិការមជ្ឈិមបក្សកុម្មុយនិស្តចិន ប្រធានាធិបតីចិន និងជាប្រធានគណៈកម្មាធិការយោធាមជ្ឈិមបក្សកុម្មុយនិស្តចិន

## 以史为鉴 开创未来

中共中央总书记、国家主席、中央军委主席 习近平



(ដកស្រង់ចេញពីសុន្ទរកថារបស់ឯកឧត្តម ស៊ី ជីនភីង ដែលថ្លែងនៅក្នុងពិធីអបអរសាទរខួបលើកទី ១០០ ឆ្នាំនៃការបង្កើតគណបក្សកុម្មុយនិស្តចិន)

---

● ឆ្លងតាមរយៈកិច្ចខិតខំប្រឹងប្រែងពីប្រជាជនគ្រប់ជនជាតិនៅទូទាំងប្រទេសចិន យើងបានសម្រេចនូវគោលដៅអភិវឌ្ឍន៍មួយរយឆ្នាំទី ១ ហើយបានកសាងសង្គមធូរធារលើទឹកដីប្រទេសចិន និងបានដោះស្រាយបញ្ហាភាពក្រីក្រដែលមានសារៈសំខាន់ជាប្រវត្តិសាស្ត្រ ។

● មួយរយឆ្នាំកន្លងទៅនោះ កិច្ចខិតខំប្រឹងប្រែងពលីកម្ម និងការច្នៃប្រឌិតទាំងអស់ ដែលគណ-បក្សកុម្មុយនិស្តចិនរួមសាមគ្គីគ្នា និងដឹកនាំប្រជាជនចិនទៅចូលរួមទាំងនោះ មានប្រធានបទតែមួយគឺ សម្រេចនូវការស្តារប្រជាជាតិចិនឱ្យមានភាពរុងរឿងឡើងវិញ ។

● មូលដ្ឋានគ្រឹះរបស់គណបក្សកុម្មុយនិស្តចិនស្ថិតនៅក្នុងចំណោមប្រជាជន មានទំនាក់ទំនងឈាមជ័រទៅនឹងប្រជាជន និងមានកម្លាំងចេញពីប្រជាជន ។ ជារៀងរហូតមក គណបក្សកុម្មុយនិស្តចិនតំណាងឱ្យផលប្រយោជន៍គន្លឹះរបស់ប្រជាជន រួមសុខទុក្ខជាមួយប្រជាជន និងពឹងផ្អែកលើគ្នាជាមួយប្រជាជន ហើយគ្មានផលប្រយោជន៍ពិសេសអ្វីរបស់ខ្លួនទេ មិនដែលតំណាងឱ្យផលប្រយោជន៍របស់ក្រុមណាមួយ អំណាចណាមួយ ឬវណ្ណៈសិទ្ធិពិសេសណាមួយទេ ។



新华社 图

- បុព្វបុរសនៃគណបក្សកុម្មុយនិស្តចិនបានបង្កើតគណបក្សកុម្មុយនិស្តចិន ហើយបង្កើតជាស្មារតីដ៏អស្ចារ្យ ដែលប្រកាន់ខ្ជាប់នូវសច្ចធម៌ និងឧត្តមគតិ អនុវត្តតាមចិត្តដើមដំបូង និងភារកិច្ចរបស់ខ្លួន មិនខ្លាចពលីកម្ម ធ្វើការតស៊ូយ៉ាងអង់អាចក្លាហាន មានចិត្តស្មោះចំពោះគណបក្ស ហើយមិនឱ្យប្រជាជនអស់សង្ឃឹម ។ នេះគឺជាប្រភពដើមនៃស្មារតីរបស់គណបក្សកុម្មុយនិស្តចិន ។

- ធ្វើដំណើរតាមផ្លូវរបស់ខ្លួន គឺជាទ្រឹស្តីទាំងអស់ និងមូលដ្ឋានគ្រឹះនៃការអនុវត្តជាក់ស្តែងរបស់គណបក្ស ហើយក៏ជាបទពិសោធន៍ដែលប្រមូលបានតាមរយៈកិច្ចខិតខំប្រឹងប្រែងរយៈពេល ១០០ ឆ្នាំ ។

- យើងប្រកាន់ខ្ជាប់ និងអភិវឌ្ឍន៍សង្គមនិយមដែលមានលក្ខណៈពិសេសចិន ជំរុញការអភិវឌ្ឍអរិយធម៌សម្ភារៈ អរិយធម៌នយោបាយ អរិយធម៌ស្មារតី អរិយធម៌សង្គម និងអរិយធម៌អេកូឡូស៊ីឱ្យស៊ីសង្វាក់គ្នា បង្កើតមាគ៌ាថ្មី និងទំនើបរបស់ប្រទេសចិន ព្រមទាំងរូបភាពថ្មីនៃអរិយធម៌មនុស្សជាតិ ។

- សន្តិភាព ការរាប់អានគ្នា និងសុខដុមរមនាជាទស្សនទានដែលជនជាតិចិនបានខិតខំស្វែងរក និងបន្តផ្សព្វផ្សាយជាង ៥ ០០០ ឆ្នាំមកហើយ ។ ក្នុងឈាមជ័ររបស់ជនជាតិចិនគ្មានហ្សែនទៅឈ្លានពានប្រទេសគេ ឬអនុត្តរភាពទេ ។ គណបក្សកុម្មុយនិស្តចិនយកចិត្តទុកដាក់លើជោគវាសនា និងអនាគតរបស់មនុស្សជាតិ ពួតដៃគ្នាជាមួយគ្រប់កម្លាំងដែលមានលក្ខណៈឈានមុខលើពិភពលោក ។ ជារៀងរហូតមក ប្រទេសចិនជាស្ថាបនិកនៃសន្តិភាពពិភពលោក ជាអ្នករួមចំណែកក្នុងការអភិវឌ្ឍពិភពលោក និងជាអ្នកថែរក្សាសណ្តាប់ធ្នាប់សង្គម !

- គណបក្សកុម្មុយនិស្តចិននឹងបន្តរួមសហការគ្នាជាមួយប្រទេស និងប្រជាជនដែលស្រឡាញ់សន្តិភាព ផ្សព្វផ្សាយពីតម្លៃរួមរបស់មនុស្សជាតិទាំងមូល ដែលប្រកបទៅដោយសន្តិភាព ការអភិវឌ្ឍ សមភាព យុត្តិធម៌ ប្រជាធិបតេយ្យ និងសេរីភាព ប្រកាន់ខ្ជាប់នូវគោលការណ៍នៃការធ្វើកិច្ចសហប្រតិបត្តិការ មិនធ្វើការទប់ទល់នឹងគ្នា ឬការបិទខ្ទប់ទេ ប្រកាន់ខ្ជាប់នូវគោលការណ៍ឈ្នះ-ឈ្នះដែលផ្តល់ផលប្រយោជន៍ដល់គ្នាទៅវិញទៅមក មិនធ្វើការប្រកួតប្រជែងបែប “zero-sum game” ទេ ប្រឆាំងនឹងអនុត្តរភាព និងនយោបាយអំណាច ហើយជំរុញឱ្យប្រវត្តិសាស្ត្រឈានដំណើរទៅកាន់ទិសដៅអនាគតដ៏ភ្លឺស្វាង !

- ប្រជាជនចិនគោរពយុត្តិធម៌ មិនខ្លាចការធ្វើបាបបង្ខំពីគេ ចំណែកជនជាតិចិនជាជនជាតិដែលមានមោទនភាព និងជំនឿចិត្តដ៏រឹងមាំ ។ ប្រជាជនចិនមិនដែលធ្វើបាប គាបសង្កត់លើប្រជាជននៃប្រទេសផ្សេងទៀតទេ កាលពីមុនមិនដែលធ្វើបែបនេះ ឥឡូវមិនធ្វើ នៅពេលអនាគតក៏មិនអាចធ្វើអញ្ចឹងទេ ។

- គណបក្សយើងធ្លាប់ឆ្លងកាត់ការសាកល្បងគ្រប់ប្រភេទ ហើយមានកម្លាំងរស់រវើកគួរឱ្យកត់សម្គាល់ ។ មូលហេតុសំខាន់មួយគឺ យើងតែងតែប្រកាន់ខ្ជាប់នូវ




គោលការណ៍ដែលគ្រប់គ្រងគណបក្សដោយគណបក្ស គ្រប់គ្រងគណបក្សយ៉ាងតឹងរ៉ឹងដោយគ្រប់ជ្រុងជ្រោយ ដើម្បីទប់ទល់នឹងការសាកល្បង និងហានិភ័យផ្សេងៗ នៅគ្រប់ដំណាក់កាលក្នុងប្រវត្តិសាស្ត្រ ធានាឱ្យ គណបក្សយើងធ្វើដំណើរនាំមុខគេក្នុងដំណើរវិវឌ្ឍន៍ នៃប្រវត្តិសាស្ត្រ ដែលមានការផ្លាស់ប្តូរជាប់ជានិច្ច ហើយបានដើរតួនាទីជាកម្លាំងស្នូលរបស់ប្រជាជនទូទាំង ប្រទេសចិនក្នុងការដោះស្រាយបញ្ហាប្រឈម និងហានិភ័យ គ្រប់ប្រភេទទាំងក្នុង និងក្រៅប្រទេសចិន ។

● ហ៊ានធ្វើការតស៊ូ ហ៊ានយកឈ្នះ នេះគឺជា កម្លាំងស្មារតីដ៏ខ្លាំងក្លាដែលមិនអាចយកឈ្នះបានរបស់ គណបក្សកុម្មុយនិស្តចិន ។ ការសម្រេច“សុបិនចិន ដ៏អស្ចារ្យ”ត្រូវខិតខំឧស្សាហ៍ព្យាយាមដោយមិនចេះ នឿយហត់ ។

● អនាគតជារបស់យុវជន ក្តីសង្ឃឹមត្រូវផ្ញើតាម រយៈយុវជន ។ មួយរយឆ្នាំមុន យុវជនមួយក្រុមបាន លើកជ្រោងគប់ភ្លើងលទ្ធិម៉ាកស៊ីស ដើម្បីស្វែងរកផ្លូវ អភិវឌ្ឍន៍សម្រាប់ស្ថារប្រជាជាតិចិនឱ្យមានភាពរុងរឿង ឡើងវិញ ។ ក្នុងរយៈពេល ១០០ ឆ្នាំកន្លងទៅនោះ យុវជនចិនបានយកភាពយុវវ័យរបស់ខ្លួន ដើម្បីរួម ចំណែកក្នុងការអភិវឌ្ឍបុព្វហេតុបក្ស និងបុព្វហេតុ ប្រជាជន ហើយបានក្លាយជាកម្លាំងឈានមុខក្នុងការ ស្តារប្រជាជាតិចិនឱ្យមានភាពរុងរឿងឡើងវិញ ។

# ជំពូកទី ១
# 第一章

ឯកឧត្ដម ម៉ៅ សេទុង

毛泽东

ភារកិច្ចរបស់យើងគឺ ខិតខំលើកទឹកចិត្តប្រជាជន បង្កើនកម្លាំងប្រជាជនរួមសាមគ្គីគ្នាជាមួយគ្រប់កម្លាំងដែលអាចសាមគ្គីគ្នាបាននៅទូទាំងប្រទេស ខិតខំប្រឹងប្រែងដើម្បីបង្កើតប្រទេសចិនថ្មី ដែលមានឯករាជ្យភាព សេរីភាព ប្រជាធិបតេយ្យ រួបរួមជាតិ និងមានភាពធូរធារក្រោមការដឹកនាំពីគណបក្សរបស់យើង ។

我们的任务不是别的，就是放手发动群众，壮大人民力量，团结全国一切可能团结的力量，在我们党领导之下，为着打败日本侵略者，建设一个光明的新中国，建设一个独立的、自由的、民主的、统一的、富强的新中国而奋斗。

ឯកឧត្ដម តឹង ស្យៀវភីង

邓小平

សង្គមនិយម គឺត្រូវកម្ចាត់ភាពក្រីក្រ ។ ក្រីក្រមិនមែនជាសង្គមនិយមទេ ហើយក៏មិនមែនជាកុម្មុយនិស្តនិយមដែរ ។

社会主义要消灭贫穷。贫穷不是社会主义，更不是共产主义。



# ចិត្តដើមដំបូងមានភាពរឹងមាំដូចថ្មរឹង

# 初心如磐

**ឯកឧត្តម ហ្សាំង ជឺមីន**

**江泽民**

មូលហេតុដែលគណបក្សយើងអាចទទួលបានការគាំទ្រពីសំណាក់ប្រជាជនគឺ គណបក្សយើងតែងតែតំណាងឱ្យតម្រូវការអភិវឌ្ឍន៍នៃកម្លាំងផលិតកម្មជឿនលឿនរបស់ប្រទេសចិន តំណាងឱ្យទិសដៅឈានដំណើរទៅមុខនៃវប្បធម៌ជឿនលឿនរបស់ប្រទេសចិន តំណាងឱ្យផលប្រយោជន៍មូលដ្ឋានរបស់ប្រជាជនទូទាំងប្រទេស នៅគ្រប់ដំណាក់កាលនៃការធ្វើបដិវត្តន៍ ការសាងសង់ និងការធ្វើកំណែទម្រង់ ហើយខិតខំប្រឹងប្រែងមិនចេះនឿយហត់ដើម្បីផ្តល់ផលប្រយោជន៍គន្លឹះដល់ប្រទេសជាតិ និងប្រជាជន តាមរយៈការកំណត់គោលការណ៍ណែនាំ និងគោលនយោបាយត្រឹមត្រូវ ។

我们党所以赢得人民的拥护，是因为我们党在革命、建设、改革的各个历史时期，总是代表着中国先进社会生产力的发展要求，代表着中国先进文化的前进方向，代表着中国最广大人民的根本利益，并通过制定正确的路线方针政策，为实现国家和人民的根本利益而不懈奋斗。

**ឯកឧត្តម ហ៊ូ ជីនតាវ**

**胡锦涛**

ឱ្យតែជារឿងដែលសមស្របទៅនឹងទស្សនៈអភិវឌ្ឍន៍វិទ្យាសាស្ត្រ យើងក៏ត្រូវខិតខំធ្វើយ៉ាងពេញទំហឹង ចំណែករឿងដែលមិនស្របនឹងទស្សនៈនេះ យើងក៏ត្រូវធ្វើការកែតម្រូវដោយមិនមានការងាករេ ដើម្បីជំរុញឱ្យគ្រប់ការងារសម្រាប់ការអភិវឌ្ឍអាចឆ្លងកាត់ការត្រួតពិនិត្យពីប្រវត្តិសាស្ត្រ និងពីប្រជាជន ។

凡是符合科学发展观的事情就全力以赴地去做，不符合的就毫不迟疑地去改，真正使促进发展的各项工作都经得起历史和人民的检验。

**ឯកឧត្តម ស៊ី ជីនភីង**

**习近平**

ប្រជាជនគឺជាទឹកដីប្រទេស ។ បក្សកុម្មុយនិស្តចិនដណ្តើមទឹកដីប្រទេស ការពារទឹកដីប្រទេសគឺដើម្បីការពារទឹកចិត្តរបស់ប្រជាជន និងធ្វើឱ្យប្រជាជនអាចរស់នៅដោយមានភាពសុខដុមរមនា ។

人民就是江山，共产党打江山、守江山，守的是人民的心，为的是让人民过上好日子。

# ជំពូកទី ២
# 第二章

从 1921 年到 2021 年，中国共产党走过了整整一百年的历程。

争取民族独立、人民解放和实现国家富强、人民幸福，是中国共产党百年历史的主题。这也是用鲜血、汗水、泪水、勇气、智慧、力量写就的百年。我们回望 100 年历史中的几个篇章，探寻中国共产党如何穿越百年，带领中国走出迷雾，走向繁荣。

តាំងពីឆ្នាំ ១៩២១ ដល់ឆ្នាំ ២០២១ គណបក្សកុម្មុយនិស្តចិនបានឆ្លងកាត់ដំណើរវិវឌ្ឍន៍មួយសតវត្សរ៍ ។

ការស្វែងរកឯករាជ្យភាព រំដោះប្រជាជន ទទួលបានជីវភាពធូរធារ និងសុភមង្គលប្រជាជន គឺជាប្រធានបទសំខាន់ក្នុងប្រវត្តិ ១០០ ឆ្នាំនៃគណបក្សកុម្មុយនិស្តចិន ។ នេះក៏ជាប្រវត្តិសាស្ត្រមួយសតវត្សរ៍ដែលបង្កើតដោយញើសឈាម ទឹកភ្នែក ក្តីក្លាហាន ប្រាជ្ញា និងកម្លាំងដែរ ។ យើងរំលឹកឡើងវិញនូវដំណាក់កាលសំខាន់ៗក្នុងប្រវត្តិសាស្ត្រមួយសតវត្សរ៍នេះ ដើម្បីបង្ហាញជូនលោកអ្នកអំពីប្រវត្តិសាស្ត្រដែលគណបក្សកុម្មុយនិស្តចិនដឹកនាំប្រទេសចិនធ្វើដំណើរឆ្លងកាត់ក្តីលំបាកនិងដើរឆ្ពោះទៅកាន់ភាពរុងរឿង ។



# ផ្លូវអភិវឌ្ឍន៍រយឆ្នាំរបស់ប្រទេសចិន

# 百年波澜中国路

បើចង់ស្វែងយល់អំពីទីចាប់ផ្តើមនៃគណបក្សកុម្មុយនិស្តចិន ក៏ត្រូវស្វែងយល់ពីស្ថានភាពនៃប្រទេសចិននាឆ្នាំ ១៩២១ ។

១០ ឆ្នាំមុន គឺនៅឆ្នាំ ១៩១១ រាជវង្សសក្តិភូមិចុងក្រោយរបស់ចិន គឺរាជវង្សឆេង ត្រូវបានផ្តួចរំលំជាផ្លូវការ ។ ក្នុងអំឡុងពេលទាំង ៦៦ ឆ្នាំពីឆ្នាំ ១៨៤០ ដល់ឆ្នាំ ១៩០៥ នោះ ស្ទើរតែគ្រប់ប្រទេសអាណានិគមនិយមសុទ្ធតែចូលរួមការឈ្លានពានប្រទេសចិន ។ នៅឆ្នាំ ១៩១៩ ក្នុងនាមជាប្រទេសយកឈ្នះ ប្រទេសចិនបានចូលរួមក្នុងកិច្ចប្រជុំបារីស តែបែរជាត្រូវបានគេដណ្តើមទឹកដីក្នុងកិច្ចប្រជុំនេះ ។ ប្រទេសជប៉ុនបានបង្ខំយកខេត្តសានតុងនៃប្រទេសចិន ។ ក្រោយពីបានទទួលដំណឹងនេះ សិស្សនិស្សិតចិនមានការមួម៉ៅខឹងសម្បា ហើយធ្វើបាតុកម្ម និងកូដកម្ម ដែលត្រូវបានហៅថា "ចលនា ៤ ឧសភា"ក្នុងប្រវត្តិសាស្ត្រ ។ គេបានស្រែកក្នុងទុក្ខវេទនាបែបនេះថា "តើត្រូវធ្វើម៉េចទើបអាចសង្គ្រោះប្រទេសចិនបាន ? ធ្វើម៉េចអាចសង្គ្រោះប្រជាជនចិន ?"

ធ្វើយ៉ាងម៉េចអាចសង្គ្រោះប្រទេសចិនបាន ? តាំងពីឆ្នាំ ១៨៤០ មក មានជនជាតិចិនកាន់តែច្រើនចាប់ផ្តើមយល់ដឹងថា បញ្ហារបស់ចិនប្រហែលមកពីជនជាតិចិននៅមិនទាន់រកឃើញមាគ៌ាអភិវឌ្ឍន៍ដ៏ត្រឹមត្រូវ ។

នៅថ្ងៃទី ១ ខែ មករា ឆ្នាំ ១៩២១ អត្ថបទ "ភាពដើមនៃម៉ាកស៊ីស" ត្រូវបានចុះផ្សាយលើទស្សនាវដ្តី"យុវជនថ្មី" ដែលបានបកស្រាយអំពីខ្លឹមសារមូលដ្ឋាននៃប្រព័ន្ធសង្គមនិយមម៉ាកស៊ីស ដែលមានលក្ខណៈវិទ្យាសាស្ត្រ ។ តាំងពី "ចលនា ៤ ឧសភា"កើតឡើងរៀងមក យុវជនចិនជាច្រើនចាប់ផ្តើមគិតគូរពិចារណាអំពីការសង្គ្រោះប្រទេសចិន ក្រោមការណែនាំពីម៉ាក-ស៊ីសនិយម ។

នៅរដូវក្តៅឆ្នាំនោះ យុវជនចិន ១៣ នាក់ ដែលមកពីខេត្តក្រុងផ្សេងៗនៃប្រទេសចិន បានជួបជុំគ្នានៅក្នុងផ្ទះមួយដែលមានអាសយដ្ឋានផ្ទះលេខ ១០៦ តាមផ្លូវវ៉ាំងជីក្នុងតំបន់កាន់កាប់ដោយប្រទេសបារាំងនៅក្រុងសៀងហៃ ។ គេកំពុងរៀបចំបង្កើតឆាកសម្តែងដ៏ធំធេងមួយ ដែលជាទីចាប់ផ្តើមរបស់យុគសម័យអស្ចារ្យជាងគេនៃបដិវត្តន៍របស់ប្រទេសចិន ។



# ទីចាប់ផ្ដើមនៃដំណើរអភិវឌ្ឍន៍

# 征程的起点

1921 — 2021



**1921** 年 7 月 23 日，上海天气异常闷热。入夜，上海法租界望志路 106 号的一栋住宅亮起昏黄的灯光。屋内，31 岁的李汉俊正等着来此参加中共一大会议的各地代表。其余 12 名代表陆续来了，多是年轻模样，有穿长衫的，有穿西装的，有人留着八字胡须，也有人一脸稚气，他们的平均年龄只有 28 岁。

នៅខែ មិថុនា ឆ្នាំ ១៩២១ លោក ម៉ៅ សេទុង ដែលទើបមានអាយុ ២៨ ឆ្នាំ បានទទួលការជូនដំណឹងមួយនៅខេត្តហ៊ូណាន ដែលសំណូមពរឱ្យអង្គការគណបក្សជ្រើសរើសអ្នកតំណាង ២ នាក់ ដើម្បីទៅចូលរួមសមាជបក្សកុម្មុយនិស្តចិនលើកទី ១ នៅក្រុងសៀងហៃ ។

នៅថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ១៩២១ ក្រុងសៀងហៃមានអាកាសធាតុក្ដៅស្អុះស្អាប់ ។ ដល់ពេលយប់ ក្នុងផ្ទះមួយតាមផ្លូវវ៉ាំងជីក្នុងតំបន់កាន់កាប់ដោយប្រទេសបារាំងនៅក្រុងសៀងហៃ បញ្ចេញពន្លឺភ្លើងពណ៌លឿង ។ ក្នុងផ្ទះនោះ លោក លី ហានជួន ដែលមានអាយុ ៣១ ឆ្នាំកំពុងរង់ចាំការមកដល់របស់អ្នកតំណាងដែលមកពីខេត្តក្រុងផ្សេងៗ ។ អ្នកតំណាងទាំង ១៣ រូបបានមកដល់ជាបន្តបន្ទាប់ ។ ពួកគាត់ភាគច្រើនជាយុវជន ដែលមានអាយុជាមធ្យមតែ ២៨ ឆ្នាំ ។ អ្នកខ្លះពាក់អាវវែង អ្នកខ្លះពាក់អាវធំ ហើយមានពុករាងអក្សរ“八” អ្នកខ្លះទៀតមើលទៅមានមុខនៅក្មេង ។

យុវជនទាំង ១៣ នាក់បានពិគ្រោះពិភាក្សាគ្នាអំពីការងាររបស់ខ្លួន ព្រមទាំងគោលលំនាំគណបក្សកុម្មុយនិស្តចិន និងផែនការការងារនាពេលអនាគត ។ នៅពេលចូលប្រជុំ នគរបាលតំបន់កាន់កាប់ដោយបារាំងបានមកស្កាត់មិនឱ្យពួកគាត់ធ្វើកិច្ចប្រជុំ ដូច្នេះ ពួកគាត់បានជិះរទេះភ្លើងទៅក្រុងចាសៀង ដើម្បីបន្តធ្វើកិច្ចប្រជុំតទៅទៀតនៅលើទូកមួយ ។ អង្គប្រជុំបានពិព្រោះពិភាក្សា និងអនុម័ត“គោលលំនាំទី ១ នៃគណបក្សកុម្មុយនិស្តចិន” ។ ឯកសារដែលមាន ១៥ ប្រការ និងមានអក្សរតែ ៧០០ តួនេះ បានកំណត់ឱ្យបានច្បាស់លាស់នូវឈ្មោះបក្ស គោលដៅអភិវឌ្ឍន៍ និងគោលនយោបាយមូលដ្ឋាន ហើយបានលើកឡើងពីរបបអំពីការទទួលសមាជិកថ្មី ការបង្កើតអង្គភាពមូលដ្ឋាន និងមជ្ឈិមបក្សជាដើម ។ វាជាឯកសារផ្លូវការទី ១ របស់គណបក្សកុម្មុយនិស្តចិន ។

គណបក្សកុម្មុយនិស្តចិនបានចាប់បដិសន្ធិជាផ្លូវការនាខែ កក្កដា លើនាវា ។

ក្រោយពីកិច្ចប្រជុំនេះ អ្នកតំណាងបានត្រឡប់ទៅកន្លែងធ្វើការរៀងខ្លួន ចំណែកអង្គការគណបក្សកុម្មុយនិស្តចិនបានទទួលការរីកចម្រើនយ៉ាងឆាប់រហ័ស ហើយបានប្រមូលផ្តុំនូវកម្លាំងដើម្បីដឹកនាំចលនាកម្មករ ។ កាលនោះ គណបក្សកុម្មុយនិស្តចិនបានធ្វើកិច្ចសហប្រតិបត្តិការជាមួយគណបក្សកុកមិញតាង ដែលដឹកនាំដោយ

គណបក្សរបស់យើងត្រូវបានដាក់ឈ្មោះថា “គណបក្សកុម្មុយនិស្តចិន” ។

គណបក្សរបស់យើងទទួលស្គាល់របបគ្រប់គ្រងបែបសូវៀត ដើម្បីជំរុញឱ្យកម្មករ កសិករ និងទាហានរួមសាមគ្គីគ្នា ហើយចាត់ទុកការធ្វើបដិវត្តន៍សង្គមនិយមជាបំណងសំខាន់នៃគោលនយោបាយរបស់ខ្លួន ។

ដកស្រង់ចេញពី“គោលលំនាំទី ១ របស់គណបក្សកុម្មុយនិស្តចិន”

我们的党定名为“中国共产党”。

我们党承认苏维埃管理制度，要把工人、农民和士兵组织起来，并以社会革命为自己政策的主要目的。

——《中国共产党的第一个纲领》




លោក សុន យ៉ាត់សេន ដើម្បីប្រយុទ្ធប្រឆាំងនឹងកម្លាំងយោធិនពីភាគខាងត្បូងទៅខាងជើង ហើយជំរុញឱ្យសម្រេចនូវការបង្រួបបង្រួមប្រទេសចិនជាបន្តបន្ទាប់ ។

ប៉ុន្តែ នៅថ្ងៃទី ១២ ខែ មេសា ឆ្នាំ ១៩២៧ ពួកខាងស្តាំនៃគណបក្សកុកមិញតាងបានធ្វើរដ្ឋប្រហារនៅក្រុងសៀងហៃ ហើយចាប់សម្លាប់សមាជិកបក្សកុម្មុយនិស្តចិន និងពួកខាងឆ្វេងនៃបក្សកុកមិញតាង ។ លោក លី ហានជូន ដែលមានអាយុតែ ៣៧ ឆ្នាំ និងមនុស្សរាប់ម៉ឺននាក់ត្រូវបានចាប់សម្លាប់ ។ គណបក្សកុម្មុយនិស្តចិនដែលបានរងគ្រោះយ៉ាងធ្ងន់ធ្ងរនោះសម្រេចចិត្តនឹងធ្វើដំណើរតាមផ្លូវដែលដណ្តើមបានអំណាចរដ្ឋចិនតាមរយៈការធ្វើបដិវត្តន៍ដោយកម្លាំងប្រដាប់អាវុធ ។

នៅឆ្នាំ ១៩៤៩ សាធារណរដ្ឋប្រជាមានិតចិនត្រូវបានបង្កើតឡើងជាផ្លូវការ ។ អ្នកតំណាងច្រើនដែលធ្លាប់ចូលរួមសមាជបក្សកុម្មុយនិស្តចិនលើកទី ១ មានតែលោក ម៉ៅ សេទុង និងលោក តុង ពីអ៊ូ បានអញ្ជើញចូលរួមក្នុងពិធីបង្កើតប្រទេសចិនថ្មី ។ ក្នុងអំឡុងពេលពីឆ្នាំ ១៩២១ ដល់ឆ្នាំ ១៩៤៩ វីរជនដែលពលីជីវិតនិងបានត្រូវកត់ឈ្មោះមានជាង ៣,៧ លាននាក់ ។ គិតជាមធ្យម មានវីរជនជាង ៣៧០ នាក់បានពលីជីវិតក្នុងមួយថ្ងៃ ។

បច្ចុប្បន្ន គណបក្សកុម្មុយនិស្តចិនមានសមាជិកជាង ៩០ លាននាក់ ចំណែកវាសនារបស់ចិនក៏បានប្រែប្រួលជាខ្លាំងណាស់ដែរ ។ នៅថ្ងៃទី ១ ខែ កក្កដា ជារៀងរាល់ឆ្នាំ ប្រជាជនចិនតែងតែរំលឹកឡើងវិញនូវការចាប់កំណើត និងដំណើរល្អលាស់របស់បក្សកុម្មុយនិស្តចិន ដើម្បីរំលឹកវិញ្ញាណក្ខន្ធរបស់វីរជនដែលបានពលីជីវិតក្នុងគ្រាអាសន្នរបស់ប្រទេសចិន ។

# ទ័ពរបស់ប្រជាជន

# 人民的队伍




1921 — 2021

长征是一次唤醒中国民众的远征。这支队伍在最艰难的时刻也保持自己的本色，中国西部缺水严重，红军抵达甘肃会宁时，不肯碰百姓家里的窖水，跑去河边挑水用，战士们住在群众家里，每天给房东担水、打扫。部队离开会宁时，有 400 多名会宁人加入红军……

> គ្រប់ប្រតិបត្តិការត្រូវស្តាប់បញ្ជា មិនអាចយកអ្វីពីប្រជាជន ខ្ចីឥវ៉ាន់ត្រូវសងវិញ បង្ខូចរបស់ត្រូវសងសំណង មិនអាចធ្វើបាបឈ្លើយទេ ។
>
> ដកស្រង់ចេញពី“វិន័យសំខាន់ ៣ និងគោលការណ៍ ៨” របស់កងទ័ពរំដោះប្រជាជនចិន
>
> 一切行动听指挥，不拿群众一针一线，借东西要还，损坏东西要赔，不虐待俘虏 ......
>
> ——中国人民解放军“三大纪律八项注意”

នៅខែ តុលា ឆ្នាំ ១៩៣៦ យុទ្ធជនមួយក្រុមដែលមានរាងស្គម និងស្លៀកពាក់អាវរយ៉ៃ កំពុងចាប់ដៃ និងឱបគ្នាជាមួយយុទ្ធជនមួយក្រុមទៀត ដោយមានភាពរាក់ទាក់កក់ក្តៅ ។ អ្នកខ្លះពាក់ស្បែកជើងស្បែក ឬក៏គ្រាន់តែយកស្បែកគោរុំជើង ហើយចងខ្សែមួយ ។ ពួកគេហាក់ដូចជាជួបនឹងការលំបាកច្រើន តែបែរជាបង្ហាញនូវចិត្តម៉ឺងម៉ាត់ស្វិតស្វាញ ។

ក្រុមយុទ្ធជននេះត្រូវបង្កើតនៅ ១១ ឆ្នាំមុន ។ នៅថ្ងៃទី ១ ខែ សីហា ឆ្នាំ ១៩២៧ ប្រឈមនឹងការធ្វើរដ្ឋប្រហារ និងការចាប់សម្លាប់របស់កុកមិញតាង គណបក្សកុម្មុយនិស្តចិនបានដឹកនាំទ័ពបដិវត្តន៍ប្រជាជនមួយក្រុម ដើម្បីធ្វើការបះបោរនៅក្រុងណានឆាងនៃខេត្តជាំងស៊ី ដែលបានបើកទំព័រថ្មីនៃការធ្វើចម្បាំងប្រដាប់អាវុធ និងការបង្កើតកងទ័ពរបស់ខ្លួន ។ ជំនឿនយោបាយដ៏មោះមុតបានធ្វើឱ្យពួកគេមានលក្ខណៈខុសគ្នានឹងទ័ពផ្សេងៗក្នុងប្រវត្តិសាស្ត្រចិន ។ ពេលដំបូង ពួកគេមានវិន័យចំនួន ២ គឺ ត្រូវស្តាប់បញ្ជារបស់អ្នកដឹកនាំ និងមិនយកដំឡូងមួយពីមហាជន ។ វិន័យទាំងពីរនេះក៏បានជំរុញឱ្យទ័ពនេះមានលក្ខណៈចារិត និងព្រលឹងពិសេសរបស់ខ្លួន ។

នៅខែ តុលា ឆ្នាំ ១៩៣៤ ទ័ពមួយក្រុមនេះគឺកងទ័ពក្រហម បានចាប់ផ្តើមធ្វើ“មហាដំណើរ” ដែលពោរពេញទៅដោយក្តីលំបាក ។ ក្រោមការប៉ះពាល់ពីគំនិតខុសឆ្គងរបស់អ្នកដឹកនាំមួយចំនួន កងទ័ពក្រហមមិនអាចទប់ទល់នឹងការវាយលុកពីទ័ពកុកមិញតាងទេ ដូច្នេះ ពួកគេមានតែធ្វើដំណើរទៅកន្លែងផ្សេងដើម្បីគេចផុតពីការហ៊ុមព័ទ្ធរបស់បក្សកុកមិញតាង ។ នេះគឺជាដំណើរលំបាកមួយ ដែលកងទ័ពក្រហមបានធ្វើដំណើរប្រមាណ ១,២៥ ម៉ឺនគីឡូម៉ែត្រ និងធ្វើចម្បាំងជាង ៦០០ លើកក្នុងរយៈពេល ២ ឆ្នាំ ហើយបានឆ្លងទន្លេជិតមួយរយខ្សែ និងភ្នំព្រឹលជាង ២០ ខ្នងដែលមានកម្ពស់ជាង ៤ ០០០ ម៉ែត្រ ។

“មហាដំណើរ”ជាប្រតិបត្តិការមួយដែលធ្វើឱ្យប្រជាជនចិនភ្ញាក់ឡើង ។ ទ័ពនេះបានរក្សារចនាបថរបស់ខ្លួនក្នុងគ្រាអាសន្ន ។ ភាគខាងលិចនៃប្រទេសចិនជាតំបន់ខ្វះទឹក ។ នៅពេលកងទ័ពក្រហមមកដល់ស្រុកហួយនីងនៃខេត្តកាន់ស៊ូ ពួកគេមិនព្រមផឹកទឹកដែលស្តុកដោយមហារាស្ត្រទេ ហើយទៅរែកទឹកតាមមាត់ទន្លេជារៀងរាល់ថ្ងៃ ។ យុទ្ធជនកងទ័ពក្រហមស្នាក់នៅក្នុងផ្ទះអ្នកស្រុក ហើយរែកទឹកជូនម្ចាស់ផ្ទះ



និងជួយបោសសម្អាតបន្ទប់ជារៀងរាល់ថ្ងៃ ។ នៅពេលគេចាកចេញពីស្រុកហ្វួយនីង មានអ្នកស្រុកជាង ៤០០ នាក់បានចូលរួមកងទ័ពក្រហមដោយស្ម័គ្រចិត្ត ។

“មហាដំណើរ”ជាការធ្វើដំណើរមួយលើកដើម្បីស្វែងរកសច្ចធម៌ ។ អ្នកចូលរួមដែលបានទទួលជោគជ័យទាំងនោះសុទ្ធតែជាមនុស្សដែលមានឆន្ទៈមោះមុតបំផុត ។ នៅពេលដើរដល់ទីដៅចុងក្រោយ មនុស្សដែលនៅរស់ទាំងនោះមុខជាជឿជាក់យ៉ាងមុតមាំថា ខ្លួនគេអាចដើរដល់ទីដៅចុងក្រោយមិនខាន ។

នេះក៏ដូចទំនុកចម្រៀងនៃចម្រៀងកងទ័ពរំដោះប្រជាជនចិនថា យើងជាកូនចៅរបស់កម្មករ និងកសិករ យើងជាកម្លាំងប្រដាប់អាវុធរបស់ប្រជាជន ។ ទ័ពមួយក្រុមនេះសម្រុកទៅកាន់សមរភូមិនៃការប្រយុទ្ធប្រឆាំងនឹងការឈ្លានពានរបស់ប្រទេសជប៉ុន សមរភូមិនៃការរំដោះប្រជាជន និងតំបន់ព្រំដែនរបស់មាតុប្រទេស ។ នៅខែ ឧសភា ឆ្នាំ ១៩៤៩ កងទ័ពរំដោះប្រជាជនចិនបានវាយលុកចូលក្រុងសៀងហៃ ។ មានកាសែតខ្លះបានថតរូបឃើញនៅពេលព្រឹកព្រលឹម ហើយមានធ្លាក់ភ្លៀងទៀត ទាហានកងទ័ពរំដោះប្រជាជនចិនរាប់សែននាក់ដេកតាមផ្លូវ ហើយគ្មានអ្នកណាចូលផ្ទះរបស់ប្រជាជនទេ ។ ថ្ងៃនេះ ពួកគេកំពុងខិតខំការពារសន្តិសុខប្រទេសចិន ដោយបានបង្ហាញខ្លួននៅក្នុងការសង្គ្រោះបន្ទាន់គ្រោះមហន្តរាយ និងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ពីព្រោះគំនិត“បម្រើប្រយោជន៍ប្រជាជន”ត្រូវបានចាក់ឫសយ៉ាងស៊ីជម្រៅក្នុងហៃ្សនរបស់ពួកគេ ។ គ្រាប់ពូជនៃការជោគជ័យត្រូវបានបង្កប់ក្នុងក្រុមមួយនេះ តាំងពីរការបង្កើតរហូតមកដល់សព្វថ្ងៃនេះ ។

1921 — 2021

# ជនបទ  និងទីក្រុង

# 农村和城市



1949年3月23日，如今的河北省西柏坡发生了一件大事。这个往日宁静的小山村里车水马龙，11辆小汽车和10辆大卡车组成车队，载着毛泽东等中国共产党中央领导人离开西柏坡前往北平（即现在的北京市）。路途上，毛泽东说：“今天是进京赶考，希望考个好成绩。”

នៅថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៤៩ មានរឿងសំខាន់មួយកើតនៅភូមិស៊ីប៉ៃភ្ជនៃខេត្តហឺប៉ី ។ ក្នុងភូមិដ៏ស្ងាត់ជ្រងំនេះ មានរថយន្តតូច ១១ គ្រឿង និងរថយន្តធំ ១០ គ្រឿង ដឹកអ្នកដឹកនាំនៃគណបក្សកុម្មុយនិស្តចិន ដើម្បីធ្វើដំណើរទៅកាន់ទីក្រុងប៉េកាំង ។

នៅពេលធ្វើដំណើរតាមផ្លូវ លោក ម៉ៅ សេទុង បានមានប្រសាសន៍ថា ថ្ងៃនេះ យើងទៅចូល“ការប្រឡង”នៅរដ្ឋធានី ហើយសង្ឃឹមថានឹងអាចបាន“ពិន្ទុ”ល្អ ។ នៅក្នុងប្រទេសចិនសម័យបុរាណ អ្នកសិក្សារៀនសូត្រត្រូវទៅចូលការប្រឡងក្នុងរាជធានី ។ លោក ម៉ៅ សេទុង យល់ឃើញថា គណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនិស្តចិនចេញដំណើរពីភូមិស៊ីប៉ៃភ្ជទៅកាន់ក្រុងប៉េកាំង គឺជា“ការប្រឡង”ដ៏សំខាន់មួយលើក ។

កាលនោះ កងទ័ពរំដោះប្រជាជនចិនជាង ១ លាននាក់ប្រុងនឹងឆ្លងទន្លេយ៉ាងសេ ដែលបានបែងចែកប្រទេសចិនជាពីរផ្នែកនៅពេលនោះ ហើយនឹងរំដោះទឹកដីប្រទេសចិនទាំងមូលក្រៅពីកោះតៃវ៉ាន់ក្នុងរយៈពេល ២ ឆ្នាំខាងមុខ ។ ប៉ុន្តែ ៣ ឆ្នាំមុននេះ គណបក្សកុម្មុយនិស្តចិនស្ទើរតែមិនដែលកាន់កាប់ទីក្រុងធំណាមួយនៃប្រទេសចិននៅឡើយ ។

ការធ្វើបដិវត្តន៍របស់ប្រទេសចិនកំពុងដំណើរការយ៉ាងឆាប់រហ័ស ។ រឿងដែលសំខាន់ជាងគេគឺស្ថិតនៅក្នុងតំបន់ជនបទ ។ តែតំបន់ជនបទបែរជាត្រូវគេធ្វេសប្រហែសនៅគ្រប់ដំណាក់កាលតាំងពីសម័យបុរាណមក តែវាជាការប្រឡងសំខាន់លើកទី ១ លើឆាកជីវិតរបស់គណបក្សកុម្មុយនិស្តចិន ។

នៅឆ្នាំ ១៩៣៦ អ្នកកាសែតអាមេរិកឈ្មោះ Edgar Snow បានធ្វើដំណើរមកដល់យ៉ានអានដែលស្ថិតនៅភាគខាងលិចនៃប្រទេសចិន ។ កាលនោះ កងទ័ពក្រហមបានទទួលការជោគជ័យក្នុងការធ្វើ“មហាដំណើរ”រួចរាល់ និងបានចាក់ឫសនៅទីនេះហើយ ។ លោកបានមើលឃើញដោយផ្ទាល់ភ្នែកនូវទិដ្ឋភាពប្លែកៗក្នុងយ៉ានអាន ដែលពោរពេញទៅដោយកម្លាំងរស់រវើក និងឧត្តមគតិដ៏ខ្ពង់ខ្ពស់ ។ លោកបានសរសេរសៀវភៅ“ផ្កាយក្រហមចែងចាំងលើទឹកដីប្រទេសចិន” ដោយបានពិពណ៌នាអំពីបទសម្ភាសន៍ និងអ្វីៗដែល

ភាពរាក់ទាក់កក់ក្តៅ ក្តីសង្ឃឹមមិនងាករេ និងសុទិដ្ឋិនិយមបដិវត្តន៍គួរជាទីចាប់អារម្មណ៍របស់យុវជនរាប់ពាន់រាប់ម៉ឺននាក់(សមាជិកបក្សកុម្មុយនិស្តចិន) ហាក់ដូចជាភ្លើងឆេះយ៉ាងសន្ធោសន្ធៅ ត្រូវបង្កប់នៅក្នុងអ្វីៗទាំងអស់ ទោះជាប្រឈមនឹងកម្លាំងមនុស្ស ធម្មជាតិ អាទិទេព ឬមរណភាពក៏ដោយ ពួកគេមិនដែលសុំចុះចាញ់នៅឡើយ ។

ដកស្រង់ចេញពីសៀវភៅ“ផ្កាយក្រហមចែងចាំងលើទឹកដីប្រទេសចិន”របស់លោក Edgar Snow

千千万万年轻人（共产党人）的经久不衰的热情、始终如一的希望、令人惊诧的革命乐观情绪，像一把烈焰，贯穿着这一切，他们不论在人力面前、或者在大自然面前、上帝面前、死亡面前都绝不承认失败……

——埃德加·斯诺《红星照耀中国》



លោកបានមើលឃើញក្នុងប្រទេសចិន ។ លោកបានកត់ត្រាពីស្មារតីមោះមុតរបស់យុទ្ធជនវ័យក្មេង និងជំនឿចិត្តដ៏រឹងមាំរបស់កសិករចិន ។

មានអ្នកស្រុកខ្លះបានប្រាប់លោកថា “៣ ឆ្នាំមុន ប្អូនស្រីខ្ញុំអត់បាយហូបហើយស្លាប់ទៅហើយ ប៉ុន្តែ ក្រោយពីកងទ័ពក្រហមមកដល់ យើងមានស្បៀងគ្រប់គ្រាន់ហើយ ។” មេបញ្ជាការម្នាក់បាននិយាយថា ពេលយើងត្រូវបានហ៊ុមព័ទ្ធដោយសត្រូវ មិត្តកសិករបានជីកយកដំឡូងដែលគេបានលាក់នៅក្រោមដី ដើម្បីឱ្យយើងហូប ។ ក្រោយមកមានមនុស្សច្រើនបានចូលរួមទ័ពយើង ហើយសង្ឃឹមថាយើងនឹងអាចទទួលបានជ័យជម្នះ !

លោក Edgar Snow បានសរុបសេចក្តីថា មូលហេតុដែលធ្វើឱ្យគណបក្សកុម្មុយនិស្តចិនទទួលបានការគាំទ្រពីមហាជននៅតំបន់ភាគពាយ័ព្យប្រទេសចិនគឺ ការបែងចែកដីស្រែជាថ្មី លុបចោលការខ្ចីប្រាក់ដែលមានការប្រាក់កម្រិតខ្ពស់ លុបចោលពន្ធដារផ្សេងៗ និងកម្ចាត់វណ្ណៈសិទ្ធិពិសេស ។

ការកែប្រែប្រទេសចិនត្រូវធ្វើឡើងពីតំបន់ជនបទ ។ ទោះបីជាដើរដល់កន្លែងណាក៏ដោយ គណបក្សកុម្មុយនិស្តចិនក៏បាននាំយកវិធានការ និងទស្សនទានអំពីបដិវត្តន៍កសិករទៅដល់កន្លែងនោះ ។ នៅឆ្នាំ ១៩៣៧ ប្រទេសជប៉ុនចាប់ផ្តើមឈ្លានពានប្រទេសចិន ហើយដណ្តើមបានទឹកដីចិនជិតពាក់កណ្តាលក្នុងពេលដ៏ខ្លី ។ អាស្រ័យលើមូលដ្ឋានក្នុងតំបន់ជនបទគណបក្សកុម្មុយនិស្តចិនបានធ្វើការប្រយុទ្ធប្រឆាំងនឹងទ័ពជប៉ុនរយៈពេល ៨ ឆ្នាំ ។ នៅចុងឆ្នាំ ១៩៤៨ កងទ័ពរំដោះប្រជាជនចិនបានធ្វើចម្បាំងចុងក្រោយជាមួយបក្សកុកមិញតាង ហើយបានទទួលការគាំទ្រពីប្រជាកសិករជាងមួយលាននាក់ ។

នៅខែ មីនា ឆ្នាំ ១៩៤៩ មជ្ឈិមបក្សកុម្មុយនិស្តចិនបានផ្លាស់ទីតាំងធ្វើការទៅក្រុងប៉េកាំង ។ ការកែទម្រង់ និងគ្រប់គ្រងប្រទេសចិនដ៏ចាស់បុរាណ និងធំទូលាយនោះ គឺជាការប្រឡងថ្មីមួយលើកសម្រាប់គណបក្សនេះ ។

ដំណើរបដិវត្តន៍ ២៨ ឆ្នាំបានធ្វើឱ្យគណបក្សកុម្មុយនិស្តចិនប្រមូលនូវធនធានមនុស្ស និងក្តីប្រាថ្នាគ្រប់គ្រាន់ ។ ប្រជាជនទូទាំងប្រទេសចិនរួមគ្នាបោះជំហានទៅមុខ ដើម្បីកសាងប្រទេសចិនថ្មីមួយ ។

# ការបង្កើតប្រទេសចិនថ្មីមួយ

# 建设一个新中国




1921 — 2021

新中国的前 10 年就是一个破旧立新的时代，中国共产党人按照理想改造着这个国家。1950 年冬天开始，大规模的土地改革运动在中国各地展开，3 亿多无地或少地的农民分到了土地；1949 年底，中国召开了第一次全国教育工作会议，一场政府领导、群众参与的识字扫盲运动从政府机关开始，向中国各地迅速展开；新中国成立后，取消外国在华一切特权，在此基础上建立平等互利的外交关系，毛泽东形象地将其形容为“打扫干净屋子再请客”。

ក្នុងប្រវត្តិសាស្ត្រចិន ប្រទេសចិនត្រូវបានហៅឈ្មោះថា “ប្រទេសចិនថ្មី” តាំងពីសាធារណរដ្ឋប្រជាមានិតចិនត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៤៩ ។

តើប្រទេសចិនថ្មីមានលក្ខណៈថ្មីអ្វីខ្លះ ? ដើម្បីឆ្លើយសំណួរនេះ យើងត្រូវស្វែងយល់ពីប្រទេសចិនចាស់ជាមុន ។

នៅឆ្នាំ ១៩៤៩ ក្នុងចំណោមប្រជាជនចិន ៥៥០ លាននាក់ មានជាង ៤០០ លាននាក់ជាអនក្ខរជន ។ ដីស្រែភាគច្រើននៅប្រទេសចិនត្រូវបានកាន់កាប់ដោយម្ចាស់ដី ហើយមានទំនៀមទម្លាប់ចាស់ដូចជា“ម៉ៅអាពាហ៍ពិពាហ៍” និង“រុំជើង” ជាដើម មិនអាចបំបាត់បានទេ ។ តាំងពីឆ្នាំ ១៨៤០ មក ប្រទេសលោកខាងលិចនិងប្រទេសចិនបានចុះហត្ថលេខាលើ“សន្ធិសញ្ញាមិនស្មើភាពគ្នា”មួយចំនួនធំ ។

យើងត្រូវកែប្រែ និងលុបចោលស្ថានភាពចាស់បែបនេះ ។

នៅថ្ងៃទី ១ ខែ ឧសភា ឆ្នាំ ១៩៥០ ច្បាប់អាពាហ៍ពិពាហ៍នៃសាធារណរដ្ឋប្រជាមានតិចិន ដែលត្រូវបានលោក ម៉ៅ សេទុង វាយតម្លៃថាជាច្បាប់ដែលមានលក្ខណៈទូទៅគួរឱ្យកត់សម្គាល់បន្ទាប់ពីច្បាប់រដ្ឋធម្មនុញ្ញចិន ត្រូវបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការ ។ ច្បាប់នេះជាច្បាប់ទី ១ របស់ប្រទេសចិនថ្មី ។ ច្បាប់អាពាហ៍ពិពាហ៍បានចែងក្នុងមាត្រាទី ១ ថា “លុបចោលនូវរបបអាពាហ៍ពិពាហ៍ដែលម៉ៅអាពាហ៍ពិពាហ៍ដោយបង្ខំ គោរពបុរសមើលងាយស្ត្រី និងមិនគិតពីផលប្រយោជន៍របស់កូនទេ ។”

ច្បាប់អាពាហ៍ពិពាហ៍ដែលជាច្បាប់ទី ១ នៃប្រទេសចិនថ្មី បានកសាងមូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍដោយភាពសុខដុមរមនារបស់គ្រួសារ និងសង្គមចិន ចំណែកស្មារតីនីតិកម្មនៃច្បាប់នេះនៅតែមានឥទ្ធិពលខ្លាំងនាពេលបច្ចុប្បន្ន ។

រយៈពេល ១០ ឆ្នាំដំបូងនៃប្រទេសចិនថ្មី គឺជាយុគសម័យដែលលុបចោលទម្លាប់ចាស់គំរិល និងបង្កើតក្បួនថ្មី ។ គណបក្សកុម្មុយនិស្តចិនបានកែលម្អប្រទេសចិនតាមឧត្តមគតិរបស់ខ្លួន ។ ចាប់ពីរដូវរងាឆ្នាំ ១៩៥០ មក ចលនាកំណែទម្រង់ដីស្រែដែលមានទ្រង់ទ្រាយធំ បានចាប់ដំណើរការជាផ្លូវការនៅខេត្តក្រុងផ្សេងៗនៃប្រទេសចិន ។ ប្រជាកសិករជាង ៣០០ លាននាក់ដែលគ្មានដីស្រែ ឬមានដីស្រែតិចតួចនោះ ទទួលបានដីស្រែ ។ នៅចុងឆ្នាំ ១៩៤៩ ប្រទេសចិនបានរៀបចំ

រឿងអតីតកាលមានប្រវត្តិរាប់ពាន់ឆ្នាំមកហើយ កាលនោះ ស្ដេច វៃអ៊ូ ធ្លាប់តែងកំណាព្យនៅពេលធ្វើដំណើរឆ្លងកាត់ភ្នំជីស៊ី ។ ពេលនេះ បានចូលរដូវរំហើយទៀត តែសង្គមយើងបានប្រែមុខមាត់ទៅហើយ ។

ដកស្រង់ចេញពីកំណាព្យ “ឡាងថាវសា-ប៉ៃតៃហ៊ី”របស់លោក ម៉ៅ សេទុង

往事越千年，魏武挥鞭，东临碣石有遗篇。萧瑟秋风今又是，换了人间。

——毛泽东《浪淘沙·北戴河》



កិច្ចប្រជុំការងារអប់រំលើកទី ១ ។ តាំងពីពេលនោះមក ចលនាអក្ខរកម្មដែលដឹកនាំដោយរដ្ឋាភិបាលចិន និងមានការចូលរួមពីសំណាក់មហាជននោះ បានចាប់ផ្តើមដំណើរការនៅទូទាំងប្រទេសចិន ដោយបានទទួលសមិទ្ធផលច្រើនគួរឱ្យកត់សម្គាល់ ។ ក្រោយពីប្រទេសចិនថ្មីត្រូវបានបង្កើតឡើង សិទ្ធិពិសេសនៅប្រទេសចិនរបស់ប្រទេសផ្សេងៗត្រូវបានលុបចោលទាំងស្រុង ។ ឈរលើមូលដ្ឋាននេះ ប្រទេសចិនបានបង្កើតទំនាក់ទំនងការទូតស្មើភាពគ្នា និងផ្តល់ផលប្រយោជន៍ដល់គ្នា ដែលត្រូវបានលោក ម៉ៅ សេទុង វាយតម្លៃថា "បោសសម្អាតបន្ទប់សិន សឹមអញ្ជើញឱ្យភ្ញៀវមកលេង ។"

នេះប្រហែលជាបដិវត្តន៍សង្គមដែលមានទ្រង់ទ្រាយធំជាងគេ និងមានលក្ខណៈស៊ីជម្រៅបំផុតលើពិភពលោក ។ វាបានជ្រៀតចូលទៅក្នុងគ្រប់វិស័យនៃសង្គមចិន ។ នៅឆ្នាំ ១៩៥៦ ក្រោមការណែនាំពីមជ្ឈិមបក្សកុម្មុយនិស្តចិន ពោលគឺ "លើកទឹកចិត្តសមាជិកបក្សទាំងអស់ មានការចូលរួមពីសំណាក់ប្រជាជនគ្រប់គ្នា កម្ចាត់ជំងឺ Schistosomiasis" ។ ជំងឺ Schistosomiasis ដែលបានប៉ះពាល់ដល់សុខភាពប្រជាជនចិនជាង ២ ០០០ ឆ្នាំនោះ ត្រូវបានកម្ចាត់ទាំងស្រុងដោយចំណាយពេលត្រឹមតែ ២ ឆ្នាំប៉ុណ្ណោះ ។

នៅឆ្នាំ ១៩៣៥ សមាជិកបក្សកុម្មុយនិស្តចិនឈ្មោះ ហ្វាង ជឺមីន ធ្លាប់គិតប្រមៃពីអនាគតកាលរបស់ចិនក្នុងពន្ធនាគារមុននឹងលោកត្រូវគេសម្លាប់ ។ លោកបានពិពណ៌នាថា កាលនោះ ចម្រៀងសប្បាយរីករាយនឹងជំនួសទុក្ខវេទនា ស្នាមញញឹមនឹងជំនួសមុខយំសោក ជីវភាពធូរធារនឹងជំនួសភាពក្រីក្រ សុខភាពល្អនឹងជំនួសជំងឺ ក្តីប្រាថ្នានឹងជំនួសភាពល្ងង់ ក្តីស្រឡាញ់នឹងជំនួសគំនុំ ភាពសប្បាយនៃជីវិតរស់នឹងជំនួសការសោកស្តាយនៃការស្លាប់ សួនផ្កាដ៏ស្រស់ស្អាតនឹងជំនួសរហោស្ថានអាប់អួន !

ប្រទេសចិនថ្មីនៅថ្ងៃនេះ មានទិដ្ឋភាពដូចអ្វីដែលគួរបួងដោយបក្សកុម្មុយនិស្តចិន ។

1921 — 2021

# “ផលិតកម្មចិន”ចាប់ផ្ដើមពីទីនេះ

# “中国制造”从此开始



中国是一个传统的农业大国，1949 年以前的中国“一辆汽车 、一架飞机、一辆坦克、一辆拖拉机都不能造”，基础设施极为薄弱。理想与激情曾经支撑中国共产党人建立了一个新中国。如今，又引领他们踏上新的征程。

នៅថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ១៩៥៦ រថយន្តម៉ាក“រំដោះ”ដែលជារថយន្តទី ១ របស់ចិន បានត្រូវផលិតដោយជោគជ័យលើខ្សែសង្វាក់ផលិតកម្មថ្មីរបស់រោងចក្រផលិតរថយន្តលេខ ១ ក្រុងឆាងឈុន ។ នេះបានក្លាយជាព័ត៌មានសំខាន់ដែលប្រជាជនទូទាំងប្រទេសចិនអបអររួមគ្នា ។

ប្រទេសចិនជាប្រទេសកសិកម្មប្រពៃណីមួយ ។ មុននឹងឆ្នាំ ១៩៤៩ សូម្បីតែ រថយន្ត យន្តហោះ រថក្រោះ ឬត្រាក់ទ័រមួយគ្រឿង គឺមិនអាចផលិតបានទេ ។ កាលនោះ ហេដ្ឋារចនាសម្ព័ន្ធប្រទេសចិនមានភាពអន់ថយណាស់ ។ គណបក្សកុម្មុយនិស្តចិនដែលធ្លាប់សម្រេចនូវ“មហាដំណើរ”ដ៏ជោគជ័យ និងយកឈ្នះសត្រូវនោះ ក៏ចាប់ផ្តើមដឹកនាំប្រជាជនចិនដើម្បីធ្វើដំណើរតាមផ្លូវអភិវឌ្ឍន៍ថ្មីដោយឈរលើស្ថានភាពបែបនេះ ។

ការកសាងប្រទេសត្រូវការប្រេងកាត ។ កម្មករប្រេងកាតរាប់ម៉ឺននាក់បានជួបជុំគ្នានៅអណ្តូងប្រេងកាត តាឈីង ក្នុងខេត្តហីឡុងជាំង ។ កម្មករឈ្មោះ វ៉ាំង ជីនស៊ី លោតចូលក្នុងដីភក់ ដើម្បីកូរភក់ដោយប្រើខ្លួនកាយ ហើយបានត្រូវគេប្រសិទ្ធនាមថា “មនុស្សដែក” ។ ផ្លូវរថភ្លើងពីឈុងឈីងទៅឈឹងទូ ដែលត្រូវបានប្លង់ឪហែ្សននៅចុងសម័យឆេង គ្រាន់តែជាខ្សែគំនូសដាច់ៗមួយខ្សែលើផែនទីមុនពេលបង្កើតប្រទេសចិនថ្មី តែក្រោយពីប្រទេសចិនថ្មីត្រូវបានបង្កើតឡើង ផ្លូវរថភ្លើងនេះបានបើកការដ្ឋានសាងសង់ជាផ្លូវការនៅឆ្នាំ ១៩៥០ ហើយបានបញ្ចប់ការសាងសង់ជាស្ថាពរក្នុងរយៈពេលត្រឹមតែ ២ ឆ្នាំប៉ុណ្ណោះ ។

នៅឆ្នាំ ១៩៥៣ ប្រទេសចិនចាប់ផ្តើមអនុវត្ត“ផែនការអភិវឌ្ឍន៍ជាតិរយៈពេល ៥ ឆ្នាំ”ទី ១ ។ ផែនការអភិវឌ្ឍន៍ជាតិរយៈពេល ៥ ឆ្នាំគឺជាផែនការអភិវឌ្ឍន៍សម្រាប់ការអនុវត្តគម្រោងសាងសង់សំខាន់ និងទិដៅអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ដើម្បីកំណត់ទិសដៅ និងគោលដៅអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិរយៈពេលវែង ។ ការអភិវឌ្ឍឧស្សាហកម្មទ្រង់ទ្រាយធំ ដែលផ្តោតសំខាន់ទៅលើគម្រោងសាងសង់ចំនួន ១៦៦ បានចាប់ដំណើរការយ៉ាងពេញលេញ ។ ប៉ុន្មានឆ្នាំក្រោយ ប្រទេសចិនផលិតបានដែកអ៊ីណុកជាលើកទី ១ សាកល្បងយន្តហោះចម្បាំងប្រភេទ Jetfighter ទី ១ ដោយជោគជ័យ និងចាប់ផ្តើមសាងសង់ស្ពានឆ្លងទន្លេយ៉ាងសេទី ១ ។

យើងមិនគ្រាន់តែពូកែបំផ្លាញសង្គមចាស់មួយប៉ុណ្ណោះទេ ហើយក៏ពូកែកសាងពិភពថ្មីមួយដែរ ។

ប្រសាសន៍របស់លោក ម៉ៅ សេទុង

我们不但善于破坏一个旧世界，我们还将善于建设一个新世界。

——毛泽东




ថ្នាំ Penicillin ជាការច្នៃប្រឌិតអស្ចារ្យជាងគេមួយនៅសតវត្សរ៍ទី ២០ ។ ប៉ុន្តែ ប្រទេសលោកខាងលិចធ្លាប់ហាមមិនឱ្យដឹកជញ្ជូនថ្នាំដែលអាចសង្គ្រោះជីវិតមនុស្សនេះមកប្រទេសចិនទេ ។ នៅឆ្នាំ ១៩៤៩ ថ្នាំ Penicillin មួយដបដែលមានទម្ងន់ត្រឹមតែ ០,១២ ក្រាមនោះ មានតម្លៃស្មើនឹងលោហៈមាស ០,៩ ក្រាមនៅប្រទេសចិន ។ នៅឆ្នាំ ១៩៥៣ រោងចក្រផលិតថ្នាំហ្វូប៉េ ប្រទេសចិនចាប់ផ្តើមអនុវត្តជាបន្ទាន់នូវគម្រោងសិក្សាស្រាវជ្រាវអំពីថ្នាំ Penicillin ដោយបានទទួលការគាំទ្រពីអ្នកបច្ចេកទេសមកពីគ្រប់តំបន់ ។ នៅថ្ងៃទី ៣ ខែ មិថុនា ឆ្នាំ ១៩៥៨ ថ្នាំ Penicillin ទី ១ របស់ប្រទេសចិនត្រូវផលិតដោយជោគជ័យ ដែលបានធ្វើឱ្យថ្នាំ Penicillin ដែលធ្លាប់មានតម្លៃខ្ពស់ជាងមាសទៅទៀតនោះ ចុះថ្លៃដល់តែប៉ុន្មានកាក់មួយដប ។

នៅសម័យនោះ មានជនជាតិចិនច្រើនរាប់មិនអស់ដែលមានជំនឿ និងទំនុកចិត្តដូចគ្នា ចូលរួមការអភិវឌ្ឍបុព្វហេតុគ្រប់វិស័យក្នុងសង្គមចិន ។ ក្រោយពីបានអនុវត្ត“ផែនការអភិវឌ្ឍន៍ជាតិរយៈពេល ៥ ឆ្នាំ”ទី ១ ប្រទេសចិនបានកំណត់ផែនការអភិវឌ្ឍន៍ជាតិរៀងរាល់ ៥ ឆ្នាំ ចំណែកការកំណត់និងរៀបរៀងផែនការអភិវឌ្ឍន៍ជាតិនេះ បានក្លាយទៅជាផ្នែកដ៏សំខាន់មួយនៃប្រព័ន្ធអភិបាលកិច្ចរបស់ប្រទេសចិន ។

ថ្ងៃនេះ ប្រទេសចិនបានបង្កើតប្រព័ន្ធឧស្សាហកម្មទំនើបដែលមានលក្ខណៈពេញលេញ ។ ទ្រង់ទ្រាយឧស្សាហកម្មរបស់ចិនបានជាប់លំដាប់លេខ ១ លើពិភពលោក ។ “ផលិតកម្មចិន”មិនគ្រាន់តែបានកែប្រែជីវភាពរស់នៅរបស់ជនជាតិចិនប៉ុណ្ណោះទេ ថែមទាំងអាចបម្រើប្រយោជន៍របស់ប្រជាជនស្ទើរគ្រប់ប្រទេសលើពិភពលោកទៀតផង ។

# តើសច្ចធម៌គឺអ្វី ?

# 真理是什么？




1921 — 2021

1978 年 12 月，中国共产党第十一届中央委员会第三次全体会议在北京举行。当时的中国最高领导人邓小平在会议闭幕式上作了题为《解放思想，实事求是，团结一致向前看》的讲话。此次会议拉开了中国改革开放的大幕，中国社会压抑的巨大力量即将爆发出来。

តើអ្វីជាផ្លូវ ? ផ្លូវត្រូវបង្កើតឡើងតាមរយៈការធ្វើដំណើរនៅកន្លែងគ្មានផ្លូវ និងត្រួសត្រាយតាមរយៈការពុះពារឧបសគ្គគ្រប់ប្រភេទ ។

អ្នកនិពន្ធល្បីឈ្មោះ លូ ស៊ីន

什么是路？就是从没路的地方践踏出来的，从只有荆棘的地方开辟出来的。

——著名作家 鲁迅

នៅថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៧៨ អត្ថបទដែលមានចំណងជើងថា“ការអនុវត្តជាក់ស្តែងគឺជាស្តង់ដារតែមួយគត់សម្រាប់សាកល្បងសច្ចធម៌” ត្រូវបានចុះផ្សាយលើទស្សនាវដ្តី“ចលនាភាពទ្រឹស្តី”ដែលជាទស្សនាវដ្តីផ្ទៃក្នុងនៃសាលាមជ្ឈិមបក្ស-កុម្មុយនិស្តចិន ។ នៅថ្ងៃទី ១១ ខែ ឧសភា ទីភ្នាក់ងារព័ត៌មានស៊ីនហួចិនបានចុះផ្សាយអត្ថបទនេះនៅទូទាំងប្រទេសចិន ។

អត្ថបទ“ការអនុវត្តជាក់ស្តែងគឺជាស្តង់ដារតែមួយគត់សម្រាប់សាកល្បងសច្ចធម៌”នេះបានលើកឡើងថា ស្តង់ដារតែមួយគត់សម្រាប់ពិនិត្យសច្ចធម៌គឺការអនុវត្តជាក់ស្តែង ។ ក្រោយមក ការពិគ្រោះពិភាក្សាអំពីស្តង់ដារពិនិត្យសច្ចធម៌បានកើតឡើងនៅទូទាំងប្រទេសចិន ដោយបានបង្កើតជាជំនោរសម្រាប់រំដោះស្មារតី ។

នៅខែ ធ្នូ ឆ្នាំ ១៩៧៨ កិច្ចប្រជុំពេញអង្គលើកទី ៣ នៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនិស្តចិនអាណត្តិទី ១១ បានរៀបចំនៅក្រុងប៉េកាំង ។ លោក តឹង សៀវភីង អ្នកដឹកនាំកំពូលនៃប្រទេសចិន បានថ្លែងសុន្ទរកថា“រំដោះស្មារតី អនុវត្តតាមស្ថានភាពជាក់ស្តែង រួមសាមគ្គីគ្នាដើម្បីធ្វើដំណើរទៅមុខ”ក្នុងពិធីបិទសម័យប្រជុំ ។ កិច្ចប្រជុំនេះបានបើកទំព័រថ្មីនៃការអនុវត្តគោលនយោបាយកែទម្រង់ និងបើកចំហរបស់ប្រទេសចិន ។

តើអ្វីជាសង្គមនិយមពិតប្រាកដ ? លោក តឹង សៀវភីង បានឆ្លើយថា ភាពក្រីក្រមិនមែនសង្គមនិយមទេ !

លោក យ៉ាន ជីនឆាង រស់នៅក្នុងភូមិសៀវកាង ស្រុកហ្វឹងយ៉ាង ខេត្តអានហ្វួយ ។ លោកមានអាយុ ៧៨ ឆ្នាំ ហើយមានចៅទួតហើយ ។ លោកតែងតែនឹកឃើញយប់រងាមួយនៅពេលជាង ៤០ ឆ្នាំមុន ដែលលោក និងសហការី ១៧ នាក់ទៀតធ្លាប់ផ្ដិតមេដៃក្នុងកិច្ចព្រមព្រៀងមួយ ដែលអាចធ្វើឱ្យគេជាប់គុក ។

លោកបានប្រាប់អ្នកកាសែតថា យើងបានយកដីស្រែចែកជូនគ្រួសារនីមួយៗ ។ គ្រួសារដែលទទួលបានដីស្រែក៏ត្រូវស៊ីញ៉េលើកិច្ចព្រមព្រៀងស្តីពីការសុំឱ្យគេថែទាំកូនរបស់ខ្លួន ។ បើយកដីស្រែ ត្រូវធានាឱ្យប្រគល់ស្បៀងជូនរដ្ឋាភិបាលតាមចំនួនកំណត់ ហើយលែងអាចស្នើសុំប្រាក់ ឬស្បៀងអាហារពីរដ្ឋទៀត ។ បើធ្វើអត់កើត



កម្មាភិបាលប្រចាំភូមិយើងសុខចិត្តជាប់គុក ឬត្រូវគេកាប់សម្លាប់ចោល ចំណែកសមាជិកនៃសហករណ៍យើងនឹងជួយថែទាំកូនយើងរហូតដល់អាយុ ១៨ ឆ្នាំ ។

បច្ចុប្បន្ន កិច្ចព្រមព្រៀងសម្ងាត់នេះបានក្លាយជានិមិត្តរូបនៃការធ្វើកំណែទម្រង់របស់ប្រទេសចិន ។ តាមពិត គ្មានអ្នកណាជាប់គុក ឬត្រូវគេកាប់សម្លាប់ទេ ។ រដ្ឋាភិបាលចិនបានយកដីស្រែសមូហភាពចែកជូនកសិករ ដែលបានលើកទឹកចិត្តឱ្យកសិករធ្វើស្រែចំការ ។ នៅឆ្នាំដដែលនោះ ភូមិសៀវកាងប្រមូលបានកសិផលដ៏ច្រើន ចំណែកកំណែទម្រង់ជនបទក៏ត្រូវបានផ្សព្វផ្សាយទៅដល់គ្រប់តំបន់នៃប្រទេសចិន តាំងពីពេលនោះមក ។

នៅខែ តុលា ឆ្នាំ ១៩៨៤ គណបក្សកុម្មុយនិស្តចិនបានចាត់ទុកការធ្វើកំណែទម្រង់ និងបើកចំហជាគោលនយោបាយមូលដ្ឋាន ។ កំណែទម្រង់ និងបើកចំហរបស់ចិនជាព្រឹត្តិការណ៍សេដ្ឋកិច្ចសំខាន់ជាងគេលើពិភពលោកនៅសតវត្សរ៍ទី ២០ ។ ទន្ទឹមនឹងការធ្វើកំណែទម្រង់សេដ្ឋកិច្ច ទាក់ទាញទុនវិនិយោគបរទេស និងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ប្រទេសចិនដែលត្រូវបានសន្មតជា"រោងចក្រពិភពលោក"បានចាប់ដំណើរការអភិវឌ្ឍន៍ជាផ្លូវការ និងបានជំរុញឱ្យសេដ្ឋកិច្ចចិនឈានចូលទៅក្នុងដំណាក់កាលដែលមានល្បឿនកំណើនយ៉ាងលឿន ។

នៅឆ្នាំ ១៩៨៧ លោក យឹន ជឹងហ្វី ដែលមានអាយុ ៤៣ ឆ្នាំ បានធ្វើដំណើរមកដល់ក្រុងសិនជិន ដែលជាសមរភូមិនៃការធ្វើកំណែទម្រង់ និងបើកចំហរបស់ប្រទេសចិន ។ ក្នុងឱកាសថៃដន្យមួយ មិត្តភក្តិរបស់លោកសុំឱ្យលោកជួយលក់គ្រឿងអេឡិចត្រូនិចខ្លះ ដូច្នេះ លោកបានយកដើមទុន ២,៤ ម៉ឺនយាន់ទៅចុះបញ្ជីពាណិជ្ជកម្ម ដើម្បីបង្កើតក្រុមហ៊ុន HUAWEI នៅក្រុងសិនជិន ។ ក្រុមហ៊ុន HUAWEI បានធ្វើអាជីវកម្មពីការនាំចូលគ្រឿងអេឡិចត្រូនិចដល់ការផលិតបរិក្ខារ និងការសិក្សាស្រាវជ្រាវ ហើយបានពង្រីកអាជីវកម្មតាមទីផ្សារអន្តរជាតិ ។ បច្ចុប្បន្ន ក្រុមហ៊ុន HUAWEI បានក្លាយជាសហគ្រាសផលិតបរិក្ខារទូរគមនាគមន៍ធំជាងគេមួយលើពិភពលោក ។

ធ្វើដំណើរតាមផ្លូវរបស់ខ្លួន ដើម្បីកសាងសង្គមនិយមដែលមានលក្ខណៈពិសេសរបស់ប្រទេសចិន ។ អ្នកបន្តវេននៃគណបក្សកុម្មុយនិស្តចិនបាន និងកំពុងសាកល្បង និងស្វែងរកផ្លូវអនុវត្តជាក់ស្តែងរបស់ប្រទេសចិន ដើម្បីពិនិត្យនិងពង្រឹងអត្ថន័យនៃសច្ចធម៌សង្គមនិយម ។

1921 — 2021

# ដើរឆ្ពោះទៅកាន់យុគសម័យថ្មី

# 走向新时代



2012年，经过近 70 年的建设和近 40 年的改革开放，中国已经成为世界第二大经济体，中国人的生活有了巨大的变化。这一年召开的中国共产党第十八次全国代表大会上，中国共产党提出要全面建成小康社会。

ជាង ២ ០០០ ឆ្នាំមុន ក្នុងសៀវភៅ“គម្ពីរកំណាព្យ”ដែលជាសៀវភៅបណ្ដុំកំណាព្យមុនគេបង្អស់របស់ប្រទេសចិន បានសរសេរថា មហារាស្ត្រហត់នឿយខ្លាំងពេក ត្រូវសម្រាកបន្តិចហើយ ។ ក្នុងប្រវត្តិសាស្ត្រ ៥ ០០០ ឆ្នាំរបស់ចិន មានភាពច្របូកច្របល់ច្រើនជាងសុខសន្តិភាព ។ ការអត់ឃ្លានត្រូវបានចាក់ឫសយ៉ាងស៊ីជម្រៅក្នុងការចងចាំរបស់ជនជាតិចិន ។ ជីវភាពធូរធារហាក់ដូចជាក្ដីសុបិនមួយដែលមិនអាចសម្រេចបានទេ ។

នៅឆ្នាំ ២០១២ ក្រោយពីបានធ្វើការអភិវឌ្ឍប្រទេសរយៈពេលជិត ៧០ ឆ្នាំ និងការធ្វើកំណែទម្រង់ និងបើកចំហជិត ៤០ ឆ្នាំ ប្រទេសចិនបានក្លាយជាសេដ្ឋកិច្ចធំទី ២ លើពិភពលោក ។ ការរស់នៅរបស់ប្រជាជនចិនបានប្រែមុខមាត់យ៉ាងខ្លាំង ។ ក្នុងសមាជបក្សកុម្មុយនិស្តចិនលើកទី ១៨ ដែលរៀបចំនៅឆ្នាំនោះ គណបក្សកុម្មុយនិស្តចិនបានលើកឡើងថា នឹងកសាងសង្គមធូរធារគ្រប់ជ្រុងជ្រោយ ។

កាលនោះ តាមទស្សនៈរបស់បក្សកុម្មុយនិស្តចិន ភាពធូរធារមិនគ្រាន់តែជា“ភាពសុខដុមរមនារបស់ប្រជាជន”ប៉ុណ្ណោះទេ វាមានពាក់ព័ន្ធនឹងគ្រប់វិស័យក្នុងសង្គម រួមមានសេដ្ឋកិច្ច នយោបាយ វប្បធម៌ សង្គមកិច្ច និងអេកូឡូស៊ីជាដើម ។ ក្នុងចំណោមនោះ ការកាត់បន្ថយភាពក្រីក្រដោយតម្រង់ទិសបានធ្វើឱ្យជនជាតិចិនចាប់អារម្មណ៍ជាងគេ ។

នៅលើទឹកដីដ៏ធំទូលាយរបស់ប្រទេសចិន ភាពក្រីក្រគឺជាបញ្ហាស្មុគស្មាញជាយូរមកហើយ ។ គណបក្សកុម្មុយនិស្តចិនបានចាត់ទុកការកាត់បន្ថយភាពក្រីក្រជាការងារមូលដ្ឋាននៃការកសាងសង្គមធូរធារ ហើយបានលើកទឹកចិត្តឱ្យគ្រប់កម្លាំងក្នុងសង្គម និងបានចាត់បញ្ជូនសមាជិកបក្សកុម្មុយនិស្តចិនរាប់លាននាក់ទៅធ្វើការតាមតំបន់ជនបទ ។

ធ្វើការប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រដូចធ្វើចម្បាំងជាមួយសត្រូវ ។ សមាជិកបក្សកុម្មុយនិស្តចិនក្នុងយុគសម័យថ្មីបានបង្ហាញពីកម្លាំង និងក្ដីក្លាហានដែលមិនចាញ់បុព្វបុរសរបស់ពួកគេ ។ យប់ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៩ លោកស្រី ហួង វិនសៀវ កម្មាភិបាលកាត់បន្ថយភាពក្រីក្រ ដែលមានអាយុ ៣០ ឆ្នាំ បរឡានទៅធ្វើការនៅពេលធ្លាក់ភ្លៀងព្យុះ ហើយបានជួបនឹងទឹកជំនន់តាមផ្លូវ និងបាន

ចិត្តដើមដំបូង និងភារកិច្ចរបស់សមាជិកបក្សកុម្មុយនិស្តចិនគឺ ស្វែងរកសុភមង្គលសម្រាប់ប្រជាជនចិន និងស្ដារប្រជាជាតិចិនឱ្យមានភាពរុងរឿងឡើងវិញ ។ ចិត្តដើមដំបូង និងភារកិច្ចនេះ គឺជាកម្លាំងចលករគន្លឹះដែលជំរុញឱ្យសមាជិកបក្សកុម្មុយនិស្តចិនឈានដំណើរទៅមុខឥតឈប់ឈរ ។

ប្រសាសន៍របស់ឯកឧត្តម ស៊ី ជីនភីង

中国共产党人的初心和使命，就是为中国人民谋幸福，为中华民族谋复兴。这个初心和使命是激励中国共产党人不断前进的根本动力。

——习近平



ពលីជីវិតនៅក្មេងរបស់លោកស្រី ។ ក្នុងដំណើរការកាត់បន្ថយភាពក្រីក្ររយៈពេល ៨ ឆ្នាំ មានជាង ១ ៨០០ នាក់បានពលីជីវិតរបស់ខ្លួន ។ នៅឆ្នាំ ២០២០ គណបក្សកុម្មុយនិស្តចិនបានប្រកាសពីការទទួលជោគជ័យគ្រប់ជ្រុងជ្រោយក្នុងយុទ្ធនាការកាត់បន្ថយភាពក្រីក្រ ហើយមានប្រជាជនចិនជិត ១០០ លាននាក់បានរួចខ្លួនផុតពីភាពក្រីក្រ តាមស្តង់ដារចំណូល និងសំណូមពរអំពីការហូបចុក ការអប់រំ សុខាភិបាលមូលដ្ឋាន និងលំនៅដ្ឋានសម្រាប់វាយតម្លៃចំពោះភាពក្រីក្រនាពេលបច្ចុប្បន្ន ។

ក្រៅពីការកសាងសង្គមធូរធារគ្រប់ជ្រុងជ្រោយ នៅមានវិធានការសំខាន់មួយចំនួនទៀត ដូចជា “ធ្វើឱ្យស៊ីជម្រៅនូវកំណែទម្រង់ដោយគ្រប់ជ្រុងជ្រោយសម្រាប់ធ្វើទំនើបភាវូបនីយកម្មនៃប្រព័ន្ធអភិបាលកិច្ច និងសមត្ថភាពគ្រប់គ្រង “ការធ្វើឱ្យមាននីតិរដ្ឋដោយគ្រប់ជ្រុងជ្រោយសម្រាប់លើកកម្ពស់កម្រិតប្រជាធិបតេយ្យ និងនីតិកម្មលើវិស័យនយោបាយ សេដ្ឋកិច្ច វប្បធម៌ និងសង្គមជាដើម “ការគ្រប់គ្រងគណបក្សយ៉ាងតឹងរ៉ឹង”សម្រាប់ពង្រឹងការគ្រប់គ្រង និងការកសាងគណបក្ស និងដាក់ទណ្ឌកម្មលើអំពើពុករលួយ ។ ល ។

អាស្រ័យលើ“ចំណុចពេញលេញទាំង ៤” គណបក្សកុម្មុយនិស្តចិនចាប់ផ្តើមកសាងក្របខ័ណ្ឌរបបអំពីប្រព័ន្ធសង្គមនិយមដែលមានលក្ខណៈពិសេសចិនក្នុងយុគសម័យថ្មី ។

វិបត្តិគឺជាកន្លែងសាកល្បងរបបល្អជាងគេ ។ ក្នុងឱកាសជិតដល់ខួបលើកទី ១០០ ឆ្នាំនៃការបង្កើតគណបក្សកុម្មុយនិស្តចិន ជំងឺកូវីដ-១៩ បានផ្ទុះឡើងនៅឆ្នាំ ២០២០ ដែលជាការសាកល្បងសំខាន់មួយសម្រាប់គណបក្សកុម្មុយនិស្តចិន ។

នៅថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០២០ ទីក្រុងអ៊ូហានត្រូវបានបិទខ្ទប់ ។ គ្រូពេទ្យរាប់សែននាក់ដែលមកពីខេត្តក្រុងផ្សេងៗនៃប្រទេសចិនបានធ្វើដំណើរទៅក្រុងអ៊ូហាន ដើម្បីចូលរួមការប្រយុទ្ធប្រឆាំងនឹងជំងឺឆ្លងនៅទីនោះ ។ មន្ទីរពេទ្យភ្នំហ្ហូស៊ីន និងមន្ទីរពេទ្យភ្នំឡីស៊ីនត្រូវបានសាងសង់រួចរាល់




ដោយចំណាយពេលតែជាង ១០ ថ្ងៃប៉ុណ្ណោះ ។ ក្រៅពីនេះ មន្ទីរពេទ្យបណ្ដោះអាសន្នចំនួន ១៦ ត្រូវបានសង់ឡើងក្នុងពេលដ៏ខ្លី ហើយមានកន្លែងធ្វើចត្តាឡីស័កចំនួនជាង ៦០០ កន្លែង ។ អង្គភាពប្រចាំមូលដ្ឋាននៃគណបក្សកុម្មុយនិស្តចិនចំនួនជាង ៤,៦ លាន ខិតខំធ្វើការលើគ្រប់វិស័យ ហើយមានអ្នកធ្វើការនៅសហគមន៍ជាង ៤ លាននាក់ប្រចាំការនៅក្នុងសហគមន៍ជាង ៦៥ ម៉ឺននៅទូទាំងប្រទេសចិន ។ រយៈពេល ២ ខែនោះ ករណីឆ្លងជំងឺកូវីដ-១៩ ក្នុងមួយថ្ងៃជាមធ្យមនៅប្រទេសចិន ស្ថិតនៅក្រោមកម្រិត ១០ នាក់ ។ នៅថ្ងៃទី ៨ ខែ មេសា ក្រុងអ៊ូហានប្រកាសបញ្ចប់ការបិទខ្ទប់ជាផ្លូវការ ។

សង្គ្រោះ និងអភិវឌ្ឍន៍ប្រទេសចិនអាស្រ័យលើប្រព័ន្ធសង្គមនិយម អភិវឌ្ឍន៍ប្រព័ន្ធសង្គមនិយមអាស្រ័យលើការអនុវត្តជាក់ស្ដែងនៃប្រទេសចិន នេះគឺជាដំណើរវិវឌ្ឍន៍ ១០០ ឆ្នាំរបស់គណបក្សកុម្មុយនិស្តចិន ។

នៅឆ្នាំ ២០១៧ របាយការណ៍នៃសមាជបក្សកុម្មុយនិស្តចិនលើកទី ១៩ បានចែងថា “ប្រព័ន្ធសង្គមនិយមដែលមានលក្ខណៈពិសេសចិនបានឈានចូលក្នុងយុគសម័យថ្មី” ។ គណបក្សកុម្មុយនិស្តចិននឹងដឹកនាំប្រជាជនទូទាំងប្រទេសចិនកសាងប្រទេសសង្គមនិយមទំនើបភាវូបនីយកម្ម ។ ថ្ងៃនេះ ពន្លឺរស្មីនៃសង្គមនិយមកំពុងចែងចាំងលើខ្លួនកាយរបស់អ្នកព្យាយាមធ្វើការ និងស្នាមញញឹមរបស់កុមារាកុមារី ។ នេះគឺជាប្រទេសចិនដែលធ្លាប់មានមនុស្សច្រើនរាប់មិនអស់ខិតខំឧស្សាហ៍ព្យាយាម និងពលីជីវិតរបស់ខ្លួន ដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍ប្រទេស ។

---

រូបភាពដោយកម្មវិធីកាសែតយូណាន ក្រុមរូបភាព“អាយុកាល ១០០ ឆ្នាំ បន្តចិត្តដើមដំបូង”របស់មហាវិទ្យាល័យសិល្បៈ និងឌីហ្សៃននៃសាកលវិទ្យាល័យយូណាន

本章节插画均由云报客户端、云南大学艺术与设计学院“百年芳华 初心传承”插画创作团队提供

# ព្រឹត្តិការណ៍សំខាន់ក្នុងរយៈពេល ១០០ ឆ្នាំកន្លងទៅ

# 100年大事记

**1921**

● នៅខែ កក្កដា ឆ្នាំ ១៩២១ គណបក្សកុម្មុយនិស្ត ចិនបង្កើតជាផ្លូវការ ។

●1921年7月 中国共产党成立

**1927**

● នៅថ្ងៃទី ១ ខែ សីហា ឆ្នាំ ១៩២៧ ការបះបោរ ណានឆាងកើតឡើង ។

● បង្កើតកងទ័ពក្រហមកម្មករ និងកសិករចិន គឺកងទ័ពរំដោះប្រជាជនចិន ។

●1927年8月1日 南昌起义

●中国工农红军，即中国人民解放军建立。

● នៅឆ្នាំ ១៩២៧ មូលដ្ឋានបដិវត្តន៍ភ្នំជីងកាងត្រូវ បង្កើតជាផ្លូវការ ។ ការងារស្នូលនៃបដិវត្តន៍ចិនផ្ទេរទៅ តំបន់ជនបទ ។

●1927年 井冈山革命根据地建立，中国革命的中心工作转向农村。

**1935**

● នៅខែ មករា ឆ្នាំ ១៩៣៥ កិច្ចប្រជុំ ជុនអ៊ី រៀបចំឡើង ។ ឈានចូលដំណាក់កាលថ្មីនៃការ ដោះស្រាយបញ្ហាជាក់ស្តែងដោយម្ចាស់ការអំពី បដិវត្តន៍ចិន ។

●1935年1月 遵义会议开启独立自主解决中国革命实际问题的新阶段。

**1945**

● នៅថ្ងៃទី ៣ ខែ កញ្ញា ឆ្នាំ ១៩៤៥ សង្គ្រាមប្រយុទ្ធ ប្រឆាំងនឹងការឈ្លានពានរបស់ជប៉ុនទទួលជោគជ័យ ។

● ១២ ឆ្នាំកន្លងទៅនោះ គណបក្សកុម្មុយនិស្តចិនដឹកនាំ កម្លាំងប្រដាប់អាវុធដើម្បីប្រយុទ្ធប្រឆាំងនឹងការឈ្លានពាន របស់ជប៉ុន ។ សង្គ្រាមប្រយុទ្ធប្រឆាំងនឹងការឈ្លានពានរបស់ ជប៉ុនក៏ជាសង្គ្រាមទី ១ ដែលប្រជាជនចិនទទួលជ័យជម្នះ ក្នុងការប្រយុទ្ធប្រឆាំងនឹងការឈ្លានពានពីបរទេសក្នុងរយៈ ពេលជាង ១០០ ឆ្នាំកន្លងទៅ ។

●1945年9月3日 抗日战争胜利

●14年来，中国共产党领导抗日武装坚持抗战，抗日战争也是一百多年来中国人民反对侵略第一次取得完全胜利的战争。

**1949**

● នៅថ្ងៃទី ១ ខែ តុលា ឆ្នាំ ១៩៤៩ សាធារណរដ្ឋប្រជាមានិតចិន ចាប់បដិសន្ធិជាផ្លូវការ ។

● ប្រវត្តិសាស្ត្រចិនឈានចូលក្នុងសករាជថ្មី ។

●1949年10月1日 中华人民共和国成立

●中国历史进入新纪元。

**1953**

● នៅឆ្នាំ ១៩៥៣ ប្រទេសចិនចាប់ផ្តើមអនុវត្ត "ផែនការអភិវឌ្ឍន៍ជាតិរយៈពេល ៥ ឆ្នាំ"ទី ១ ។ កសាងមូលដ្ឋានគ្រឹះសម្រាប់ការធ្វើទំនើបភាវូបនីយកម្ម របស់ប្រទេសចិន ។

●1953年 中国开始实施"第一个五年计划"为新中国现代化打下基础。

● នៅឆ្នាំ ១៩៦៤ គ្រាប់បែកបរមាណូទី ១ របស់ប្រទេសចិនត្រូវបំផ្ទុះដោយជោគជ័យ ។

● “គ្រាប់បែកបរមាណូ មីស៊ីល និងផ្កាយរណប” បានកសាងមូលដ្ឋានគ្រឹះសម្រាប់លើកកម្ពស់តួនាទីអន្តរជាតិរបស់ប្រទេសចិន ។

● 1964年 中国第一颗原子弹爆炸成功

● “原子弹、导弹和人造卫星”奠定了中国国际地位的基础。

● នៅឆ្នាំ ១៩៧៨ កិច្ចប្រជុំពេញអង្គលើកទី ៣ នៃគណៈកម្មាធិការគណបក្សកុម្មុយនិស្តចិនអាណត្តិទី ១១ ប្រារព្ធជាផ្លូវការ ។

● សម្រេចឱ្យផ្ទេរការងារសំខាន់របស់បក្សទៅលើវិស័យសេដ្ឋកិច្ច ។

● 1978年 中国共产党第十一届中央委员会第三次全体会议

● 确立全党的工作重点转移到经济建设上来。




● នៅឆ្នាំ ២០១២ សមាជបក្សកុម្មុយនិស្តចិនលើកទី ១៨ រៀបចំឡើង ។

● សម្រេចឱ្យកសាងនិម្មាបនកម្ម “បង្រួមវិស័យទាំង ៥” គឺសេដ្ឋកិច្ច នយោបាយ វប្បធម៌ សង្គមកិច្ច និងអេកូ-អរិយធម៌ ដើម្បីជំរុញឱ្យមានការស៊ីសង្វាក់គ្នាក្នុងវិស័យផ្សេងៗសម្រាប់ការធ្វើទំនើបភាវូបនីយកម្មប្រទេសជាតិ ។

● 2012年 中国共产党第十八次全国代表大会

● 决定全面落实经济建设、政治建设、文化建设、社会建设、生态文明建设五位一体总体布局，促进国家现代化建设各方面相协调。

● នៅឆ្នាំ ២០១៧ សមាជបក្សកុម្មុយនិស្តចិនលើកទី ១៩ រៀបចំឡើង ។

● កំណត់ឱ្យបានច្បាស់ថា សង្គមនិយមដែលមានលក្ខណៈពិសេសចិនឈានចូលក្នុងយុគសម័យថ្មី ចំណែកជំទាស់សំខាន់ក្នុងសង្គមចិនបានប្រែក្លាយជាទំនាស់រវាងតម្រូវការអំពីការរស់នៅល្អប្រសើរដែលកំពុងលើកកម្ពស់ជាបន្តបន្ទាប់ និងការអភិវឌ្ឍដែលមិនមានតុល្យភាព និងភាពពេញលេញ ។

● 2017年 中国共产党第十九次全国代表大会

● 明确中国特色社会主义进入了新时代，中国社会主要矛盾已经转化为人民日益增长的美好生活需要和不平衡不充分的发展之间的矛盾。

● នៅឆ្នាំ ២០២១ គណបក្សកុម្មុយនិស្តចិនគម្រប់ខួប ១០០ ឆ្នាំ ។

● គណបក្សកុម្មុយនិស្តចិននឹងដឹកនាំប្រជាជនចិន ដើម្បីកសាងប្រទេសសង្គមនិយមទំនើបដ៏ខ្លាំងក្លា ដែលប្រកបដោយភាពថ្កូរថ្កើង ប្រជាធិបតេយ្យ អរិយធម៌ ការចុះសម្រុងគ្នា និងសម្រស់ស្អាត ។

● 2021年 中国共产党成立100周年

● 中国共产党将领导中国人民，建设富强民主文明和谐美丽的社会主义现代化强国。

# ជំពូកទី ៣
# 第三章



# 今日中国

# ប្រទេសចិនបច្ចុប្បន្ន
# 今日中国



ក្រុងសិនជិន ខេត្តក្វាងតុង
广东省深圳市 新华社 图



# 01

នៅខេត្តហឺប៉ៃ   កម្មករកំពុងបញ្ជាម៉ាស៊ីននៅស្រែអំបិល

河北省，工人在盐田操作机械设备作业 新华社 图

# 02

នៅខេត្តគួយចូវ   យុវនារីកំពុងធ្វើការផ្សាយផ្ទាល់តាមអ៊ីនធើណេត   ដើម្បីផ្សព្វផ្សាយពីទេសភាពស្រែរាងជណ្ដើរ

贵州省，青年通过直播推荐梯田风光 新华社 图





# 03

នៅថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០២១   ស្ថានីយវារីអគ្គិសនីឆ្អេរកុកសទន្លេជីនសាចាប់ដំណើរការផលិតអគ្គិសនីជាផ្លូវការ

2021年6月28日，金沙江白鹤滩水电站首批机组投产发电 新华社 图



04

ដំរីអាស៊ីព្រៃនៅខេត្តយូណាន  កំពុងដេកលក់នៅស្រែចំការ

栖息在云南省的野生亚洲象在田间酣睡 新华社 图



05

នៅក្រុងអ៊ុនចូវ ខេត្តជឺជាំង  ជាងសិប្បកម្មកំពុងបង្ហាញពីសិប្បកម្ម“ដំដែកចេញរូបផ្កា”

浙江省温州市，手艺人表演打铁花 新华社 图



06

នៅរដូវរងា  ស្រុកចាវស៊ូនៃតំបន់ស្វយ័តជនជាតិអុយហ្គួររៀបចំការប្រណាំងជិះសេះ  អាស្រ័យលើធនធានព្រឹលដ៏សម្បូរ

冬季，新疆维吾尔自治区昭苏县依托优质的冰雪资源，举办赛马活动 新华社 图

ជំពូកទី ៤

# 第四章

今年是中国共产党成立 100 周年，百年大党，恰似风华正茂。

百年求索正青春。百年前，中国共产党从前人找不到路的地方，开出一条新路来；百年后，中国共产党人仍在不断探索、拓展中国道路的内涵。

百年斗志正青春。百年前，无数青年志士义无反顾投身解放和国家建设的一线；百年后，中国共产党人迎难而上，抗疫情、斗贫困、勇创造，敢于斗争、善于斗争的鲜明品格流淌在他们的血液中。

……

理想不老，才成就了百年正青春的中国共产党。

今天，让我们跟随几位最为人所知的中国共产党员，倾听他们的故事。

## 永远年轻



# អ្នកបដិវត្តន៍មានភាពយុវវ័យជាដរាប

# 革命人永远是年轻

ឆ្នាំនេះជាខួបលើកទី ១០០ នៃការបង្កើតគណបក្សកុម្មុយនិស្តចិន ។ ឆ្លងតាមរយៈការវិវឌ្ឍមួយសតវត្សរ៍កន្លងទៅ បក្សកុម្មុយនិស្តចិនបានរីកចម្រើនលូតលាស់ខ្លាំងណាស់ ។

មួយរយឆ្នាំមុន គណបក្សកុម្មុយនិស្តចិនបានត្រួសត្រាយផ្លូវថ្មីមួយខ្សែនៅកន្លែងដែលគេរកផ្លូវមិនឃើញ ។ មួយរយឆ្នាំក្រោយ សមាជិកបក្សកុម្មុយនិស្តចិននៅតែខិតខំធ្វើការអភិវឌ្ឍ ដើម្បីស្វែងរក និងធ្វើដំណើរតាមផ្លូវអភិវឌ្ឍន៍ពិសេសរបស់ប្រទេសចិន ។

មួយរយឆ្នាំមុន វីរជនវីរនារីរាប់ពាន់រាប់រយនាក់ចូលរួមបុព្វហេតុរំដោះប្រជាជន និងការអភិវឌ្ឍប្រទេសជាតិដោយមិនដែលគិតពីផលប្រយោជន៍របស់ខ្លួន ។ មួយរយឆ្នាំក្រោយ សមាជិកបក្សកុម្មុយនិស្តចិនខិតខំពុះពារឧបសគ្គគ្រប់ប្រភេទ ចូលរួមការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ កិច្ចកាត់បន្ថយភាពក្រីក្រ និងការធ្វើនវានុវត្តន៍ ។ ពួកគេហ៊ានធ្វើការតស៊ូ ហើយពូកែធ្វើការតស៊ូ ចំណែកចារិតមិនព្រមចុះចាញ់បានចាក់ឫសយ៉ាងជ្រៅក្នុងឈាមជ័ររបស់ពួកគេ ។ ឧត្តមគិតមិនដែលចាស់ជរាទេ ។ នេះបានធ្វើឱ្យគណបក្សកុម្មុយនិស្តចិនដែលមានអាយុកាល ១០០ ឆ្នាំនោះ កាន់តែមានភាពយុវវ័យ ។

ថ្ងៃនេះ យើងខ្ញុំសូមបង្ហាញជូនលោកអ្នកអំពីរឿងរ៉ាវរបស់សមាជិកបក្សកុម្មុយនិស្តចិនប៉ុន្មានរូបដែលមានឈ្មោះល្បីរន្ទឺនៅទូទាំងប្រទេសចិន ។



CFP 图

# ឆឹន យ៉ានទីន  វីរជនពលីជីវិតវ័យក្មេង

## 陈延年：年轻的牺牲者

这个夏天，上海龙华烈士陵园，雨后的早晨。有人在一位叫陈延年的青年墓碑前放上了中国神舟十二号载人飞船的照片。即使已经牺牲 90 多年，人们依然纪念他。



ឆឹន យ៉ានទីន
◀ 陈延年
新华社 图

នៅរដូវក្ដៅនេះ  គេបានដាក់រូបថតយានអវកាសសញ្ញា“ស៊ីនចូវ”លេខ ១២ នៅលើផ្នូររបស់បុរសម្នាក់ឈ្មោះ ឆឹន យ៉ានទីន ។  ទោះបីជាគាត់បានពលីជីវិតជាង ៩០ ឆ្នាំហើយ  តែយើងនៅតែរំលឹកវិញ្ញាណក្ខន្ធគាត់ជារៀងរហូត ។

លោក ឆឹន យ៉ានទីន ជាកូនប្រុសច្បងរបស់លោក ឆឹន ទូសៀវ  ដែលជាអ្នកដឹកនាំគណបក្សកុម្មុយនិស្តចិននៅពេលដំបូង ។  កាលនោះ  លោក ឆឹន យ៉ានទីន សង្ឃឹមថានឹងអាចសង្គ្រោះប្រទេសចិនតាមបែបអនាធិបតេយ្យ ។  ពេលគាត់ទទួលដំណឹងថាឪពុកគាត់កំពុងរៀបចំបង្កើតគណបក្សកុម្មុយនិស្តនោះគាត់មើលងាយលើអ្វីដែលឪពុកធ្វើ ។  នៅឆ្នាំ ១៩១៩ លោក ឆឹន យ៉ានទីន  និងប្អូនប្រុសលោកឈ្មោះ ឆឹន ឈីវទីន  ធ្វើដំណើរទៅប្រទេសបារាំងជាមួយគ្នាដើម្បីស្វែងរកវិធីសាស្ត្រកែប្រែជោគវាសនារបស់ប្រទេសចិន ។  ការសិក្សានៅប្រទេសបារាំងបានធ្វើឱ្យគាត់កែប្រែជំនឿរបស់ខ្លួន  ហើយបានចូលជាសមាជិកនៃគណបក្សកុម្មុយនិស្តចិននៅឆ្នាំ ១៩២២ ។  កាលនោះ  លោក ឆឹន យ៉ានទីន មានអាយុតែ ២៤ ឆ្នាំ ។

នៅឆ្នាំ ១៩២៤  លោកត្រឡប់មកប្រទេសចិនវិញហើយទៅធ្វើការជាលេខាធិការគណបក្សនៃតំបន់ក្វាងតុង ។  ក្នុងរយៈពេលមិនដល់ ២ ឆ្នាំ  ចំនួនសមាជិកបក្សកុម្មុយនិស្តចិននៅខេត្តក្វាងតុងបានកើនឡើងពីរាប់រយនាក់ដល់ទៅជាង ៥ ០០០ នាក់ស្មើនឹង ១ ភាគ ៣ នៃចំនួនសមាជិកបក្សកុម្មុយនិស្តចិននៅទូទាំងប្រទេសចិន ។  ចលនាកម្មករនៅខេត្តក្វាងតុងក៏បានទទួលការរីកចម្រើនយ៉ាងឆាប់រហ័ស ។

៣ ឆ្នាំក្រោយ បក្សកុកមិញតាងធ្វើរដ្ឋប្រហារ ហើយបានចាប់សម្លាប់សមាជិកបក្សកុម្មុយនិស្តចិន ។ នៅខែ មិថុនា ឆ្នាំ ១៩២៧ លោក ឆឹន យ៉ានទីន ត្រូវបានចាប់ឃុំដោយទ័ពកុកមិញតាង រួចត្រូវបានសម្លាប់នៅប៉ុន្មានថ្ងៃក្រោយ ។ កាលនោះ លោកមានអាយុតែ ២៧ ឆ្នាំ ។

មិនដល់មួយឆ្នាំក្រោយ ប្អូនប្រុសរបស់លោកក៏ត្រូវបានចាប់សម្លាប់ នៅពេលលោកខិតខំធ្វើការស្តារអង្គការបក្សដែលត្រូវបានបំផ្លាញនៅខេត្តជាំងស៊ូ ។

បច្ចុប្បន្ន គេបានសាងសង់ផ្លូវមួយខ្សែឈ្មោះ “យ៉ានឈីវ” នៅស្រុកកំណើតរបស់លោក ឆឹន យ៉ានទីន និងលោក ឆឹន ឈីវនីន ដើម្បីរំលឹកវិញ្ញាណក្ខន្ធរបស់លោកទាំង ២ រូប ។ ពេលចូលរដូវផ្ការីក ផ្កាស្រស់បំព្រងរីកស្គុះស្គាយតាមសងខាងផ្លូវ ចំណែកនៅចុងម្ខាងនៃផ្លូវនេះ មានតភ្ជាប់នឹងផ្លូវធំទូលាយមួយខ្សែទៀត ដែលត្រូវបានគេដាក់ឈ្មោះថា “ផ្លូវវិបុលភាព” ។

អតីតទីស្នាក់ការនៃគណៈកម្មាធិការគណបក្សកុម្មុយនិស្តចិនសាខាក្វាងតុង
▼中共广东区委旧址 新华社 图



# លោក ចាំង សឺឌឺ បម្រើប្រយោជន៍ប្រជាជន

## 张思德：为人民服务

在为张思德举行的追悼大会上，毛泽东结合他的故事，发表了著名演讲《为人民服务》，第一次从理论上深刻阐明了中国共产党为人民服务的思想。



ចាំង សឺឌឺ(រូបឆ្វេង) ដែលកំពុងដុតធ្យូងជាមួយមិត្តយុទ្ធជន

▲和战友一起烧炭的张思德（左）

新华社 图

នៅខែ កញ្ញា ឆ្នាំ ១៩៤៤ លោកប្រធាន ម៉ៅ សេទុង បានអញ្ជើញចូលរួមពិធីរំឭកវិញ្ញាណក្ខន្ធរបស់ទាហានសាមញ្ញម្នាក់។ ក្នុងពិធីនេះ លោកប្រធាន ម៉ៅ សេទុង មិនគ្រាន់តែសរសេរពាក្យរំឭកវិញ្ញាណក្ខន្ធប៉ុណ្ណោះទេ ថែមទាំងបានថ្លែងសុន្ទរកថាដែរ ។

ទាហាននេះឈ្មោះ ចាំង សឺឌឺ ដែលកើតនៅខែ មេសា ឆ្នាំ ១៩១៥ ក្នុងគ្រួសារកសិករក្រីក្រនៅតំបន់ភ្នំភាគខាងលិចប្រទេសចិន ។ ពេលគាត់មានអាយុតែ ៧ ខែប៉ុណ្ណោះ ម្ដាយរបស់គាត់បានទទួលមរណភាពដោយសារជំងឺធ្ងន់ ហើយឪពុកបានយកគាត់ឱ្យមីងថែទាំ ។ ដោយសារ ចាំង សឺឌឺ ធំធាត់ឡើងដោយហូបអាហារ និងស្លៀកសម្លៀកបំពាក់មកពីអ្នកស្រុកនីមួយៗ មីងបានដាក់ឈ្មោះឱ្យគាត់ថា សឺឌឺ ដែលមានន័យថា ត្រូវដឹងគុណអ្នកស្រុកជានិច្ច ។

នៅខែ ធ្នូ ឆ្នាំ ១៩៣៣ ចាំង សឺឌឺ ដែលមានអាយុ ១៨ ឆ្នាំ បានចូលទ័ពក្រហម ។ នៅឆ្នាំ ១៩៣៧ គាត់បានចូលជាសមាជិកនៃគណបក្សកុម្មុយនិស្តចិន ។

នៅពេលរស់នៅក្នុងយ៉ានអាន (មូលដ្ឋានបដិវត្តន៍ភាគពាយ័ព្យនៃគណបក្សកុម្មុយនិស្តចិន) សម្ភារៈផ្សេងៗខ្វះខាតច្រើនណាស់ ។ នៅដើមឆ្នាំ ១៩៤៤ ដើម្បីដោះស្រាយបញ្ហារងាក្នុងរដូវរងានៃប្រជាជន និងកងទ័ព ចាំង សឺឌឺ បានដឹកនាំទាហានផ្សេងៗចូលរួមក្នុងសកម្មភាពដុតអុសធ្វើធ្យូង ។ ពេលថ្ងៃ គាត់ត្រូវទៅពិនិត្យឡនីមួយៗដើម្បីគ្រប់គ្រងកម្ដៅ ដល់ពេលយប់ គាត់ក៏ត្រូវការក្រោកឡើងច្រើនដងមើលផ្សេងនៃការដុតអុសដែរ ។

នាថ្ងៃទី ៥ ខែ កញ្ញា ឆ្នាំ ១៩៤៤ ចាំង សឺឌឺ និងមិត្តទាហានសម្រេចជីកឡមួយចំនួនទៀត ដើម្បី

ដុតអុសធ្វើធ្យូងឱ្យបានច្រើន ។ ពេលថ្ងៃត្រង់ មានការទ្រុឌទ្រោមក្នុងឡ ហើយកើតមានគ្រោះថ្នាក់ ខណៈពេលនោះ ចាំង សឺដឺ បានរុញមិត្តទាហានចេញពីឡភ្លាមៗ ។ ដីធ្លីដ៏ក្រាស់ធ្លាក់ចុះ ហើយកប់ ចាំង សឺដឺ ក្នុងដី ហេតុនេះ ចាំង សឺដឺ បានពលីជីវិតដ៏វ័យក្មេងរបស់គាត់ ។ កាលនោះ គាត់តែមានអាយុ ២៩ ឆ្នាំ ។

ក្នុងពិធីរំឭកវិញ្ញាណក្ខន្ធដែលរៀបចំឡើងសម្រាប់ ចាំង សឺដឺ លោកប្រធាន ម៉ៅ សេទុង បានថ្លែងសុន្ទរកថាសំខាន់ ដែលមានចំណងជើងថា "បម្រើប្រយោជន៍ប្រជាជន" ហើយបានយករឿងលោក ចាំង សឺដឺ បញ្ជាក់ពីគំនិតបម្រើប្រយោជន៍ប្រជាជនរបស់បក្សកុម្មុយនិស្តចិនជាលើកទី ១ ។ លោកប្រធាន ម៉ៅ សេទុង បានមានប្រសាសន៍ថា មនុស្សម្នាក់ៗសុទ្ធតែនឹងស្លាប់ ចំពោះសារៈសំខាន់នៃការស្លាប់ អ្នកខ្លះធ្ងន់ជាងភ្នំថៃសាន អ្នកខ្លះទៀតស្រាលជាងរោមបក្សី ។ បើអ្នកណាស្លាប់ដើម្បីប្រយោជន៍របស់ប្រជាជន គឺធ្ងន់ជាងភ្នំថៃសានទៅទៀត ។

សារមន្ទីររំលឹកវិញ្ញាក្ខន្ធ ចាំង សឺដឺ
▼ 张思德纪念馆
CFP 图



# ស៊ីន ជីឡាន ប្រុសស្រីធ្វើការដូចគ្នា ត្រូវឱ្យចំណូលស្មើគ្នា

## 申纪兰：男女要同工同酬

1954 年 9 月，在中华人民共和国第一届全国人民代表大会上，年轻的人大代表申纪兰提出的“男女同工同酬”倡议正式写入《中华人民共和国宪法》。



ស៊ីន ជីឡាន
◀申纪兰
新华社 图

នៅខែ កញ្ញា ឆ្នាំ ១៩៥៤ គំនិតផ្ដួចផ្ដើម“ប្រុសស្រីធ្វើការដូចគ្នា ត្រូវឱ្យចំណូលស្មើគ្នា”ដែលលើកឡើងដោយអ្នកតំណាងស្ត្រីវ័យក្មេងមួយរូបឈ្មោះ ស៊ីន ជីឡាន បានត្រូវសរសេរចូលក្នុង“ច្បាប់រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតចិន”ជាផ្លូវការ ។

ស៊ីន ជីឡូន កើតនៅស្រុកភីងស្វូន ខេត្តសានស៊ីក្នុងឆ្នាំ ១៩២៩ ។ គាត់ចូលជាសមាជិកនៃគណបក្សកុម្មុយនិស្តចិននៅពេលមានអាយុ ២៤ ឆ្នាំ ។ នៅស្រុកកំណើតរបស់គាត់ធ្លាប់មានសុភាសិតមួយពោលថា “ប្រុសល្អចូលទីរួមស្រុក ស្រីល្អពុំចេញពីផ្ទះ” ។ ពាក្យនេះមានន័យថា ប្រុសចេញទៅរកស៊ីអាចបង្ហាញពីឆន្ទះរបស់ខ្លួន តែស្រីត្រូវចាំនៅផ្ទះហើយមិនចេញទៅក្រៅទេ ។ រាល់ពេលស្តាប់ឮគេនិយាយយ៉ាងនេះ ស៊ីន ជីឡាន តែងតែខឹងសម្បា ។ គាត់តែងតែនិយាយថា “ហេតុអ្វីបានជាស្ត្រីត្រូវចាំនៅឯផ្ទះ ? ខ្ញុំមិនចាញ់គេទេ !”

ស៊ីន ជីឡាន បានបញ្ជាក់ថា បើតាមស្តង់ដារឱ្យចំណូល ប្រុសធ្វើការមួយថ្ងៃអាចបាន ១០ ពិន្ទុ តែស្ត្រីទទួលបានតែ ៥ ពិន្ទុ ។ ការឱ្យចំណូលមិនស្មើគ្នាបែបនេះ ធ្វើឱ្យស្ត្រីជាច្រើនមិនចង់ទៅធ្វើការនៅខាងក្រៅទេ ហើយក៏បានប៉ះពាល់ដល់តួនាទីរបស់ស្ត្រីក្នុងសង្គមដែរ ។

ដើម្បីឱ្យស្ត្រីទទួលបានការរំដោះ ស៊ីន ជីឡាន ទៅសាកសួរគ្រួសារដ៏ច្រើន ដើម្បីផ្សព្វផ្សាយពីគោលការណ៍“ធ្វើពលកម្មទើបអាចទទួលបានការ

វិដោះ”ចំពោះស្ត្រី ហើយខិតខំយ៉ាងពេញទំហឹងដើម្បីសម្រេចនូវគោលការណ៍ដែល“ប្រុសស្រីធ្វើការដូចគ្នា ត្រូវឱ្យចំណូលស្មើគ្នា”។ ពេលដំបូង មានប្រុសច្រើនមិនយល់ព្រមទេ តែស៊ីន ជីឡាន យល់ឃើញថា មានតែខិតខំធ្វើការឱ្យបានផលល្អ ទើបអាចធ្វើឱ្យស្ត្រីមិនត្រូវគេមើលងាយទេ ។

តាមសំណើសុំរបស់ ស៊ីន ជីឡាន សហករណ៍បានផ្តល់ដីស្រែមួយដុំឱ្យសមាជិកសហករណ៍ភេទស្រីដើម្បីធ្វើការប្រកួតប្រជែងជាមួយសមាជិកប្រុស ។ ក្រុមស្ត្រីទទួលជ័យជម្នះនៅពេលចុងក្រោយ ។ នៅឆ្នាំ ១៩៥២ ភូមិស៊ីកូវចាប់ផ្តើមអនុវត្តគោលការណ៍ដែល“ប្រុសស្រីធ្វើការដូចគ្នា ត្រូវឱ្យចំណូលស្មើគ្នា”។

នៅឆ្នាំ ១៩៥៤ ស៊ីន ជីឡាន ដែលមានអាយុតែ ២៥ ឆ្នាំ បានជាប់ឈ្មោះជាតំណាងរាស្ត្រនៃសភាតំណាងប្រជាជនទូទាំងប្រទេសចិននីតិកាលទី ១ ។ គាត់បានរំលឹកឡើងវិញថា ពេលចូលរួមកិច្ចប្រជុំសភាតំណាងប្រជាជនទូទាំងប្រទេសចិនជាលើកទី ១ ខ្ញុំជិះសត្វលាទៅចូលប្រជុំ ។ តាំងពីពេលនោះមក ស៊ី ជីឡាន បានជាប់ឈ្មោះជាតំណាងរាស្ត្រក្នុងរយៈពេល ១៣ ឆ្នាំជាប់គ្នា ។ ស្មារតីរំដោះស្ត្រីដែលតំណាងដោយគាត់នោះ បានក្លាយទៅជាចំណុចឯកភាពគ្នាក្នុងសង្គមចិននាពេលបច្ចុប្បន្ន ។

នៅថ្ងៃទី ៥ ខែ មីនា ឆ្នាំ ២០១៣ កិច្ចប្រជុំលើកទី ១ នៃសភាតំណាងប្រជាជនទូទាំងប្រទេសចិននីតិកាលទី ១២ ប្រារព្ធនៅវិមានសភាប្រជាជនក្រុងប៉េកាំង ។ លោកស្រី ស៊ីន ជីឡាន(រូបកណ្តាល) ដើរចូលក្នុងសាលប្រជុំ

▼ 2013 年 3 月 5 日，北京，第十二届全国人民代表大会第一次会议在北京人民大会堂开幕。申纪兰（中）步入会场。CFP 图



# លោក ឈាន សៀសិន ខ្ញុំចង់វិលត្រឡប់ទៅប្រទេសចិនវិញ

## 钱学森：我要回祖国

“欲归（国）不得心急如火……”

1955 年一封来自美国的求救信被辗转送到中国总理周恩来手中。写信的人是钱学森，此时的他已被美国政府拘留长达 5 年之久。1955 年 9 月 17 日，钱学森一家终于登上回国的邮轮，他于 1959 年加入中国共产党。此后的一生，钱学森在空气动力学、航空工程、喷气推进、工程控制论、物理力学等技术科学领域做出了开创性贡献，是当之无愧的“中国航天之父”。



ឈាន សៀសិន
◀钱学森
新华社 图

នៅឆ្នាំ ១៩៥៥ សំបុត្រសុំការជួយមួយច្បាប់ដែលមកពីសហរដ្ឋអាមេរិក ត្រូវបានផ្ញើជូននាយករដ្ឋមន្ត្រីចិន ចូវ អិនឡាយ ។ អ្នកដែលសរសេរសំបុត្រនោះឈ្មោះ ឈាន សៀសិន ពេលនោះ គាត់ត្រូវបានរដ្ឋាភិបាលសហរដ្ឋអាមេរិកឃុំឃាំងអស់រយៈពេល ៥ ឆ្នាំហើយ ។ ក្នុងសំបុត្រនេះគាត់បានសរសេរថា “ខ្ញុំប្រញាប់ខ្លាំងណាស់ ដោយសារមិនអាចត្រឡប់ទៅស្រុកចិនវិញបានទេ ។”

លោក ឈាន សៀសិន កើតនៅក្នុងទីក្រុងសៀងហៃ ប្រទេសចិន ។ នៅឆ្នាំ ១៩៣៤ លោកប្រឡងជាប់ នឹងក្លាយទៅជានិស្សិតទទួលអាហារូបករណ៍ ដែលបន្តការសិក្សានៅសហរដ្ឋអាមេរិកនៃសាកលវិទ្យាល័យឈីងហួ និងសិក្សាស្រាវជ្រាវវិស្វកម្មអាកាសចរណ៍ និងអេរ៉ូឌីណាមិក ( aerodynamics ) ។ ក្រោយមកគាត់បង្កើតរូបមន្ត Karman-Tsien ដ៏ល្បីឈ្មោះដោយសហការជាមួយសាស្ត្រាចារ្យផ្នែកអេរ៉ូឌីណាមិកឈ្មោះ Theodore von Kármán ។ តាមអនុសាសន៍របស់លោកសាស្ត្រាចារ្យ Theodore von Kármán លោក ឈាន សៀសិន ដែលមានអាយុ ៣៦ ឆ្នាំបានក្លាយទៅជាសាស្ត្រាចារ្យពេញមួយជីវិតនៃសាកលវិទ្យាល័យ MIT ។

នៅខែ ឧសភា ឆ្នាំ ១៩៤៩ លោក ឈាន សៀសិន បានទទួលសំបុត្រមួយដែលមកពី“អាជ្ញាធរភាគខាងជើង”របស់ប្រទេសចិន ដើម្បីអញ្ជើញគាត់វិលត្រឡប់ទៅស្រុកចិនវិញ ហើយដឹកនាំការកសាងឧស្សាហកម្មអាកាសចរណ៍ ។ “អាជ្ញាធរភាគខាងជើង”នេះ គឺគណបក្សកុម្មុយនិស្តចិន ។ នៅថ្ងៃទី ១ ខែ តុលា



មហាជនកំពុងមើលការបង្ហោះកាំជ្រួចនៅក្រុងវិនឆាងនៃខេត្តហៃណាន
▲群众在海南省文昌市观看火箭发射
CFP 图

ឆ្នាំ ១៩៤៩ ទង់ក្រហមផ្កាយ ៥ ទីមួយត្រូវបានបង្ហូតឡើងនៅទីធ្លាធានអានមិន ដែលបានបញ្ជាក់ថាយុគសម័យថ្មីមួយនៃប្រទេសចិនមកដល់ហើយ ។ លោក ឈាន សៀសិន និងភរិយាលោកសម្រេចចិត្តនឹងវិលត្រឡប់ទៅប្រទេសចិនវិញ ប៉ុន្តែ ពេលនោះសហរដ្ឋអាមេរិកកំពុងឡោមព័ទ្ធដោយ McCarthyism ។ លោក ឈាន សៀសិន ត្រូវបានចាប់ ហើយជាប់ពន្ធនាគារ ១៣ ថ្ងៃទើបត្រូវបានដោះលែង ។

បន្ទាប់ពីលេក ឈាន សៀសិន ត្រូវបានដោះលែង និងចេញពីគុក លោកមិនទទួលបានសេរីភាពពិតប្រាកដទេ ។ សវនាការ បានធ្វើម្តងហើយម្តងទៀត ។ គាត់បានត្រូវគេកាត់ទោសដ៏ចម្លែក និងមិនសមហេតុផលក្នុងប្រវត្តិសាស្ត្រអាមេរិក ពីព្រោះគាត់មានទំនោរខាងគណបក្សកុម្មុយនិស្ត ត្រូវបណ្តេញគាត់ឱ្យចេញពីសហរដ្ឋអាមេរិក តែម្យ៉ាងទៀតដោយសារគាត់កាន់កាប់ចំណេះដឹង និងសម្ងាត់ច្រើនពេក មិនអនុញ្ញាតឱ្យគាត់ចេញពីសហរដ្ឋអាមេរិកឡើយ ។

នៅរដូវក្តៅនៃឆ្នាំ ១៩៥៥ លោក ឈាន សៀសិន បានរកឃើញឱកាសសរសេរសំបុត្រមួយ និងខិតខំផ្ញើចេញពីសហរដ្ឋអាមេរិកដោយភរិយារបស់គាត់ ។ សំបុត្រមួយនេះ ឆ្លងកាត់ពាក់កណ្តាលភពផែនដីទើបដល់ក្រុងប៉េកាំង ។ ជាទីបំផុត ដោយសាររដ្ឋាភិបាលចិនដោះលែងឈ្លើយនៃកងទ័ពសហរដ្ឋអាមេរិកមុនពេលកំណត់ និងមានសំបុត្រមួយនេះ សហរដ្ឋអាមេរិកយល់ព្រមឱ្យលោក ឈាន សៀសិន វិលត្រឡប់ទៅប្រទេសចិនវិញ ។

នាថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ១៩៥៥ ក្រុមគ្រួសាររបស់លោក ឈាន សៀសិន បានឡើងកប៉ាល់វិលត្រឡប់ទៅចិនវិញនោះ ហើយលោក ឈាន សៀសិន ចូលជាសមាជិកនៃគណបក្សកុម្មុនិស្តចិននៅឆ្នាំ ១៩៥៩ ។ ក្នុងជីវិតរបស់ លោក ឈាន សៀសិន បានធ្វើការបរិច្ចាគដែលមានលក្ខណៈត្រួសត្រាយលើវិស័យវិទ្យាសាស្ត្របច្ចេកទ្យា ដូចជាអេរ៉ូឌីណាមិក វិស្វកម្មអាកាសចរណ៍ ការរុញច្រានយន្តហោះ Engineering Cybernetics និងមេកានិចរូបវន្តជាដើម លោកបានត្រូវគេដាក់ឈ្មោះថា “បិតាអាកាសចរណ៍ប្រទេសចិន” ។

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយរបស់ជីវិតគាត់ អវកាសយានិកចិនគ្រប់គ្នាសុទ្ធតែទៅសួរសុខទុក្ខជាមួយលោកភ្លាមៗក្រោយពីពួកគេវិលត្រឡប់មកភពផែនដីវិញពីលំហរអវកាស។

# លោក ជីវ យូលូ  អ្នកបម្រើល្អរបស់ប្រជាជន

## 焦裕禄：人民的好公仆

作为一位县委书记，焦裕禄的一条被子上有 42 个补丁，当年县委有一辆破旧的吉普车，但他从来没有坐过，唯独“青睐”那辆别人骑了 11 年的自行车，下乡工作都靠它。焦裕禄成为了中国干部的楷模，他的精神至今被人牢记。



ជីវ យូលូ
◀ 焦裕禄
新华社 图

លោក ជីវ យូលូ កើតនៅគ្រួសារក្រីក្រមួយក្នុងខេត្តសានតុង ប្រទេសចិន ។ ក្នុងសង្គ្រាមប្រយុទ្ធប្រឆាំងនឹងការឈ្លានពានរបស់ជប៉ុន លោកធ្លាប់ត្រូវបានចាប់ឃុំដោយទ័ពជប៉ុន ហើយទៅធ្វើការនៅអណ្ដូងរ៉ែធ្យូងថ្មនៅក្រុងហ្វូស្ហួន ។ ក្រោយពីរត់ចេញពីកន្លែងនោះ លោកបានត្រឡប់ទៅស្រុកកំណើតវិញ តែដោយសារបានជួបនឹងគ្រោះមហន្តរាយធម្មជាតិ លោកបានធ្វើចំណាកស្រុកហើយរហូតដល់បញ្ចប់សង្គ្រាមប្រឆាំងជប៉ុន ទើបលោកត្រឡប់ទៅស្រុកកំណើតវិញ ។

កាលនោះ បក្សកុម្មុយនិស្តចិនបានដឹកនាំមហាជនធ្វើសកម្មភាពបដិវត្តន៍នៅស្រុកកំណើតរបស់លោក ។ ដោយសារធ្លាប់រងគ្រោះពីការឈ្លានពានពីបរទេស លោកបានចុះឈ្មោះចូលកងជីវពល ហើយបានចូលជាសមាជិកនៃបក្សកុម្មុយនិស្តចិននៅឆ្នាំ ១៩៤៦ ។

នៅរដូវរងានៃឆ្នាំ ១៩៦២ លោកត្រូវបានតែងតាំងជាលេខាបក្សប្រចាំស្រុកឡានខាវនៃក្រុងខាយហ្វឹងខេត្តហឺណាន ។ តាំងពីពេលនោះមក លោកសម្រេចចិត្តនឹងកែប្រែមុខមាត់នៃតំបន់រងគ្រោះនេះ ។

កាលនោះ ស្រុកឡានខាវបានកើតគ្រោះមហន្តរាយយ៉ាងធ្ងន់ធ្ងរ ។ តាមដងទន្លេលឿងក្នុងស្រុកនេះ សុទ្ធតែជាខ្សាច់ពណ៌លឿង ។ ដីធ្លីមានសារធាតុអំបិលកម្រិតខ្ពស់ ហើយមានស្មៅដុះពេញពាសទីកន្លែង ។ នៅឆ្នាំនេះ ខ្យល់ខ្សាច់បានបំផ្លាញស្រែស្រូវជាង ១,៣ ម៉ឺនហិកតានៅរដូវផ្ការីក ទឹកលិចស្រែពីរម៉ឺនហិកតានៅរដូវរំហើយ ហើយមានដំណាំជាង ៦ ៦០០ ហិតាត្រូវបានងាប់ដោយសារសារធាតុអំបិល ។ ទាំងនេះបានធ្វើឱ្យបរិមាណនៃការប្រមូលផលស្រូវរបស់ស្រុកឡានខាវធ្លាក់ចុះដល់កម្រិតទាបបំផុត ។

ក្នុងអំឡុងពេលជាង ៤៧០ ថ្ងៃ ដែលលោកធ្វើការនៅស្រុកឡានខាវនេះ លោក ជីវ យូលូ បានទៅ



ទស្សនាភូមិចំនួនជាង ១២០ ក្នុងចំណោមភូមិទាំង ១៤៩ ហើយបានធ្វើការសិក្សាយ៉ាងហ្មត់ចត់អំពីស្ថានភាពដីស្រែជាង ១ ០០០ គីឡូម៉ែត្រការ៉េនៅស្រុកឡានខាវ ។ លោកបានកំណត់ផែនការអភិវឌ្ឍន៍ស្រុកដែលនឹងគ្រប់គ្រងខ្សាច់ ទឹកជំនន់ ដីមានសារធាតុអំបិលដោយជោគជ័យក្នុងរយៈពេល ៣-៥ ឆ្នាំខាងមុខ" ។ ដើម្បីសម្រេចនូវគោលដៅនេះ លោកបានដឹកនាំប្រជាជននៅស្រុកទាំងមូលដាំដើមឈើការពារខ្សាច់ និងខិតខំធ្វើការ ហើយតែងតែហូបបាយរស់នៅ និងធ្វើការជាមួយមហាជនជាប់រហូត ។

នៅថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ១៩៦៤ លោក ជីវ យូលូ បានទទួលមរណភាពដោយសារជំងឺមហារីកថ្លើម ។ កាលនោះ លោកមានអាយុត្រឹមតែ ៤២ ឆ្នាំ ។

"ខ្ញុំធ្លាប់ជាប់គុក ជីករ៉ែធ្យូងថ្ម ធ្វើការឱ្យគេនៅសង្គមចាស់ ហើយបានចូលជាសមាជិកបក្សកុម្មុយ-និស្តចិន និងទទួលស្វាគមន៍ការមកដល់នៃប្រទេសចិនថ្មី ។" នេះគឺជាប្រវត្តិរូបដែលសរសេរដោយលោក ជីវ យូលូ ផ្ទាល់ ។ លោកបានបញ្ជាក់ថា បើមិនកែប្រែមុខមាត់នៃស្រុកឡានខាវ ខ្ញុំមិនព្រមចាកចេញពីទីនេះទេ ។ សព្វថ្ងៃ ដើមឈើដែលដាំដោយលោកបានជំរុញការអភិវឌ្ឍឧស្សាហកម្មកែច្នៃផលិតផលឈើនៅស្រុកឡានខាវ ជាពិសេស កសិកម្មត្រសក់ផ្អែមនៅស្រុកនេះអាចទទួលបានចំណូលរាប់រយលានយ៉ាន់ជារៀងរាល់ឆ្នាំ ។ នៅខែ កុម្ភៈ ឆ្នាំ ២០១៧ ស្រុកឡានខាវបានក្លាយជាស្រុកដែលគេចខ្លួនចេញពីភាពក្រីក្រក្រុមទី ១ របស់ប្រទេសចិន ។

ទិដ្ឋភាពភូមិចាំងជួង ឃុំតុងប៉ាធូវ ស្រុកឡានខាវ ខេត្តហឺណាន ដែលថតនៅថ្ងៃទី ៣ ខែកញ្ញា ឆ្នាំ ២០២០

▲ 2020 年 9 月 3 日拍摄的河南省兰考县东坝头镇张庄村村貌 新华社 图

# ធូ យូវយូវ សមាជិកបក្សកុម្មុយនិស្តចិនដែលទទួលបានរង្វាន់ Nobel

## 屠呦呦：获得诺贝尔奖的共产党员

1946 年，16 岁的屠呦呦不幸染上了肺结核，被迫终止学业，在家休养了两年。这次的生病经历，让屠呦呦对医学产生了极大的兴趣，她觉得医学不仅能够帮助自己走出病痛，还能治疗更多的人。1955 年，屠呦呦被分配在中国中医科学院中药研究所工作，她当时并不知道，自己以后研究的工作，将对全球上亿人产生影响。



ធូ យូវយូវ
◀ 屠呦呦
中新社 图

នៅឆ្នាំ ១៩៤៦ កញ្ញា ធូ យូវយូវ ដែលមានអាយុតែ ១៦ ឆ្នាំ បានកើតជំងឺរបេង ហើយមានតែផ្អាកការរៀនសូត្រក្នុងសាលារៀនដោយបង្ខំចិត្ត និងបានសម្រាកនៅឯផ្ទះរយៈពេល ២ ឆ្នាំ ។ នេះបានធ្វើឱ្យគាត់មានចំណាប់អារម្មណ៍យ៉ាងខ្លាំងចំពោះវេជ្ជសាស្ត្រ ពីព្រោះគាត់យល់ឃើញថា វិជ្ជាពេទ្យមិនគ្រាន់តែអាចជួយគាត់រួចខ្លួនផុតពីការឈឺចាប់នៃជំងឺប៉ុណ្ណោះទេ ថែមទាំងនឹងអាចជួយព្យាបាលជំងឺរបស់មនុស្សកាន់តែច្រើនទៀតផង ។

នៅឆ្នាំ ១៩៥៥ កញ្ញា ធូ យូវយូវ បានបញ្ចប់ការសិក្សា ហើយទៅធ្វើការនៅវិទ្យាស្ថានសិក្សាស្រាវជ្រាវថ្នាំចិនសែនៃបណ្ឌិត្យសភាវេជ្ជសាស្ត្រចិន ។ កាលនោះគាត់មិនទាន់ដឹងថា ការសិក្សាស្រាវជ្រាវរបស់គាត់អាចនឹងផ្តល់ផលប្រយោជន៍ដល់មនុស្សរាប់រយលាននាក់លើពិភពលោក ។

នៅឆ្នាំ ១៩៦៧ ប្រទេសចិនចាប់ផ្តើមអនុវត្តគម្រោងសិក្សាស្រាវជ្រាវអំពីថ្នាំថ្មីសម្រាប់បង្ការនិងព្យាបាលជំងឺគ្រុនចាញ់ ។ ធូ យូវយូវ ធ្វើជាប្រធានក្រុមសិក្សាស្រាវជ្រាវថ្នាំចិនសែនៃគម្រោងនេះ ។ នៅថ្ងៃទី ៤ ខែ តុលា ឆ្នាំ ១៩៧១ គេបានទទួលជោគជ័យក្នុងការសិក្សាស្រាវជ្រាវនៅបន្ទប់ពិសោធន៍មួយនៃវិទ្យាស្ថានសិក្សាស្រាវជ្រាវថ្នាំចិនសែនៃបណ្ឌិត្យសភាវេជ្ជសាស្ត្រចិន ក្រោយពីបានបរាជ័យ ១៩០ លើក ។ ថ្នាំដែលគេបានរកឃើញនោះអាច





លោកស្រី ធូ យូវយូវ ទទួលបានរង្វាន់ Nobel
▲ 屠呦呦获得诺贝尔奖
新华社 图

បង្ការជំងឺគ្រុនចាញ់ ១០០% ។

ក្រោយពីនោះ គេត្រូវសាកល្បងថ្នាំថ្មីនេះលើខ្លួនមនុស្ស ។ ធូ យូវយូវ ក៏បានលើកសំណើសុំជូនថ្នាក់ដឹកនាំថា "ខ្ញុំជាមេក្រុម ហើយត្រូវសាកល្បងថ្នាំថ្មីជាមុន !" ដូច្នេះ ធូ យូវយូវ និងអ្នកសិក្សាស្រាវជ្រាវផ្សេងទៀត បានចូលទៅមន្ទីរពេទ្យ ដើម្បីធ្វើជាអ្នកស្ម័គ្រចិត្តក្រុមទី ១ សម្រាប់សាកល្បងថ្នាំថ្មីនេះ ។ បន្ទាប់ពីនោះ គាត់បានសាកល្បងថ្នាំនេះលើខ្លួនអ្នកជំងឺ ហើយទទួលបានលទ្ធផលគួរឱ្យពេញចិត្ត ។

នៅឆ្នាំ ១៩៧៣ ថ្នាំព្យាបាលជំងឺគ្រុនចាញ់ថ្មីដែលសិក្សាស្រាវជ្រាវដោយ ធូ យូវយូវ បានទទួលជោគជ័យ ហើយបានសង្គ្រោះជីវិតរបស់មនុស្សច្រើនលើពិភពលោក ។

នៅឆ្នាំ ២០១៥ ដោយសារបានរួមវិភាគទានយ៉ាងធំធេងក្នុងការបង្ការ និងព្យាបាលជំងឺគ្រុនចាញ់ ធូ យូវយូវ បានទទួលរង្វាន់វេជ្ជសាស្ត្រ Nobel ។ ធូ យូវយូវ និងអ្នកទទួលរង្វាន់ Nobel ជាជនជាតិចិនម្នាក់ទៀត គឺអ្នកនិពន្ធ មូ យ៉ាន សុទ្ធតែជាសមាជិកនៃគណបក្សកុម្មុយនិស្តចិន ។

# ហួង វិនសៀវ សម្រេចសុបិនជាមួយប្រជាជន ក្នុងជីវិតទើបគ្មានការសោកស្ដាយ

## 黄文秀：同人民一起梦想，青春才能无悔

驻村满一周年时，母校北京师范大学转载了黄文秀的文章《扶贫 从“新手”到“熟路”》，她在里面写道：“扶贫之路，对我而言，更像是心中的长征”。在听到黄文秀遇难的消息时，很多被她生前照顾的老人和小孩都接受不了这个现实，难过得痛哭流涕、泣不成声。在 1 年 82 天的日子里，百坭村贫困发生率由 22% 降至 2.71%。



រូបថត កញ្ញា ហួង វិនសៀវ ពេលធ្វើការងារ

◀ 黄文秀生前的工作照 新华社图

ពេលយប់ថ្ងៃសុក្រទី ១៤ ខែ មិថុនា ឆ្នាំ ២០១៩ ឆ្លៀតឱកាសចុងសប្ដាហ៍ កញ្ញា ហួង វិនសៀវ កម្មាភិបាលជួយកាត់បន្ថយភាពក្រីក្រដែលមានអាយុ ៣០ ឆ្នាំ បានវិលត្រឡប់ទៅស្រុកកំណើតរបស់គាត់វិញ គឺតំបន់ជនបទនៅស្រុកធានយ៉ាង ក្រុងប៉ៃស៊ី តំបន់ស្វយ័តជនជាតិជ្វួង ក្វាងស៊ី ដើម្បីជួបនិងសួរសុខទុក្ខឪពុករបស់គាត់ដែលបានកើតជំងឺមហារីក និងទទួលបានការវះកាត់ពីរដងជាប់គ្នា ។ នាថ្ងៃទី ១៦ ខែ មិថុនា មេឃធ្លាក់ភ្លៀងធំ ដល់ម៉ោង ២ រសៀលជាង ហួង វិនសៀវ មិនទាន់ហូបបាយតែប្រញាប់ចេញពីផ្ទះទៅភូមិដែលគាត់ជួយកាត់បន្ថយភាពក្រីក្រនោះវិញ ។ ឪពុករបស់គាត់បានមើលការព្យាករណ៍អាកាសធាតុ ហើយដឹងថាពេលយប់នឹងធ្លាក់ភ្លៀងយ៉ាងខ្លាំង ឪពុកនិយាយថា “កូន ចាំស្អែកទៅវិញបានទេ ?”

ប៉ុន្តែ ហួង វិនសៀវ ទទូចវិលត្រឡប់ទៅវិញ ។ គាត់ឆ្លើយតបថា “ប៉ា ពីព្រោះធ្លាក់ភ្លៀងខ្លាំងប្រហែលនឹងបណ្ដាលឱ្យភូមិរងគ្រោះមហន្តរាយ ខ្ញុំត្រូវទៅវិញឱ្យបានឆាប់ ។” មុនពេលចេញពីផ្ទះ ហួង វិនសៀវ បានជំរាបឪពុកថា “ប៉ា កុំភ្លេចលេបថ្នាំផង ។” តាមផ្លូវត្រឡប់ទៅវិញ ហួង វិនសៀវ បើកឡានបណ្ដើរ ផ្ញើសារឱ្យលេខាគណបក្សភូមិលោក ចូវ ឆាំងចាន បណ្ដើរ ដើម្បីសួរពីស្ថានភាពរបស់ភូមិ ។ ហួង វិនសៀវ ព្រួយបារម្ភនឹងភូមិដោយសារដីធ្លីក្នុង




ទិដ្ឋភាពថ្មីនៃភូមិបែនី
▲ 百坭村的新村貌
新华社 图

តំបន់នោះមានភាពទន់ជ្រាយ រាល់ពេលចូលរដូវវស្សា ងាយកើតគ្រោះថ្នាក់បាក់ដី ។

ពេលព្រលឹមថ្ងៃទី ១៧ ខែ មិថុនា ហ្វួង វិនសៀវ ពលីជីវិតដោយសារជួបនឹងទឹកជំនន់ពេលបើកឡាន ។

ហ្វួង វិនសៀវ កើតនៅឆ្នាំ ១៩៨៩ ហើយបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិតពីសាកលវិទ្យាល័យគរុកោសល្យប៉េកាំងនៅឆ្នាំ ២០១៦ ។ នៅខែ មីនា ឆ្នាំ ២០១៨ គាត់បានចូលកាន់តំណែងជាលេខាបក្សទី ១ ប្រចាំភូមិបែនី ស្រុកលីយេ ។

ហ្វួង វិនសៀវ ក៏ធ្លាប់យំដែរខណៈពេលគាត់ទើបដល់ភូមិបំពេញបេសកកម្ម ក្នុងសៀវភៅសរសេររបស់គាត់មានការសរសេរថា អ្នកស្រុកមើលឃើញថាលេខាបក្សទី ១ ប្រចាំភូមិជាស្ត្រី ពិតជាមានចំណាប់អារម្មណ៍ និងចម្ងល់ខ្លាំង នេះធ្វើឱ្យខ្ញុំមានសម្ពាធធ្ងន់ ។ ទោះបីជា ហ្វួង វិនសៀវ មិនស្ទូវស្គាល់អ្នកភូមិ គាត់បានទៅសួរសុខទុក្ខតាមគ្រួសារនីមួយៗ ។ តាមធម្មតា ហ្វួង វិនសៀវ មិនផឹកស្រាទេ តែពេលខ្លះ គាត់បានយកស្រាទៅរកអ្នកភូមិផឹកជាមួយគ្នា ។ គាត់ក៏បានគូរគំនូរផែនទីដោយផ្ទាល់ដៃ ហើយនៅលើផែនទីនោះបានកត់ត្រាឈ្មោះរបស់គ្រួសារនីមួយៗ ។

នៅពេល ហ្វួង វិនសៀវ ធ្វើការក្នុងភូមិដល់ខែទី ៥ គាត់បានសរសេរក្នុងសៀវភៅសរសេររបស់ខ្លួនថា "ខ្ញុំរកឃើញថា គ្រាមភាសារបស់ខ្ញុំមានការរីកចម្រើនហើយ ខ្ញុំអាចនិយាយគ្នាលេងជាមួយអ្នកភូមិដោយប្រើគ្រាមភាសាហើយ ។" ដើម្បីជួយកាត់បន្ថយភាពក្រីក្រ ហ្វួង វិនសៀវ ជួយកសិករនាំចូលបច្ចេកទេសដាំក្រូចដីជឿនលឿន ហើយបង្រៀនអ្នកភូមិឱ្យចេះរកស៊ីតាមប្រព័ន្ធពាណិជ្ជកម្មអេឡិចត្រូនិច ។

បន្ទាប់ពីទទួលដំណឹងថា ហ្វួង វិនសៀវ បានពលីជីវិត មនុស្សចាស់ និងកុមារាកុមារីដែលធ្លាប់ទទួលបានថែទាំពីគាត់ឈឺចាប់ខ្លាំងណាស់ ។ នៅឆ្នាំ ២០២០ ភូមិប៉ៃនីបានសម្រេចការកាត់បន្ថយភាពក្រីក្រដោយជោគជ័យ ដំណឹងល្អនេះជាការលួងលោមសម្រាប់ ហ្វួង វិនសៀវ ។



**រូបសញ្ញាបក្ស**

បង្ហាញពីការដឹកនាំ និងតួនាទីស្នូលរបស់បក្សកុម្មុយនិស្តចិន

**党徽:**

体现中国共产党的领导和核心地位

**ពពកសិរីមង្គល**

បង្កប់អត្ថន័យដែលមាតុប្រទេសមានភាពរុងរឿងថ្កុំថ្កើង និងទទួលការរីកចម្រើនដោយមានភាពសុខដុមរមនា

**如意祥云:**

寓意国家繁荣昌盛、和谐发展

**បង្គោល និងរស្មី**

បង្កប់អត្ថន័យអំពីភាពត្រចះត្រចង់ និងគុណបំណាច់របស់បក្ស

**丰碑与光芒:**

寓意党的辉煌历程与丰功伟绩

**ទង់**

មានន័យថាខិតខំឧស្សាហ៍ព្យាយាម ដើម្បីសម្រេចគោលដៅបដិវត្តន៍ ក្រោមការដឹកនាំពីបក្ស

**旗帜:**

寓意在党的领导下，为实现革命理想而永远奋斗

**ផ្កាយ**

ជានិមិត្តរូបនៃឧត្តមគតិខ្ពង់ខ្ពស់ និងការបន្តវេន

**五角星:**

象征共产主义崇高理想与薪火相传

**ផ្កាឈូករ័ត្ន**

ជានិមិត្តរូបដែលសមាជិកបក្សទាំងអស់ និងប្រជាជនទូទាំងប្រទេសរួមសាមគ្គីគ្នាជុំវិញមជ្ឈិមបក្ស

**向日葵:**

象征全党全中国紧密团结在党中央周围

# “គ្រឿងឥស្សរិយយស ១ កក្កដា”

# “七一勋章”

នេះជាកិត្តិយសខ្ពង់ខ្ពស់បំផុតនៃគណបក្សកុម្មុយនិស្តចិន

中国共产党党内最高荣誉



新华社 图



今年是中国共产党成立 100 周年。为了隆重表彰在中国革命、建设、改革各个历史时期，孜孜以求、默默奉献，贡献突出、品德高尚的功勋模范党员，中共中央决定，授予 29 人“七一勋章”。

这次受表彰的“七一勋章”获得者中，有冒着炮火运送三批解放军成功渡过长江的小英雄马毛姐、点亮贫困山区女孩受教育梦想的张桂梅、牺牲在扶贫一线的黄文秀、带领村民致富的村书记黄大发等。

ឆ្នាំនេះជាខួបលើកទី ១០០ នៃការបង្កើតបក្សកុម្មុយនិស្តចិន ។ ដើម្បីកោតសរសើរដល់សមាជិកបក្សកុម្មុយនិស្តចិនដែលឧស្សាហ៍ព្យាយាមធ្វើការ និងមានស្នាដៃពិសេសក្នុងដំណាក់កាលបដិវត្តន៍ ដំណាក់កាលកសាងប្រទេស និងដំណាក់កាលកំណែទម្រង់ មជ្ឈិមបក្សកុម្មុយនិស្តចិនបានសម្រេចផ្តល់“គ្រឿងឥស្សរិយយស ១ កក្កដា”ដល់សមាជិកបក្សឆ្នើម ២៩ នាក់ ។

ក្នុងចំណោមសមាជិកបក្សដែលទទួល“គ្រឿងឥស្សរិយយស ១ កក្កដា”លើកនេះ មានវីរនារី ម៉ា ម៉ៅជា ដែលធ្លាប់ជួយកងទ័ពរំដោះប្រជាជនចិនឆ្លងទន្លេយ៉ាងសេ ៣ លើក មានលោកស្រី ចាំង គួយម៉ី ដែលជួយសម្រេចសុបិនទទួលការអប់រំរបស់ក្មេងស្រីក្នុងតំបន់ក្រីក្រ មានកញ្ញា ហួង វិនសៀវ ដែលជាកម្មាភិបាលកាត់បន្ថយភាពក្រីក្រពលីជីវិតនៅពេលធ្វើការ និងមានលោក ហួង តាហ្វា លេខាបក្សប្រចាំភូមិដែលដឹកនាំអ្នកភូមិដើរឆ្ពោះទៅកាន់ជីវភាពធូរធារគ្រប់គ្នា ។ល ។

# 1／95148000













截至2021年6月5日，中国共产党党员总数为9514.8万名。

他们来自各行各业，有救死扶伤的医生，有教书育人的教师，有辛勤淳朴的农民，也有驰骋赛场的运动健将……虽然身份不同，职业各异，但他们都有同样的坚持——为人民服务。

គិតមកដល់ថ្ងៃទី ៥ ខែ មិថុនា ឆ្នាំ ២០២១ គណបក្សកុម្មុយនិស្តចិនមានសមាជិកចំនួនសរុប ៩៥,១៤៨ លាននាក់ ។

ពួកគេធ្វើការងារលើវិស័យផ្សេងៗក្នុងសង្គម រួមមានគ្រូពេទ្យដែលខិតខំសង្គ្រោះជីវិតប្រជាជន គ្រូបង្រៀនដែលខិតខំបង្រៀនប្រដៅសិស្សនិស្សិត កសិករដែលខិតខំធ្វើស្រែចំការ និងកីឡាករកីឡាការិនីដែលចូលរួមការប្រកួតលើកីឡាដ្ឋាន ។ ពិតមែនតែពួកគេមានអត្តសញ្ញាណ និងមុខរបរខុសគ្នា តែមានឧត្តមគតិដូចគ្នាតែមួយ គឺបម្រើប្រយោជន៍របស់ប្រជាជន ។


















新华社 图

# ជំពូកទី ៥
# 第五章

# 友好往来

“永远不要离开中国。”这是汉斯·米勒医生 1994 年去世前反复叮嘱妻子的话。

1939 年，二战爆发。瑞士医学博士毕业的德国青年米勒辗转来到延安，在抗日战争、解放战争中与中国共产党和中国人民并肩战斗，之后又投身中国社会主义建设。

自 1921 年成立以来，中国共产党在革命、建设、改革等不同时期，吸引了众多像米勒这样的外国友人。中国共产党人与国际友人的百年交往故事，成为世界认识中共的一个窗口。



លោក Edgar Snow

斯诺（右一）资料图片



លោក លីន ម៉ែក  និងប្រពន្ធរបស់លោក

林迈可和妻子 资料图片

# រឿងនិទានរបស់មិត្តបរទេស និងបក្សកុម្មុយនិស្តចិន
# 国际友人与中国共产党的故事



លោក ហានស៍ មីឡេ និងប្រពន្ធរបស់លោក
汉斯 · 米勒和妻子 资料图片



គ្រូពេទ្យ ម៉ា ហៃតឺ
马海德医生 资料图片

នៅឆ្នាំ ១៩៩៤ មុនពេលចែកឋានលោកគ្រូពេទ្យ ហានស៍ មីឡេ បានផ្តាំផ្ញើប្រពន្ធលោកថា កុំចាកចេញពីប្រទេសចិនជានិច្ច ។

នៅឆ្នាំ ១៩៣៩ សង្គ្រាមលោកលើកទី ២ បានផ្ទុះឡើង ។ បុរសអាល្លឺម៉ង់ម្នាក់ដែលបញ្ចប់ការសិក្សាថ្នាក់បណ្ឌិតនៅប្រទេសស្វីស បានធ្វើដំណើរមកដល់យ៉ានអាន ដើម្បីរួមសហការគ្នាជាមួយគណបក្សកុម្មុយនិស្តចិន ក្នុងសង្គ្រាមប្រយុទ្ធប្រឆាំងនឹងការឈ្លានពានរបស់ប្រទេសជប៉ុន និងសង្គ្រាមរំដោះប្រទេសចិន ។ ក្រោយមក លោកបានចូលរួមក្នុងបុព្វហេតុអភិវឌ្ឍន៍សង្គមនិយមនៅប្រទេសចិន ។

នៅពេលនិយាយអំពីការជាប់និស្ស័យជាមួយគណបក្សកុម្មុយនិស្តចិន កូនប្រុសរបស់លោកឈ្មោះ មីតេវ៉ា បាននិទានរឿងឪពុកគួរជាទីរំភើបចិត្ត ។ “លោកប្រធាន ម៉ៅ សេទុង និងអគ្គមេបញ្ជាការ ជូ តឺ បានសំណេះសំណាលគ្នាជាមួយឪពុកខ្ញុំ ដែលបានធ្វើឱ្យគាត់ចាប់អារម្មណ៍ខ្លាំងណាស់ ។”

តាំងពីការបង្កើតនៅឆ្នាំ ១៩២១ មក គណបក្សកុម្មុយនិស្តចិនបានទាក់ទាញមិត្តបរទេសជាច្រើនដូចលោក ហានស៍ មីឡេ ដើម្បីចូលរួមការធ្វើបដិវត្តន៍ ការកសាងប្រទេស និងការធ្វើកំណែទម្រង់នៅដំណាក់កាលផ្សេងៗ ។ រឿងនិទានរាប់អានគ្នារវាងបក្សកុម្មុយនិស្តចិន និងមិត្តបរទេសក្នុងរយៈពេល ១០០ ឆ្នាំកន្លងទៅនោះ បានក្លាយទៅជាច្រកដ៏សំខាន់មួយសម្រាប់ឱ្យពិភពលោកស្វែងយល់ពីគណបក្សកុម្មុយនិស្តចិន ។



នៅឆ្នាំ ១៩៣៨ លោកស្រី សុង ឈីងលីង និងសមាជិកនៃគណៈកម្មាធិការកណ្ដាលការពារសហព័ន្ធចិនដែលដឹកនាំដោយលោកស្រី ថតរូបនៅហុងកុង ។ ពីរឆ្វេងទៅស្ដាំរួមមាន អែភ្ជូស្ថាន តឹង វិនចាវ លីវ ម៉ឹងសៀង សុង ឈីងលីង ហ្វាឡាងស៍ ក្លាក និងលីវ ឈឹងជី
1938 年，宋庆龄和她领导的保卫中国同盟中央委员会成员在香港合影。左起爱泼斯坦、邓文钊、廖梦醒、宋庆龄、法朗斯、克拉克、廖承志 资料图片



នៅថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ១៩៣៩ លោក ជូ តឺ (រូបទី ៣ ខាងស្ដាំ) ទទួលជួបសមាជិកក្រុមសុខាភិបាលនៅភូមិវ៉ាំងចាយូ ។ រូបទី ២ ខាងឆ្វេងគឺ លោក មីឡេ
1939 年 12 月 21 日，朱德（右三）在王家峪会见医疗队成员。左二为米勒 资料图片

## កម្លាំងដ៏ខ្លាំងក្លានៃឧត្ដមគតិ
理想的力量“难以置信”

តើសមាជិកបក្សកុម្មុយនិស្ដចិនជាមនុស្សបែបណា ?

នៅឆ្នាំ ១៩៣៦ អ្នកនិពន្ធអាមេរិកឈ្មោះ Edgar Snow បានធ្វើដំណើរមកដល់តំបន់ភាពខាងជើងនៃខេត្តសាន់ស៊ី ដើម្បីស្វែងរកចម្លើយនៃសំណួរនេះ ។ លោកធ្លាប់ពិគ្រោះពិភាក្សាគ្នាជាមួយលោក ម៉ៅ សេទុង ដល់យប់ជ្រៅជាច្រើនលើក ។ មិនតែប៉ុណ្ណោះ លោកក៏បានធ្វើបទសម្ភាសន៍ជាមួយលោក ភឹង តឺហួយ លោក សៀ ហៃតុង និងកម្មាភិបាលជាន់ខ្ពស់ជាច្រើនរូបទៀតនៃគណបក្សកុម្មុយនិស្ដចិន ព្រមទាំងទាហានសាមញ្ញជាច្រើននាក់ ។ លោកចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះជំនឿដ៏មោះមុតរបស់សមាជិកបក្សកុម្មុយនិស្ដចិន ។

ក្នុងសៀវភៅ“ផ្កាយក្រហមចែងចាំងលើទឹកដីប្រទេសចិន” លោកបានថ្លែងចំណាប់អារម្មណ៍ចំពោះជំនឿម៉ឹងម៉ាត់របស់បក្សកុម្មុយនិស្ដ ។ លោកបានសរសេរថា ឧត្ដមគតិបានធ្វើឱ្យគេមានកម្លាំងដ៏ខ្លាំងក្លា“ហួសការប៉ាន់ស្មាន” ។

គ្រូពេទ្យអាមេរិកឈ្មោះ ម៉ា ហៃតឺ ដែលធ្លាប់ទៅធ្វើការសិក្សានៅភាគខាងជើងនៃខេត្តសាន់ស៊ី មានចំណាប់អារម្មណ៍យ៉ាងខ្លាំងចំពោះស្មារតីពលីកម្ម និងរួមសុខទុក្ខជាមួយគ្នារបស់ទាហានកងទ័ពក្រហម ។ លោកសម្រេចចិត្តចូលជាសមាជិកនៃបក្សកុម្មុយនិស្ដចិន និងរស់នៅក្នុងប្រទេសចិន ដែលជាជនលោកខាងលិចទី ១ ដែលចូលជាសមាជិកនៃបក្សកុម្មុយនិស្ដចិន ។ នៅពេលចាស់ជរា លោកធ្លាប់និយាយថា មនុស្សម្នាក់បើចង់បង្កើតស្នាដៃរបស់ខ្លួន ចាំបាច់ត្រូវតែមានសសរទ្រូងផ្នែកស្មារតីយ៉ាងរឹងមាំ ។

១០០ ឆ្នាំកន្លងទៅនោះ បក្សកុម្មុយនិស្ដចិនបានរក្សាចិត្តដើមដំបូង និងឧត្ដមគតិរបស់ខ្លួន ដឹកនាំប្រជាជនចិនពីការក្រោកឈរឡើង មានជីវភាពធូរធារ ដល់ការហក់ឡើងមានកម្លាំងខ្លាំងក្លា ហើយបានបង្កើតអច្ឆរិយៈសំខាន់ ២ គឺអភិវឌ្ឍន៍សេដ្ឋកិច្ចយ៉ាងឆាប់រហ័ស និងរក្សាស្ថិរភាពសង្គមក្នុងរយៈពេលយូរវែង ។

អ្នកសិក្សាស្រាវជ្រាវអង់គ្លេសឈ្មោះ ម៉ាទីងយ៉ាក ធ្លាប់សរសេរអត្ថបទថា អ្វីដែលមិនបាច់មន្ទិលសង្ស័យនោះ គឺបក្សកុម្មុយនិស្ដចិនជាគណបក្សដែលជោគជ័យបំផុតក្នុងរយៈពេល ១០០ ឆ្នាំកន្លងទៅ ។





នៅពេលក្រុមអ្នកកាសែតចិន និងបរទេសទៅទស្សនាយ៉ានអានដែលត្រូវបានបិទខ្ទប់នៅឆ្នាំ ១៩៤៤ លោកប្រធាន ម៉ៅ សេទុង (រូបទី ១ ខាងស្តាំនៃជួរក្រោយ) ទទួលជួបលោក អែភ្សូស្ថាន (រូបទី ២ ខាងស្តាំនៃជួរមុខ) និងអ្នកកាសែតបរទេសផ្សេងទៀត
1944 年，中外记者团突破封锁访问延安时，毛泽东（后排右一）接见了爱泼斯坦（前排右二）和其他外国记者 资料图片

នៅឆ្នាំ ១៩៨០ លោកសាស្រ្តាចារ្យ ម៉ា ហៃតឺ ដែលមានអាយុ ៧០ ឆ្នាំហើយ ជួយព្យាបាលជំងឺស្បែកឱ្យកូនក្មេង
1980 年，70 岁的马海德教授为小患者看病 资料图片

## “យកចិត្តទុកដាក់ចំពោះប្រជាជន និងបម្រើប្រយោជន៍ប្រជាជននៅគ្រប់ពេលវេលា”

“始终心系人民、服务人民”

អ្នកនិពន្ធប៉ូឡូញឈ្មោះ អែភ្សូស្ថាន ដែលបានចូលសញ្ជាតិចិន និងចូលជាសមាជិកបក្សកុម្មុយនិស្តចិន បានសរសេរក្នុងអត្ថបទមួយដែលចុះផ្សាយតាមកាសែត“The New York Time” ថា កងទ័ពលេខ ៨(ដឹកនាំដោយបក្សកុម្មុយនិស្តចិន) បានរក្សាទំនាក់ទំនងជិតស្និទ្ធជាមួយប្រជាជន ។ គេមិនយកអ្វីទាំងអស់ពីប្រជាជនទេ ។

លោក Edgar Snow ធ្លាប់ពិពណ៌នាអំពីភាគខាងជើងខេត្តសាន់ស៊ីថាជាតំបន់ក្រីក្រជាងគេមួយនៅប្រទេសចិន ។ បច្ចុប្បន្ន ក្រោយពីបានអនុវត្តគោលនយោបាយកាត់បន្ថយភាពក្រីក្រដោយតម្រង់ទិស តំបន់នេះក៏ដូចជាតំបន់ក្រីក្រផ្សេងៗទៀតនៃប្រទេសចិន បានដកខ្លួនចេញពីភាពក្រីក្ររួចរាល់ទៅហើយ ។ ក្រោយពីបានអនុវត្តគោលនយោបាយកែទម្រង់ និងបើកចំហ មានប្រជាជនចិនជាង ៧០០ លាននាក់បានរួចខ្លួនផុតពីភាពក្រីក្រ ។

នៅឆ្នាំ ២០២០ ដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ប្រទេសចិនបានប្រកាន់ខ្ជាប់នូវគោលការណ៍ដែលផ្តល់អាទិភាពដល់អាយុជីវិត លើកទឹកចិត្តឱ្យប្រជាជនទូទាំងប្រទេសចូលរួមយុទ្ធនាការប្រយុទ្ធប្រឆាំងនឹងជំងឺឆ្លង ។ ក្នុងនោះ សមាជិកបក្សកុម្មុយនិស្តចិនបានដើរតួនាទីនាំមុខគេជាប់រហូត ។

លោកគ្រូពេទ្យ យ៉ាង ក្លីស្ទីន អេជឹក ដែលមកពីប្រទេសហ្គាបុង ធ្វើការនៅមន្ទីរពេទ្យមួយក្នុងក្រុងក្វាងចូវ ។ លោកធ្លាប់ចូលរួមការងារគ្រប់គ្រងការរាតត្បាតនៃជំងឺកូវីដ-១៩ ក្នុងសហគមន៍ជាមួយសមាជិកបក្សកុម្មុយនិស្តចិនច្រើនរូប ដើម្បីពិនិត្យសុខភាពអ្នកជំងឺក្តៅខ្លួន ។ លោកបានបញ្ជាក់ថា នេះជាការងារមានគ្រោះថ្នាក់ ប៉ុន្តែ សមាជិកបក្សទាំងអស់គ្នាមិនដែលត្អូញត្អែរសោះ ។ ពួកគេខិតខំធ្វើការ មានក្តីក្លាហាន ពីព្រោះពួកគេស្រឡាញ់មាតុភូមិរបស់ខ្លួន ហើយចង់ថែរក្សាប្រជាជនរបស់ប្រទេសខ្លួន ។

តាមសៀវភៅគម្របស“ប្រតិបត្តិការរបស់ប្រទេសចិនអំពីការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩” ដែលប្រកាសនៅខែមិថុនា ឆ្នាំ ២០២០ បានឱ្យដឹងថា ក្នុងប្រទេសចិនមានសមាជិក និងកម្មាភិបាលបក្សកុម្មុយនិស្តចិនជាង ៣៩ លាននាក់ធ្វើការងារនៅសមរភូមិប្រយុទ្ធជំងឺកូវីដ-១៩ ហើយមានសមាជិក ឬកម្មាភិបាលបក្សជិត ៤០០ នាក់បានពលីជីវិតរបស់ខ្លួន ដើម្បីការពារអាយុជីវិតរបស់ប្រជាជន ។





លោក អែភ្ជស្ថាន កំពុងសរសេរអត្ថបទ
爱泼斯坦在写作 资料图片

លោក លីន ម៉ែក កំពុងបង្រៀនសិក្ខាកាមក្នុងវគ្គបណ្តុះបណ្តាលបច្ចេកទេសវិទ្យុជាន់ខ្ពស់នៅភូមិភាគយោធា ជីនឆាជី
林迈可为晋察冀军区无线电技术高级训练班学员授课 新华社 图

## “បើមានរឿង ត្រូវពិគ្រោះពិភាក្សាជាមួយប្រជាជន”

“有事跟群众商量”

មិត្តបរទេសមួយចំនួនដែលបានចូលសញ្ជាតិចិនធ្លាប់ត្រូវជ្រើសតាំងជាសមាជិកសភាប្រឹក្សានយោបាយប្រជាជនទូទាំងប្រទេសចិន ដើម្បីចូលរួមប្រព័ន្ធនយោបាយប្រជាធិបតេយ្យដែលមានលក្ខណៈពិសេសចិន។ ពួកគេខិតខំបំពេញភារកិច្ចរបស់ខ្លួន និងបានលើកសំណើ និងមតិដ៏មានតម្លៃលើវិស័យសុខាភិបាល និងការអប់រំជាដើម ។ នៅឆ្នាំ២០១៥ រដ្ឋាភិបាលចិនបានសួរយោបល់ពីអ្នកជំនាញការបរទេសជាលើកទី ១ នៅពេលសរសេររបាយការណ៍ការងាររដ្ឋាភិបាល ។

លោក មូសថាហ្វា ដែលធ្វើការនៅទីភ្នាក់ងារព័ត៌មានស៊ូដង់ជាង ១០ ឆ្នាំនោះ ធ្លាប់ធ្វើការ និងរស់នៅមួយរយៈពេលក្នុងប្រទេសចិន ។ លោកមានការយល់ដឹងរបស់ខ្លួនចំពោះប្រទេសចិន និងគណបក្សកុម្មុយនិស្តចិន ។ លោកបានបញ្ជាក់ថា “បើនិយាយចំពោះគណបក្សកុម្មុយនិស្តចិន អំណាចគ្រាន់តែជាមធ្យោបាយមួយសម្រាប់បម្រើប្រយោជន៍ប្រជាជនចំណែកយុទ្ធសាស្រ្ត និងផែនការអភិវឌ្ឍន៍ទាំងអស់សុទ្ធតែធ្វើឡើងដើម្បីបម្រើប្រយោជន៍របស់ប្រជាជន ។”

លោក ខឺ ម៉ាខៃ ប្រធានគណៈកម្មាធិការអន្តរជាតិនៃសមាគមសហប្រតិបត្តិការឧស្សាហកម្មចិន បានបញ្ជាក់ថាគណបក្សកុម្មុយនិស្តចិនពូកែបំផុសមហាជនទទួលការពិនិត្យពីប្រជាជន ហើយមានរឿងកើតឡើង ក៏ធ្វើការពិគ្រោះពិភាក្សាជាមួយប្រជាជន ។

ក្រោមការដឹកនាំពីគណបក្សកុម្មុយនិស្តចិន ប្រព័ន្ធនយោបាយសង្គមនិយមដែលមានលក្ខណៈពិសេសចិនត្រូវបានកែលម្អជាបន្តបន្ទាប់ ដែលបានធានាឱ្យប្រជាជនអាចចូលរួមការបោះឆ្នោត ការប្រឹក្សានយោបាយ ការសម្រេចបែបប្រជាធិបតេយ្យ អភិបាលកិច្ច និងការអធិការកិច្ចបែបប្រធាធិបតេយ្យ ហើយបានបង្ហាញពីកម្លាំងរស់រវើកដ៏ខ្លាំងក្លា ។



លោក តឹង សៀវភីង និងលោក ហានស៍ មីឡេ
邓小平和汉斯 · 米勒 资料图片



នៅថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៩ មន្ត្រីរដ្ឋាភិបាលចិនទៅសួរសុខទុក្ខជាមួយអ្នកទទួល“គ្រឿង ឥស្សរិយយសមិត្តភាព” លោកស្រី យីសាបែ ខឺលូក ហើយចូលរួមការអបអរខួបកំណើត ១០៤ ឆ្នាំរបស់លោកស្រី
2019 年 12 月 15 日，中国政府官员看望 “友谊勋章” 获得者伊莎白 · 柯鲁克，并为其庆祝 104 岁生日 资料图片

## “ត្រូវធ្វើដំណើរតាមផ្លូវសហប្រតិបត្តិការដែលជាជម្រើសរបស់ប្រទេសចិន”

### “应该走中国选择的合作道路”

លោក លីន ម៉ែក មកពីប្រទេសអង់គ្លេស ។ លោកជាស្ថាបនិកមួយរូបនៃការផ្សាយសំឡេងជាភាសាអង់គ្លេសនៃទីភ្នាក់ងារព័ត៌មានស៊ីនហួចិន ។ នៅខែ កញ្ញា ឆ្នាំ ១៩៤៤ ក្រោមការជួយឧបត្ថម្ភពីលោក ទីភ្នាក់ងារព័ត៌មានស៊ីនហួចិនចាប់ផ្តើមផ្សាយសំឡេងជាភាសាអង់គ្លេស ដែលបានធ្វើឱ្យពិភពលោកស្តាប់ឮសំឡេងពីយ៉ានអាន ។

បច្ចុប្បន្ន ទស្សនទាន និងសំឡេងចិនបានសាយភាយដល់គ្រប់ទីកន្លែងលើពិភពលោក ហើយមានមនុស្សកាន់តែច្រើនទទួលស្គាល់ និងគាំទ្រប្រទេសចិន ។

ឈរលើគោលការណ៍រួមគ្នាពិគ្រោះពិភាក្សា ស្ថាបនា និងចែករំលែកគ្នា ប្រទេសចិនបានចុះហត្ថលេខាលើលិខិតស្តីពីកិច្ចសហប្រតិបត្តិការ“ខ្សែក្រវាត់ និងផ្លូវ”ចំនួន ២០១ ជាមួយប្រទេសចំនួន ១៣៨ និងអង្គការអន្តរជាតិចំនួន ៣១ ។ “ខ្សែក្រវាត់ និងផ្លូវ”បានក្លាយជាវេទិកាសហប្រតិបត្តិការធំជាងគេ និងជាផលិតផលសាធារណៈសំខាន់បំផុតលើពិភពលោក ។

កូនប្រុសរបស់លោក លីន ម៉ែក ឈ្មោះ លីន តឺសាយ បានបញ្ជាក់ថា សព្វថ្ងៃ ប្រទេសចិនកំពុងដើរតួនាទីសំខាន់ក្នុងកិច្ចការអន្តរជាតិ ។ ប្រទេសធំផ្សេងទៀតត្រូវធ្វើកិច្ចសហ-ប្រតិបត្តិការជាមួយប្រទេសចិនទើបអាចដោះស្រាយបញ្ហាប្រឈមរបស់មនុស្សជាតិបាន ដូចជាបម្រែបម្រួលអាកាសធាតុ ការថែរក្សាជីវចម្រុះ និងការគ្រប់គ្រងជំងឺឆ្លងលើពិភពលោកជាដើម ។

គណបក្សកុម្មុយនិស្តចិនបានបង្កើតទំនាក់ទំនងជាមួយគណបក្ស ឬអង្គការនយោបាយជាង ៦០០ នៃប្រទេស ឬតំបន់ចំនួនជាង ១៦០ លើពិភពលោក ហើយបានបង្កើតបណ្តាញទំនាក់ទំនងជាមួយគណបក្សជាដៃគូគ្រប់ជ្រុងជ្រោយលើពិភពលោក ។

# អបអរសាទរការទទួលបានសមិទ្ធផលដ៏អស្ចារ្យរបស់បក្សកុម្មុយនិស្តចិន

## 为中国共产党的伟大成就喝彩



ដោយបណ្ឌិត ជា មុនីឫទ្ធី ប្រធានសមាគមអ្នកស្រាវជ្រាវវឌ្ឍនភាពកម្ពុជា-ចិន
柬中关系发展学会会长 谢莫尼勒博士

中国共产党始终坚持以人民为中心的根本立场，自成立以来，一直致力于推动人民共同富裕、维护人民权益、增进人民福祉。中国共产党始终坚定走和平发展道路，无论国际形势如何变化，无论自身发展如何。在中国共产党的领导下，没有人能剥夺中国人民追求美好生活的权利，也没有人能阻止中国向前发展的步伐。

ចាប់តាំងពីឆ្នាំ ២០០៨ ខ្ញុំមានឱកាសបានទៅទស្សនកិច្ចប្រទេសចិនលើសពី ៣០ ដង ហើយខ្ញុំសង្កេតឃើញថា ការអភិវឌ្ឍរបស់ប្រទេសចិនក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ បានផ្តល់ឱ្យខ្ញុំនូវអារម្មណ៍ដ៏ភ្ញាក់ផ្អើលបំផុតដែលថា ល្បឿននៃការអភិវឌ្ឍប្រទេសចិនមានសម្ទុះយ៉ាងលឿនជាទីបំផុត ។ ល្បឿនអភិវឌ្ឍន៍ប្រទេសចិនអាចប្រៀបប្រដូចទៅនឹងល្បឿនផ្លូវដែកល្បឿនលឿន ។ ខ្ញុំយល់ថាប្រទេសចិនកាន់តែទំនើបពីមួយឆ្នាំទៅមួយឆ្នាំ ហើយបច្ចេកវិទ្យាជឿនលឿនជាច្រើន បានក្លាយជាផ្នែកមួយនៃជីវិតរស់នៅប្រចាំថ្ងៃរបស់ប្រជាជនចិន ដូចជាល្បឿនអ៊ីនធឺណេត ៥G និងការទូទាត់សាច់ប្រាក់តាមប្រព័ន្ធទូរស័ព្ទជាដើម ។ ទាំងនេះពិតជាមិនអាចកាត់ផ្តាច់ពីអភិបាលកិច្ចប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលរបស់បក្សកុម្មុយនិស្តចិននោះឡើយ ។

បក្សកុម្មុយនិស្តចិនបានធ្វើកំណែទម្រង់បក្ស និងកំណែទម្រង់រដ្ឋឱ្យកាន់តែប្រសើរយ៉ាងខ្លាំង ។ ប្រទេសចិនដែលមានបក្សកុម្មុយនិស្តចិនបានយកគោលការណ៍សង្គមនិយមតាមបែបផែនចិនជាស្នូល បានបង្កើតឡើងនូវអព្ភូតហេតុអច្ឆរិយភាពធំទាំងពីរគឺ ទី១-សេដ្ឋកិច្ចរីកចម្រើនយ៉ាងឆាប់រហ័ស និងទី២-សង្គមរក្សាបាននូវស្ថិរភាពរយៈពេលយូរអង្វែងចាប់តាំងពីបក្សកុម្មុយនិស្តចិនបានបង្កើតរបបសាធារណរដ្ឋប្រជាមានិតចិន ។

លើសពីនេះ ប្រទេសចិនក្រោមការដឹកនាំរបស់បក្សកុម្មុយនិស្តចិនបានចូលរួមចំណែកយ៉ាងសកម្មនៅក្នុងការលើកកម្ពស់ពហុភាគីនៅក្នុងសេដ្ឋកិច្ចពិភពលោក និងជាកម្លាំងចលករថ្មីនៃសន្តិភាព ស្ថិរភាពការអភិវឌ្ឍប្រកបដោយចីរភាព បរិយាបន្ន និងវិបុលភាព ។

យើងគួររំលេចផងដែរថា ក្រោមការដឹកនាំរបស់ឯកឧត្តម ស៊ី ជីនភីង ដែលជាស្នូលនៃសង្គមនិយមតាមបែបផែនចិន គឺជាមាគ៌ាមួយក្រាលដោយមាសដែលបក្សកុម្មុយនិស្តចិន ដោយបានការចូលរួម និងការគាំទ្រយ៉ាងពេញទំហឹងរបស់ប្រជាជនចិនទាំងមូលបានខិតខំប្រឹងប្រែងអស់រយៈពេលជិតមួយសតវត្សរ៍ ។ ជោគជ័យដ៏អស្ចារ្យដែលសម្រេចបានលើមាគ៌ានេះបង្ហាញថា ក្រោមការដឹកនាំរបស់បក្សកុម្មុយនិស្តចិន ប្រទេសចិន និងប្រជាជនចិននឹងបន្តបង្កើតអព្ភូតហេតុកាន់តែច្រើនឡើងថែមទៀតសម្រាប់ប្រទេសចិន និងពិភពលោក ។

អ្វីដែលគួឱ្យបញ្ជាក់នោះគឺ ការផ្តល់ជូនដល់ជីវភាពរស់នៅយ៉ាងសមរម្យ និងថ្លៃថ្នូជូនដល់ប្រជាជនចិន ដែលជាប្រជាជនមានចំនួនច្រើនជាងគេបង្អស់នៅក្នុងពិភពលោក គឺជាអម្រែកយ៉ាងធ្ងន់ដែលបក្សកុម្មុយនិស្តចិនបានរែក និងជួយរំលែកពីស្មារបស់ពិភពលោក ។ ក្រោមការដឹកនាំរបស់បក្សកុម្មុយនិស្តចិន ប្រជាជនចិនបានចាកផុតពីភាពក្រីក្រ និងបានរស់នៅក្នុងជីវភាពយ៉ាងសមរម្យជាទីបំផុត ។

បក្សកុម្មុយនិស្តចិនបានលើកឡើងគំនិតផ្តួចផ្តើម“ខ្សែក្រវ៉ាត់ និងផ្លូវ” ដែលជាទស្សនវិជ្ជាថ្មីសម្រាប់បង្កើតឡើងនូវសហគមន៍ជោគវាសនារួម ដែលឈរលើផលប្រយោជន៍រួម និងឈ្នះ-ឈ្នះ ។

បក្សកុម្មុយនិស្តចិនចង់សម្រេចបានវឌ្ឍនភាពដែលគោលបំណងធំបំផុត គឺចង់ឱ្យប្រជាជនចិនមានជីវភាពសម្បូរធូរធារ ការប្រកាន់ខ្ជាប់នូវទស្សនៈអភិវឌ្ឍន៍ដែលចាត់ទុកប្រជាជនជាស្នូល ជួយប្រជាជនសម្រេចសុបិនដែលមានជីវភាពល្អប្រសើរ នោះជាគោលដៅតស៊ូមិនអាចប្រែប្រួលបាន ។ តាំងពីពេលបង្កើតឡើង បក្សកុម្មុយនិស្តចិនតែងដាក់ការជំរុញប្រជាជនចិនឱ្យមានជីវភាពសម្បូរធូរធាររួមគ្នា ថែរក្សាការពារផលប្រយោជន៍ និងបង្កើនសុភមង្គលឱ្យកាន់តែល្អ ។ ការដើរតាមមាគ៌ាអភិវឌ្ឍន៍ដោយសន្តិវិធី ជាជម្រើសយុទ្ធសាស្ត្ររបស់បក្សកុម្មុយនិស្តចិនក្នុងការដឹកនាំប្រទេសចិន ដោយមិនងាករេ មិនថាស្ថានភាពអន្តរជាតិប្រែប្រួលយ៉ាងណាក៏ដោយ មិនថាខ្លួនរីកចម្រើនដល់កម្រិតណាក៏ដោយ បក្សកុម្មុយនិស្តចិននឹងនៅតែបន្តធ្វើជាអ្នកកសាងសន្តិភាពជូនពិភពលោក អ្នកចូលរួមចំណែកវឌ្ឍន-ភាពជូនពិភពលោក និងអ្នកការពាររបៀបរៀបរយអន្តរជាតិជារៀងរហូត ។ ក្រោមការដឹកនាំរបស់បក្សកុម្មុយនិស្តចិន គ្មានអ្នកណាអាចដកហូតសិទ្ធិស្វែងរកជីវភាពល្អប្រសើររបស់ប្រជាជនចិនបាន ហើយក៏គ្មានអ្នកណាអាចរារាំងជំហានវិវឌ្ឍន៍ទៅមុខរបស់ប្រទេសចិនបានដែរ ។

ឆ្នាំ ២០២១ ជាខួប ១ សតវត្សរ៍នៃការបង្កើតបក្សកុម្មុយនិស្តចិន ដែលជាគណបក្សនយោបាយដ៏អស្ចារ្យមួយសម្រាប់ប្រទេសចិននិយាយដោយឡែក សម្រាប់ពិភពលោកនិយាយរួម ។ បក្សកុម្មុយនិស្តចិនបានដឹកនាំប្រជាជនចិនទទួលបានឯករាជ្យជាតិ ស្ថិរភាពសង្គម ការអភិវឌ្ឍសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស និងការកសាងឡើងវិញនូវប្រទេសជាតិដ៏អស្ចារ្យ ។ នេះមិនត្រឹមតែជាភ័ព្វសំណាងសម្រាប់ប្រជាជនចិនប៉ុណ្ណោះទេ ថែមទាំងសម្រាប់ប្រជាជនពិភពលោកផងដែរ ។ ចាប់តាំងពីការធ្វើកំណែទម្រង់ និងការបើកចំហរបស់ប្រទេសចិន ផែនការដែលបានបង្កើតអស់ជាច្រើនសតវត្សរ៍ត្រូវបានបញ្ចប់ជាជំហានៗ ។ មនុស្សជាតិទាំងអស់បាន និងកំពុងសាទរដល់បក្សកុម្មុយនិស្តចិនក្នុងការបញ្ចប់យ៉ាងរលូនក្នុងពេលឆាប់ៗនូវការស្តារភាពអស្ចារ្យឡើងវិញនៃប្រជាជាតិចិន ។

# ប្រទេសចិនជាមិត្តពិតរបស់កម្ពុជា

## 中国是柬埔寨的真朋友



ដោយលោក តូច ណារត្ន អគ្គនាយករងវិទ្យុជាតិកម្ពុជា ទទួលបន្ទុកគ្រប់គ្រងវិទ្យុជាតិ FM ៩៦ MHz និងបណ្តាស្ថានីយវិទ្យុFM ជាតិ តាមបណ្តារាជធានី-ខេត្តទូទាំងប្រទេស

柬埔寨新闻部国家广播电台总局副总局长、柬埔寨 FM96 MHz 及首都金边—全国各省国家调频广播电台负责人 杜 · 纳洛

2021年，对于中国共产党而言是值得庆祝的重要年份。对于柬中关系的发展而言，2021年是充满希望的一年。无论国际风云如何变幻，中国和柬埔寨始终坚定如一，共同推动构建柬中命运共同体行动计划，并在涉及两国核心利益问题上继续相互支持。

ប្រទេសកម្ពុជា និងចិនជា"មិត្តដែកថែប" និងជាដៃគូជិតស្និទ្ធ ។ ជារៀងរហូតមក ប្រទេសទាំងពីរជួយឈឺឆ្អាលគ្នា ផ្តល់ការគាំទ្រដល់គ្នាទៅវិញទៅមក ហើយផ្តោតការយកចិត្តទុកដាក់លើចំណងមិត្តភាពប្រពៃណី ។ បច្ចុប្បន្ន ឈរលើទីចាប់ផ្តើមប្រវត្តិសាស្ត្រថ្មី យើងត្រូវប្រកាន់ខ្ជាប់កាលានុវត្តនភាពប្រវត្តិសាស្ត្រ ដើម្បីជំរុញឱ្យកិច្ចសហប្រតិបត្តិការគ្រប់វិស័យឈានដល់កម្រិតកាន់តែខ្ពស់ ។

ប្រទេសចិនមានសុភាសិតបុរាណមួយថា "ឃើញមនោសញ្ចេតនាពិតប្រាកដនៅគ្រាអាសន្ន ស្វែងយល់ពីចិត្តមនុស្សក្រោយពីស្គាល់គ្នាបានយូរ" ។ រដ្ឋាភិបាល និងប្រជាជនចិនតែងតែឈរនៅជាមួយប្រជាជនកម្ពុជានៅគ្រាក្រ ។ ជាច្រើនឆ្នាំចុងក្រោយនេះ ប្រទេសចិនបានផ្តល់ការគាំទ្រយ៉ាងពេញទំហឹង និងជំនួយឧបត្ថម្ភដ៏ច្រើនដល់ប្រទេសកម្ពុជា ក្នុងការអភិវឌ្ឍវិស័យកសិកម្ម សាងសង់ហេដ្ឋារចនាសម្ព័ន្ធ កាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍវិស័យសុខាភិបាលជាដើម ។

ខណៈពេលជំងឺកូវីដ-១៩ បានបណ្តាលឱ្យកម្ពុជាជួបនឹងវិបត្តិដ៏ធ្ងន់ធ្ងរ ប្រទេសចិនបានផ្តល់ជំនួយដល់កម្ពុជាឱ្យទាន់ពេលវេលា ។ ប្រទេសចិនមិនត្រឹមតែបានចាត់បញ្ជូនក្រុមវេជ្ជបណ្ឌិតទៅធ្វើការនៅកម្ពុជាប៉ុណ្ណោះទេ ហើយបានផ្តល់ដល់កម្ពុជានូវការគាំទ្រផ្នែកបច្ចេកទេស សម្ភារៈបរិក្ខារពេទ្យ



នៅខែ មេសា ឆ្នាំ ២០២១ នារីខ្មែរម្នាក់ទទួលចាក់វ៉ាក់សាំងប្រយុទ្ធជំងឺកូវីដ-១៩Sinovac របស់ប្រទេសចិននៅរាជធានីភ្នំពេញ
2021 年 4 月，一名柬埔寨女子在金边接种中国科兴新冠疫苗 新华社 图

និងវ៉ាក់សាំងប្រយុទ្ធជំងឺកូវីដ-១៩ ។ គិតមកដល់ពេលនេះ វ៉ាក់សាំងចិនរាប់លានដូសត្រូវបានដឹកជញ្ជូនមកដល់កម្ពុជា ដែលបានបញ្ជាក់ឱ្យឃើញថា ប្រទេសចិន និងប្រជាជនចិនដែលដឹកនាំដោយគណបក្សកុម្មុយនិស្តចិន ជាមិត្តពិតរបស់ប្រទេស និងប្រជាជនកម្ពុជា ។

ឆ្នាំ ២០២១ ជាឆ្នាំសំខាន់ដែលគួរជាទីអបអរសាទរ និងរំលឹកសម្រាប់គណបក្សកុម្មុយនិស្តចិន ហើយក៏ជាឆ្នាំដែលពោរពេញទៅដោយក្តីសង្ឃឹមសម្រាប់ការពង្រឹងទំនាក់ទំនងចិន និងកម្ពុជាផងដែរ ។ មិនថាស្ថានភាពអន្តរជាតិមានការផ្លាស់ប្តូរយ៉ាងណាក្តី ចិន និងកម្ពុជានឹងជំរុញការកសាងសហគមន៍ជោគវាសនារួមយ៉ាងម៉ឺងម៉ាត់ បន្តគាំទ្រគ្នាទៅវិញទៅមកលើបញ្ហាដែលទាក់ទងនឹងអត្ថប្រយោជន៍ស្នូលរវាងប្រទេសទាំងពីរ ។

បើនិយាយអំពីកិច្ចសហប្រតិបត្តិការរវាងប្រព័ន្ធផ្សព្វផ្សាយនៃប្រទេសកម្ពុជា និងចិន ឆ្នាំ ២០២១ នេះគឺជាឆ្នាំដែលពោរពេញទៅដោយក្តីសង្ឃឹម ។ ប៉ុន្មានឆ្នាំចុងក្រោយនេះ ប្រព័ន្ធផ្សព្វផ្សាយនៃប្រទេសកម្ពុជា និងចិនបានរក្សាការផ្លាស់ប្តូរទស្សនកិច្ចជាញឹកញាប់ និងរៀបចំកម្មវិធីបណ្តុះបណ្តាលកាន់តែច្រើន ហើយបានទទួលនូវសមិទ្ធផលជាផ្លែផ្កា ។ គួរបញ្ជាក់ថា ចាប់ពីខែ កក្កដា ឆ្នាំ ២០២០ មក វិទ្យុជាតិ FM ៩៦ MHz កម្ពុជាបានបង្កើតកិច្ចសហប្រតិបត្តិការអំពីការផ្លាស់ប្តូរអត្ថបទព័ត៌មានជាមួយទស្សនាវដ្តី“ខ្មែរ” ។ ក្នុងរយៈពេលមួយឆ្នាំកន្លងទៅនោះ ភាគីទាំងពីរបានទទួលជោគជ័យក្នុងការផ្លាស់ប្តូរព័ត៌មានលើវិស័យនយោបាយ វប្បធម៌ និងចំណងមិត្តភាពជាដើម ។ ខ្ញុំសង្ឃឹមថា នៅឆ្នាំ ២០២១ នេះ ភាគីទាំងពីរនឹងអាចពង្រីក និងពង្រឹងកិច្ចសហប្រតិបត្តិការឱ្យកាន់តែស៊ីជម្រៅថែមទៀត និងបង្កើនការស្វែងយល់គ្នារវាងមិត្តអ្នកអាននៃប្រទេសទាំងពីរ ។

# ប្រទេសចិនទទួលសមិទ្ធផលមហិមា

## 中国取得了伟大成就



ដោយលោក ទាវ សារៈមុន្នី អគ្គនិពន្ធនាយកនៃកាសែត“រស្មីកម្ពុជា”
《柬埔寨之光》总编辑 迪欧 · 萨拉莫尼

中国共产党领导下的中国一直秉持和平外交政策，尊重各国主权，对所有国家一视同仁，不会畏强欺弱。此外，中国共产党领导下的中国对一些发展相对落后的国家提供援助，因此中国共产党得到了很多国家和人民的支持与信任。

ខ្ញុំធ្លាប់បានទៅបំពេញទស្សនកិច្ចផ្លូវការក្នុងនាមប្រតិភូក្រសួងព័ត៌មាន ដែលរៀបចំដោយស្ថានទូតចិនប្រចាំព្រះរាជាណាចក្រកម្ពុជាចំនួនមួយដង នៅខែ កញ្ញា ឆ្នាំ ២០០១ ។ ក្រោមការដឹកនាំរបស់បក្សកុម្មុយនិស្តចិន ដែលរក្សាបាននូវវប្បធម៌ដ៏ចំណាស់ និងដឹកនាំធ្វើឱ្យមហាប្រទេសចិនមានការរីកចម្រើនយ៉ាងខ្លាំង ។ ខ្ញុំសូមកោតសរសើរ ។

នាពេលក្រោយៗមក មានការអញ្ជើញឱ្យខ្ញុំទស្សនកិច្ច និងចូលរួមព្រឹត្តិការណ៍ជាច្រើនលើកទៀតនៅប្រទេសចិន តែខ្ញុំពុំបានចូលរួម ។ ប៉ុន្តែសហការីរបស់ខ្ញុំជាច្រើនរូបសុទ្ធតែបានមកបំពេញទស្សនកិច្ចនៅប្រទេសចិនជាបន្តបន្ទាប់ដែរ ។ តាមការឧទ្ទេសនាមពីសហការីខ្ញុំ ព្រមទាំងតាមរយៈព័ត៌មាន និងឯកសារបង្ហាញជាច្រើនបានបញ្ជាក់ថា ទីកន្លែងដែលខ្ញុំធ្លាប់បានទៅនាពេលនោះ គឺមានការផ្លាស់ប្តូរមុខមាត់ថ្មីថែមទៀតយ៉ាងឆាប់រហ័ស ។ យើងទាំងអស់គ្នាយល់ឃើញថា ក្រោមការដឹកនាំពីគណបក្សកុម្មុយនិស្តចិន ប្រទេសចិនដែលមានប្រជាជនជាង ១ ៤០០ លាននាក់នេះបានទទួលនូវសមិទ្ធផលអភិវឌ្ឍន៍គួរឱ្យកត់សម្គាល់ ពិតជាអស្ចារ្យណាស់ ។

ហេតុអ្វីបានជាក្រោមការដឹកនាំរបស់គណបក្សកុម្មុយនិស្តចិន ប្រទេសចិនអាចមានការផ្លាស់ប្តូរគួរជាទីកត់សម្គាល់ ? ខ្ញុំសូមយកតែបួនចំណុចក្នុងចំណោមចំណុចសំខាន់ៗជាច្រើនដែលខ្ញុំយល់ឃើញ ។

ទី១-សង្គមនិយមដែលមានលក្ខណៈពិសេសចិនប្រកបទៅដោយកម្លាំងរស់រវើក ក្រោមការដឹកនាំពីគណបក្សកុម្មុយនិស្តចិន ។ គណបក្សកុម្មុយនិស្ត



មាត់ទន្លេហួងភូក្នុងក្រុងសៀងហៃ
上海外滩 CFP 图

ចិនដឹកនាំប្រជាជនចិនធ្វើដំណើរតាមមាគ៌ាសង្គមនិយម ហើយបង្កើតរបបសហប្រតិបត្តិការពហុបក្ស ប្រឹក្សានយោបាយ តំបន់ស្វយ័តជនជាតិភាគតិច និងរបបគ្រប់គ្រងស្វយ័តមហាជនមូលដ្ឋានជាដើម ។ ពិសេសគឺការផ្លាស់ប្តូរជីវភាពរបស់ប្រជាជនចិនបានយ៉ាងឆាប់រហ័ស និងរឹងមាំ ។ ប្រជាជនចិនបានក្លាយជាប្រជាជនដែលមានចំណូលកម្រិតខ្ពស់ និងជាប្រជាជនដែលធ្វើទេសចរណ៍ក្រៅប្រទេសច្រើនជាងគេបំផុតលើពិភពលោក ។ បក្សកុម្មុយនិស្តចិនមាននយោបាយការបរទេសទន់ភ្លន់ រស់រវើក ទៅគ្រប់ប្រទេសទាំងអស់ មិនថាប្រទេសអ្នកមាន ឬប្រទេសទន់ខ្សោយ ។ ទំនាក់ទំនងការបរទេសប្រកបដោយភាពស្មើសិទ្ធិ ស្មើភាព គោរពអធិប-តេយ្យភាពនៃប្រទេសនីមួយៗហើយបានផ្តួចផ្តើមលើការអភិវឌ្ឍ និងជួយដល់ប្រទេសដែលទន់ខ្សោយ ។ ប្រការនេះបានធ្វើឱ្យបក្សកុម្មុយនិស្តចិនទទួលបាននូវការគាំទ្រ ការពេញចិត្តទាំងក្នុង និងក្រៅប្រទេស ដែលជាការធានាដល់កិត្យានុភាពនៃបក្សកុម្មុនិស្តចិន ។

ទី២-បក្សកុម្មុយនិស្តចិនមានថ្នាក់ដឹកនាំកំពូលល្អៗ មានសមត្ថភាពក្នុងការដឹកនាំ និងសម្លឹងបានមុន បានវែងឆ្ងាយចំពោះការវិវត្តប្រែប្រួលនៃពិភពលោក ទាំងនយោបាយសេដ្ឋកិច្ច និងឱជីជថល ។ បក្សកុម្មុយនិស្តចិនមានថ្នាក់ដឹកនាំល្អៗគ្រប់លំដាប់ថ្នាក់ មានគុណភាព មានប្រសិទ្ធភាព ចូលរួមក្នុងការអនុវត្ត ចូលរួមក្នុងការដឹកនាំអនុវត្តនូវរាល់គោលនយោបាយ ផែនការអភិវឌ្ឍន៍ទាំងឡាយដែលកំណត់ដោយបក្សកុម្មុយនិស្តចិន ។

ទី៣-គឺមានការចូលរួមគាំទ្រពីគ្រប់កម្លាំងទាំងអស់នៃសង្គមចិនសម័យទំនើប ពិសេសពីប្រជាជនចិនទាំងមូលដែលប្រមូលផ្តុំបានជាកម្លាំងមហាសាមគ្គីក្នុងការជំរុញប្រទេសចិនឱ្យក្លាយទៅជាប្រទេសមហាអំណាចសេដ្ឋកិច្ច ។ នេះជាចំណុចសំខាន់ដែលមិនអាចខ្វះបាន ។

ទី៤-នៅថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៥៨ ប្រទេសចិន និងកម្ពុជា បានចាប់ផ្តើមមានទំនាក់ទំនងការទូតជាផ្លូវការ ។ ចាប់តាំងពីមានចំណងទាក់ទងការទូតរយៈពេលជាងកន្លះសតវត្សរ៍កន្លងមកនេះ មិត្តភាពជាប្រពៃណីរវាងប្រទេសចិន និងកម្ពុជាដែលត្រួសត្រាយដោយថ្នាក់ដឹកនាំជំនាន់មុន និងថ្នាក់ថ្នមថែរក្សាយ៉ាងយកចិត្តទុកដាក់ដោយថ្នាក់ដឹកនាំជំនាន់ក្រោយៗរបស់ប្រទេសកម្ពុជា និងចិន បានទទួលការរីកចម្រើនពីមួយឆ្នាំទៅមួយឆ្នាំ ។ សូមជូនពរមិត្តភាពកម្ពុជា-ចិន ឋិតថេរអមតៈ ។

# គារវកិច្ចចំពោះគណបក្សកុម្មុយនិស្តចិនដ៏អស្ចារ្យ

## 致敬伟大的中国共产党



ដោយលោក ប៉ាង រតនា មន្ត្រីស្រាវជ្រាវនៃវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា
柬埔寨王家研究院国家语言研究所研究员 邦 · 拉达纳

当提起中国发展的辉煌成就时，人们不会忘记感谢中国共产党和中国人民的伟大领袖毛泽东、中国改革开放的总设计师邓小平以及江泽民、胡锦涛等中共中央领导人，更不会忘记感谢如今正在带领中国人民取得伟大成就的习近平。他们，将与中国共产党百年成就一同彪炳史册。

តើមកពីមូលហេតុអ្វីដែលធ្វើឱ្យប្រទេសចិនរក្សានិន្នាការអភិវឌ្ឍន៍ដ៏ខ្លាំងក្លា ក្រោមស្ថានការណ៍អន្តរជាតិដ៏ស្មុគស្មាញ? នេះមកពីគំនិតផ្តួចផ្តើម "ខ្សែក្រវាត់ និងផ្លូវ"ដែលលើកឡើងដោយឯកឧត្តម ស៊ី ជីនភីង ។ "ខ្សែក្រវាត់ និងផ្លូវ"ឆ្លងកាត់ដីគោកអាស៊ី-អឺរ៉ុប ដែលជាក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច វប្បធម៌ និងបច្ចេកវិទ្យាដែលមានអត្ថន័យកាន់តែស៊ីជម្រៅ មានក្របខ័ណ្ឌកាន់តែទូលាយ និងមានកម្រិតកាន់តែខ្ពស់ជាងពាណិជ្ជកម្ម ។ ម្យ៉ាងទៀត ក្នុងសៀវភៅ"ស៊ី ជីនភីង : អភិបាលកិច្ចប្រទេសចិន"នៅមានបទពិសោធន៍ថ្មីមួយគឺ កែលម្អ និងអភិវឌ្ឍន៍របបសង្គមនិយមដែលមានលក្ខណៈពិសេសចិន និងជំរុញការធ្វើទំនើបភាវូបនីយកម្មនៃប្រព័ន្ធអភិបាលកិច្ច និងសមត្ថភាពគ្រប់គ្រង ។ តាមរយៈការធ្វើកំណែទម្រង់យ៉ាងស៊ីជម្រៅ អនុវត្តខ្លាំងនូវយុទ្ធនាការប្រឆាំងអំពើពុករលួយ និងបង្កើនសុពលភាពនៃប្រព័ន្ធច្បាប់ ។

៥ ឆ្នាំចុងក្រោយនេះ ប្រទេសចិនបានប្រកាន់ខ្ជាប់នូវទស្សនទានអភិវឌ្ឍន៍ចំនួន ៥ គឺ ច្នៃប្រឌិត សម្របសម្រួល មានពណ៌បៃតង បើកទូលាយ និងចែករំលែកគ្នា ផ្លាស់ទម្រង់អភិវឌ្ឍន៍តាមរយៈការផ្លាស់ទស្សនទានអភិវឌ្ឍន៍ លើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការអភិវឌ្ឍតាមរយៈការផ្លាស់ទម្រង់អភិវឌ្ឍន៍ ដែលបានបង្ហាញឱ្យឃើញពីជំនឿចិត្ត និងការប្តេជ្ញាចិត្តអំពីការអភិវឌ្ឍនៃប្រទេសចិន ព្រមទាំងជំនឿដ៏រឹងមាំរបស់ចិនក្នុងការបន្តចូលរួមចំណែកសេដ្ឋកិច្ចពិភពលោកគ្រប់ជ្រុងជ្រោយ ។


សហាគមន៍ប្រវត្តិសាស្ត្រ និងវប្បធម៌ "សានហ្វាងឈីសៀង" ក្នុងក្រុងហ្វូចូវនៃខេត្តហុកគៀន
福建省福州市三坊七巷历史文化街区 新华社 图

តាមរយៈការបង្ហាញរបស់ឯកឧត្តម ស៊ី ជីនភីង កាលពីថ្ងៃទី ១ ខែ តុលា ឆ្នាំ ២០១៩ ក្នុងពិធីអបអរសាទរខួបលើកទី ៧០ នៃការបង្កើតសាធារណរដ្ឋប្រជាមានិតចិននៅក្រុងប៉េកាំងថា ក្នុងដំណើរឆ្ពោះទៅមុខ ប្រទេសចិនត្រូវប្រកាន់ខ្ជាប់នូវការដឹកនាំរបស់បក្សកុម្មុយនិស្តចិន និងប្រកាន់ខ្ជាប់ឋានៈជាម្ចាស់របស់ប្រជាជន ក៏ដូចជាប្រកាន់ខ្ជាប់នូវមាគ៌ាសង្គមនិយមដែលមានលក្ខណៈពិសេសរបស់ចិន ។ ទាំងនេះបានធ្វើឱ្យប្រទេសចិនធ្វើដំណើរទៅមុខកាន់តែឆ្ងាយ ។

កាលណានិយាយពីភាពរុងរឿងរបស់ប្រទេសចិន នាពេលនេះ គេមិនដែលភ្លេចគិតទៅដល់ឯកឧត្តម ម៉ៅ សេទុង ដែលជាស្ថាបនិកដ៏សំខាន់ដែលបានបង្កើតបក្សកុម្មុយនិស្តចិនដំបូង ហើយក៏មិនភ្លេចគិតទៅដល់បិតាកែទម្រង់ឯកឧត្តម តឹង សៀវភីង និងថ្នាក់ដឹកនាំកំពូលជាច្រើនរូបទៀតដូចជា ឯកឧត្តម ហ្សាំង ជីមីន និងឯកឧត្តម ហ៊ូ ជីនថាវ ជាដើម រហូតដល់មិនភ្លេចអរគុណជាមហិមាដល់ស្ថាបនិកអភិវឌ្ឍន៍ដ៏អស្ចារ្យនាពេលបច្ចុប្បន្នគឺឯកឧត្តមប្រធានាធិបតីចិន ស៊ី ជីនភីង ។ ភាពរុងរឿងរបស់ប្រទេសចិននាពេលបច្ចុប្បន្ននេះ ត្រូវបានប្រវត្តិសាស្ត្រផ្លូវការរបស់ចិនចាត់ទុកថាជាស្នាដៃដ៏ធំមហិមារបស់ថ្នាក់ដឹកនាំកំពូលៗ និងអស្ចារ្យនៃគណបក្សកុម្មុយនិស្តចិន ។

# សំឡេង
# 声音

在中国共产党百年华诞来临之际，世界多国政党政府领导人和友好人士，热烈祝贺中国共产党成立 100 周年。

## លោកជំទាវ ឃួន សុដារី សមាជិកអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា និងជាអនុប្រធានទី ២ រដ្ឋសភាកម្ពុជា

គណបក្សកុម្មុយនិស្តចិនមិនគ្រាន់តែបានដឹកនាំប្រទេសចិនទទួលបាននូវសមិទ្ធផលអភិវឌ្ឍន៍គួរឱ្យកត់សម្គាល់ប៉ុណ្ណោះទេ ហើយថែមទាំងបានដើរតួនាទីសំខាន់ក្នុងការគាំពារសណ្តាប់ធ្នាប់អន្តរជាតិ ជំរុញការអភិវឌ្ឍប្រព័ន្ធពហុភាគីនិយម និងដោះស្រាយបញ្ហាប្រឈមលើពិភពលោកទាំងមូលទៀតផង ។

## លោកជំទាវ Bidhya Devi Bhandari ប្រធានាធិបតីនេប៉ាល់

ក្រោមការដឹកនាំពីគណបក្សកុម្មុយនិស្តចិន ប្រទេសចិនបានក្លាយជាប្រទេសទំនើប ជឿទុកចិត្តលើខ្លួនឯង និងមានកម្លាំងខ្លាំងក្លាមួយ ។ ប្រទេសចិនបានកាត់បន្ថយភាពក្រីក្រជូនប្រជាពលរដ្ឋរាប់រយលាននាក់ និងបានបង្កើតស្នាដៃដ៏អស្ចារ្យដែលមិនធ្លាប់មានពីមុនមក ។ ការជោគជ័យរបស់ប្រទេសចិនបាន និងកំពុងលើកទឹកចិត្តឱ្យប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើនលើពិភពលោកក្នុងការអភិវឌ្ឍប្រទេសពឹងលើខ្លួនឯង ទទួលការគោរពពីគេ និងស្វែងរកវិបុលភាពរបស់ប្រទេសជាតិ ។

## ឯកឧត្តម Ilham Aliyev ប្រធានគណបក្សអាស៊ែបៃហ្សង់ថ្មី និងជាប្រធានាធិបតីអាស៊ែបៃហ្សង់

ប្រវត្តិសាស្ត្រដ៏ត្រចះត្រចង់របស់ប្រទេសចិន គឺជាប្រវត្តិសាស្ត្រខិតខំឧស្សាហ៍ព្យាយាមរបស់គណបក្សកុម្មុយនិស្តចិន ។ ក្រោមការដឹកនាំពីគណបក្សកុម្មុយនិស្តចិន ប្រទេសចិនបានទទួលសមិទ្ធផលច្រើនគួរឱ្យកត់សម្គាល់លើគ្រប់វិស័យ និងមានកិត្តិសព្ទកាន់តែខ្លាំងឡើងៗលើពិភពលោក ហើយបានផ្តល់ផលប្រយោជន៍ជាក់ស្តែងដល់ប្រជាជនចិន និងប្រជាជននៃបណ្តាប្រទេសនានា ។

## ឯកឧត្តម Ivica Dačić ប្រធានគណបក្សសង្គម និងជាប្រធានសភាស៊ែប៊ី

ក្នុងរយៈពេលមួយសតវត្សរ៍កន្លងទៅ គណបក្សកុម្មុយនិស្តចិនបានឆ្លងកាត់ភាពបត់បែន និងការសាកល្បងដ៏ច្រើន តែពុំដែលលះបង់ចិត្តដើមដំបូងនៅឡើយ ហើយបានខិតខំប្រឹងប្រែងដើម្បីសម្រេចនូវឯករាជ្យភាព វិវឌ្ឍនភាពសង្គម និងសុភមង្គលប្រជាជន ។

ក្នុងឱកាសនៃការអបអរសាទរខួបលើកទី ១០០ ឆ្នាំនៃការបង្កើតគណបក្សកុម្មុយនិស្តចិន អ្នកដឹកនាំបក្ស និងឥស្សរជននៃប្រទេសផ្សេងៗបានសម្តែងនូវការអបអរសាទរចំពោះខួបលើកទី ១០០ ឆ្នាំនៃការបង្កើតគណបក្សកុម្មុយនិស្តចិន ។

## ឯកឧត្តម Roman Golovchenko នាយករដ្ឋមន្ត្រីបេឡារុស្ស

គណបក្សកុម្មុយនិស្តចិនបានដឹកនាំប្រជាជនចិនធ្វើដំណើរតាមផ្លូវដ៏ជោគជ័យ ដែលប្រកបទៅដោយភាពលំបាក ហើយបានទទួលនូវសមិទ្ធផលដ៏ត្រចះត្រចង់គួរជាទីកត់សម្គាល់ រួមមានការជោគជ័យនៃកិច្ចកាត់បន្ថយភាពក្រីក្រ ការគ្រប់គ្រងជំងឺកូវីដ-១៩ និងការអភិវឌ្ឍសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស ។ ទាំងនេះបានឆ្លុះបញ្ចាំងឱ្យឃើញពីប្រព័ន្ធអភិបាលកិច្ចដែលមានប្រសិទ្ធភាពខ្ពស់ និងការជឿទុកចិត្តលើខ្លួនឯងរបស់គណបក្សកុម្មុយនិស្តចិន ។

## ឯកឧត្តម Gennady Zyuganov ប្រធានគណៈកម្មាធិការកណ្តាលនៃគណបក្សកុម្មុយនិស្តរុស្ស៊ី

ចាត់ទុកប្រជាជនជាគោល និងបំពេញតម្រូវការរបស់ប្រជាជន គឺជាទស្សនៈនយោបាយដែលបក្សកុម្មុយនិស្តចិនអនុវត្តទៅតាមជារៀងរហូតមក ។ អាស្រ័យលើទស្សនៈនេះ គណបក្សកុម្មុយនិស្តចិនបានដឹកនាំប្រទេសចិនទទួលបាននូវសមិទ្ធផលអភិវឌ្ឍន៍ដ៏អស្ចារ្យ និងបានបង្ហាញពីឧត្តមភាពដ៏ធំសម្បើមនៃរបបសង្គមនិយម ។

## លោកជំទាវ Nalinee Taveesin ទីប្រឹក្សាប្រធានបក្ស និងជាប្រធានគណៈកម្មការកិច្ចការបរទេសនៃគណបក្ស Pheu Thai

ដំណើរអភិវឌ្ឍន៍នៃគណបក្សកុម្មុយនិស្តចិនអាចបំផុសគំនិតដល់គណបក្សនយោបាយនៃប្រទេសផ្សេងៗ ពោលគឺ“គណបក្សនយោបាយត្រូវរក្សាទំនាក់ទំនងស្អិតល្មួតជាមួយមហាជន គ្រប់គ្រងប្រទេសដើម្បីផលប្រយោជន៍ប្រជាជន ខិតខំឧស្សាហ៍ព្យាយាមដើម្បីពង្រឹងភាពស្អាតស្អំ និងបែងចែកសមិទ្ធផលអភិវឌ្ឍសេដ្ឋកិច្ចដោយកាន់តែមានភាពយុត្តិធម៌ និងតម្លាភាព ។”

## ឯកឧត្តម Alberto Fernández ប្រធានាធិបតីអាហ្សង់ទីន

គណបក្សកុម្មុយនិស្តចិនអាចសម្របទៅនឹងការផ្លាស់ប្តូរនៃយុគសម័យ ហើយមានជំនាញក្នុងការបូកសរុបបទពិសោធន៍នៅដំណាក់កាលផ្សេងៗ ខិតខំឧស្សាហ៍ព្យាយាម និងបានដើរតួនាទីសំខាន់ក្នុងដំណើរអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមចិន ។

(វេបសាយនៃក្រសួងទំនាក់ទំនងអន្តរជាតិនៃមជ្ឈិមបក្សកុម្មុយនិស្តចិន)

中共中央对外联络部网站




# ក្រុងគុនមីងរាប់អានជាមួយលោកអ្នក
# គុនមីងអបអរខួប ១០០ ឆ្នាំនៃការបង្កើតបក្សកុម្មុយនិស្តចិន !

## 友好昆明｜庆祝中国共产党成立 100 周年！

红色的灯光、红色的鲜花，近一个月来，“红色”成为昆明的主色调，昆明人以最靓丽的颜色，献礼中国共产党成立 100 周年。昆明在全市范围内组织开展形式多样、丰富多彩的文娱活动，以大合唱、交响乐、音乐剧、朗诵、舞蹈、绘画、书法、摄影等多种艺术形式为党创造的辉煌成就喝彩。

ក្នុងរយៈពេលមួយខែកន្លងទៅនោះ ភ្លើងក្រហម និងផ្កាស្រស់បានតំណាងឱ្យពណ៌សំខាន់នៃក្រុងគុនមីង ។ គុនមីងបានយកពណ៌ស្រស់ស្អាតជាងគេសម្រាប់ចូលរួមការអបអរសាទរខួបលើកទី ១០០ ឆ្នាំនៃការបង្កើតគណបក្សកុម្មុយនិស្តចិន ។

រដ្ឋបាលក្រុងគុនមីងបានរៀបចំសន្និសីទសារព័ត៌មាន ២៥ លើក ដើម្បីអបអរសាទរខួបលើកទី ១០០ ឆ្នាំនៃការបង្កើតគណបក្សកុម្មុយនិស្តចិន សំដៅបង្ហាញពីសមិទ្ធផលសំខាន់ និងការរីកចម្រើនលូតលាស់នៃក្រុងគុនមីងលើវិស័យសេដ្ឋកិច្ច នយោបាយ វប្បធម៌ សង្គមកិច្ច អេកូ-អរិយធម៌ និងការពង្រឹងសមត្ថភាពបក្សជាដើម ។ រដ្ឋបាលក្រុងក៏បានរៀបចំកម្មវិធីសម្តែងសិល្បៈគ្រប់ប្រភេទដូចជា ច្រៀងចម្រៀង ប្រគំតន្ត្រី សម្តែងល្ខោនភ្លេង រាំរបាំ គូរគំនូរ សរសេរអក្សរផ្ចង់ និងថតរូបជាដើម ដើម្បីបង្ហាញពីសមិទ្ធផលអភិវឌ្ឍន៍នៃគណបក្សកុម្មុយនិស្តចិន ។

សមាជិកក្រុមកុមារឈានមុខនៃគណបក្សកុម្មុយនិស្តចិន ឈ្មោះ ឈីន ជួនស៊ី បាននិយាយថា ទង់បក្សមានពណ៌ក្រហមដែលជ្រលក់ពណ៌ដោយឈាមរបស់វីរបុរសច្រើនរាប់មិនអស់ ។ កន្សែងក្រហមដែលខ្ញុំបានពាក់នោះក៏មានពណ៌ក្រហមដែរ ដែលជាពណ៌របស់ព្រះអាទិត្យទើបរះ ។ នេះគឺជាការបន្តវេនស្មារតីបដិវត្តន៍ និងជាការបន្តវេនភារកិច្ចរបស់យើង ។ យើងទាំងអស់គ្នាត្រូវខិតខំរៀនសូត្រ ដើម្បីធ្វើជាកុមារល្អ និងជាអ្នកបន្តវេនក្នុងយុគសម័យថ្មីនៃបុព្វហេតុងើបឡើងវិញរបស់ប្រជាជាតិចិន ។

(ផ្នែកឃោសនាការនៃគណៈកម្មាធិការបក្សកុម្មុយនិស្តចិនក្រុងគុនមីង)

昆明市委宣传部供稿 人民视觉 图




# ដើរចូលក្នុងក្រុងយូស៊ី
# មិនភ្លេចចិត្តដើមដំបូង ចងចាំបេសកកម្មបានច្បាស់

## 走进玉溪｜不忘初心 牢记使命
### ——庆祝中国共产党成立 100 周年

6月 30 日，“不忘初心　牢记使命”玉溪市庆祝中国共产党成立 100 周年成就展在玉溪市博物馆开展。展览充分展示了玉溪人民百年来在中国共产党领导下，完成新民主主义革命和推进社会主义建设、改革、复兴事业的光辉历程，聚焦玉溪的重大历史事件、杰出历史人物和优秀共产党人，再现中国共产党的光辉历程和不朽功勋。

នៅថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០២១ ពិព័រណ៍សមិទ្ធផលអបអរសាទរខួបលើកទី ១០០ ឆ្នាំនៃការបង្កើតគណបក្សកុម្មុយនិស្តចិន បានរៀបចំនៅសារមន្ទីរក្រុងយូស៊ី ក្រោមប្រធានបទ“មិនភ្លេចចិត្តដើមដំបូង ចងចាំបេសកម្មបានច្បាស់”។ ពិព័រណ៍នេះបានដាក់តាំងបង្ហាញនូវដំណើរវិវឌ្ឍន៍នៃការធ្វើបដិវត្តប្រជាធិបតេយ្យថ្មី និងការសាងសង់ កែទម្រង់ស្តារឡើងវិញនូវសង្គមនិយម ហើយនិងព្រឹត្តិការណ៍ប្រវត្តិសាស្ត្រសំខាន់ៗ តួអង្គប្រវត្តិសាស្ត្រល្បី និងសមាជិកបក្សកុម្មុយនិស្តចិនដ៏ឆ្នើម ព្រមទាំងដំណើរវិឌ្ឍន៍ដ៏ត្រចះត្រចង់ និងគុណបំណាច់ធំធេងរបស់បក្សកុម្មុយនិស្តចិន ។

អ្នកក្រុងយូស៊ីឈ្មោះ ចាំង បានប្រាប់អ្នកកាសែតថា ក្រុងយូស៊ីមានទេសភាពស្រស់ស្អាត សម្បូរធនធានធម្មជាតិ ហើយជាក្រុងឈានមុខនៅខេត្តយូណាន ។ ការអភិវឌ្ឍរបស់យើងមិនអាចកាត់ផ្តាច់ពីការដឹកនាំរបស់គណបក្សកុម្មុយនិស្តចិនទេ ។

យប់ថ្ងៃទី ១ ខែ កក្កដា ក្រុងយូស៊ីបានរៀបចំកម្មវិធីបាញ់កាំជ្រួច ។ កាំជ្រួចដែលមានពណ៌ចម្រុះ និងរូបរាងពិពិធកម្មនោះ ត្រូវបានបាញ់ទៅក្នុងលំហរអាកាសនាពេលរាត្រី ដែលបានបង្កើតជាគំរូចម្រុះពណ៌ដ៏ស្រស់ស្អាតមួយផ្ទាំង និងបានទាក់ទាញអ្នកក្រុងដ៏ច្រើនសន្ធឹកមកទស្សនា ។ អ្នកក្រុងឈ្មោះ លីវ បានបញ្ជាក់ថា “ខ្ញុំសង្ឃឹមថា មាតុប្រទេសយើងនឹងអាចមានភាពរុងរឿងថ្កុំថ្កើង ហើយសង្ឃឹមថាគណបក្សកុម្មុយនិស្តចិននឹងអាចដឹកនាំយើងទាំងអស់គ្នាដើរឆ្ពោះទៅកាន់ជីវភាពរស់នៅកាន់តែល្អប្រសើរ !”

(ផ្នែកឃោសនាការនៃគណៈកម្មាធិការបក្សកុម្មុយនិស្តចិនក្រុងយូស៊ី)

玉溪市委宣传部供稿供图




# ជួបនឹងក្រុងអាននីង  បង្កើតគណបក្សកុម្មុយនិស្តចិន ១០០ ឆ្នាំ ប្រទេសមានសុខសន្តិភាពមួយសតវត្សរ៍

## 遇见安宁｜建党百年 家国安宁

未来五年，安宁市的发展目标是地区生产总值力争突破1200 亿元；城市建成区面积突破 70 平方公里，常住人口城镇化率突破 85%；农村居民人均可支配收入突破30000 元……2035 年前，在云南省率先基本实现社会主义现代化，成为中国共同富裕示范（县）市。安宁的快速发展，离不开国家繁荣稳定，离不开中国共产党的领导。

ក្នុងរយៈពេល ៥ ឆ្នាំខាងមុខ  គោលដៅអភិវឌ្ឍន៍នៃក្រុងអាននីងគឺសម្រេចនូវតម្លៃផលិតផលក្នុងតំបន់លើសពី ១២០ ០០០ លានយាន់ប្រាក់ចិន  ពង្វាតទំហំទីក្រុងដល់ជាង ៧០ គីឡូម៉ែត្រការ៉េ  ប្រជាជនអចិន្ត្រៃយ៍ធ្វើនគរូបនីយកម្មលើសពី ៨៥％  ប្រជាជនក្នុងតំបន់ជនបទបានចំណូលជាមធ្យមសម្រាប់មនុស្សម្នាក់ៗលើសពី ៣ ម៉ឺនយាន់ ។ ល ។  មុនឆ្នាំ ២០៣៥  ក្រុងអាននីងនឹងសម្រេចនូវការធ្វើទំនើបភាវូបនីយកម្មកសិកម្មជាទូទៅមុនគេបង្អស់នៅខេត្តយូណាន  ហើយក្លាយជាក្រុង(ស្រុក)គំរូដែលមានភាពធូរធាររួមក្នុងប្រទេសចិន ។

ការរីកចម្រើនយ៉ាងឆាប់រហ័សរបស់ក្រុងអាននីង  មិនអាចកាត់ផ្តាច់ពីវិបុលភាពជាតិ  និងការដឹកនាំពីគណបក្សកុម្មុយនិស្តចិនបានទេ ។

ដើម្បីអបអរសាទរខួបលើកទី ១០០ ឆ្នាំនៃការបង្កើតគណ-បក្សកុម្មុយនិស្តចិន  និងសម្តែងនូវចិត្តដឹងគុណបក្សកុម្មុយនិស្តចិន  អ្នកក្រុងអាននីងបានខិតខំកែលម្អសោភណភាពទីក្រុងឱ្យបានប្រែមុខមាត់ជាថ្មី  ដោយបានបង្ហូតឡើងនូវទង់ក្រហមតាមផ្លូវតូចធំ  ដាំផ្កាស្រស់ស្អាតនៅគ្រប់ទីកន្លែង  ចំណែកស្លាកពាណិជ្ជកម្ម  និងកញ្ចក់ទូរទស្សន៍នៅកន្លែងសាធារណៈសុទ្ធតែបង្ហាញអក្សរ  និងរូបភាពសម្រាប់ការអបអរសាទរខួបលើកទី ១០០ ឆ្នាំនៃការបង្កើតគណបក្សកុម្មុយនិស្តចិន ។  ទាំងនេះបានឆ្លុះបញ្ចាំងឱ្យឃើញពីទំនាក់ទំនងជិតស្និទ្ធរវាងប្រជាជននិងគណបក្សក្នុងក្រុងអាននីង ។

អ្នកតំណាងដែលមកពីស្ថាប័ន ១៥  តំណាងប្រជាជននិងតំណាងសិស្សនិស្សិត ៥០០ នាក់  បានច្រៀងបទចម្រៀង "ច្រៀងចម្រៀងជូនគណបក្ស"  ដែលបានបង្ហាញឱ្យឃើញពីមនោសញ្ចេតនាស្រឡាញ់គណបក្ស  ស្រឡាញ់មាតុប្រទេសនិងស្រឡាញ់ស្រុកកំណើតរបស់ពួកគេ ។

កម្មវិធីអបអរសាទរខួបលើកទី ១០០ ឆ្នាំនៃការបង្កើតគណបក្សកុម្មុយនិស្តចិននឹងត្រូវរៀបចំជាបន្តបន្ទាប់ក្នុងឆ្នាំនេះ ដើម្បីបង្ហាញពីជំនឿចិត្ត  និងការប្តេជ្ញាចិត្តរបស់អ្នកក្រុងអាននីងក្នុងការដើរឆ្ពោះទៅមុខជាមួយគណបក្សកុម្មុយនិស្តចិន ។

(ផ្នែកឃោសនាការនៃគណៈកម្មាធិការបក្សកុម្មុយនិស្តចិនក្រុងអាននីង)

安宁市委宣传部供稿供图



云桥网
WWW.YUNNANGATEWAY.COM
แม่น้ำโขง
《湄公河》
ຈຳປາ
《占芭》
မင်္ဂလာ
《吉祥》
ខ្មែរ
《高棉》
2021
SEE CHINA
SEE YUNNAN
WWW.YUNNANGATEWAY.COM
Amazing Yunnan

# 庆祝中国共产党成立100周年

**The 100th Anniversary of the Founding of The Communist Party of China**

